ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ អន្លង់វែង៖ ស្រមោលនៃសាសនានៅក្នុងដំណើរការនៃការស្វែងរកសន្តិភាព

◆ សិល្បៈក៏ជាឧបករណ៍សម្រាប់ការព្យាបាល និងធ្វើឱ្យជាសះស្បើយ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៨ ខែកុម្ភៈ ឆ្នាំ២០១៨

# ស្វែងរកការពិត

លេខ២១៨ ខែកុម្ភៈ ឆ្នាំ២០១៨

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ អន្លង់វែងៈ ស្រមោលនៃសាសនានៅក្នុងដំណើរការ ............................១

**ផ្នែកឯកសារ**

◆ ផៀង វ៉ាន់ទឿង ពលទោដ្ឋាយមួយអនុសេនាធំលេខ១១៥ ...................៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ វេទិកាថ្នាក់រៀនស្ដីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ....................៩

◆ វគ្គបណ្ដុះបណ្ដាលស្ដីពីការចងក្រង ស្រាវជ្រាវ ប្រវត្តិសាស្ត្រ.............១២

◆ អតីតកងទ័ពជើងទឹកខ្មែរក្រហមបានរំឭកពីបទពិសោធ........................១៥

◆ ជីវិតតស៊ូជាមួយខ្មែរក្រហម......................................................១៨

◆ ពីមេដឹកនាំដែលប្រព្រឹត្តអំពើឃោរឃៅ មកជាមេដឹកនាំដែល ..............២០

◆ ជីវភាពរស់នៅរបស់ប្រជាជននៅអន្លង់វែងមុន និងក្រោយ ................២២

◆ ការបែងចែករបបអាហារក្នុងរបបខ្មែរក្រហម ..................................២៤

◆ មិនហ៊ាននៅផ្ទះនាពេលថ្ងៃ........................................................២៦

◆ បទពិសោធដំបូងរបស់ខ្ញុំនៅក្នុងទឹកដី តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ........២៨

◆ អ៊ិន លន មានទោសប្រហារជីវិតដោយសារដេកលក់ជ្រុល ................៣១

**ផ្នែកច្បាប់**

◆ អំណះអំណាងមេធាវីការពារក្ដីរបស់ នួន ជា ក្នុងការបិទបញ្ចប់.......៣៣

**វេទិកាពិភាក្សាសាធារណៈ**

◆ សិល្បៈក៏ជាឧបករណ៍សម្រាប់ការព្យាបាល និងធ្វើឲ្យជាសះស្បើយ ...៤២

**ធំព័រស្រាវជ្រាវរកគ្រួសារ**

◆ ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ .......................៤៦

◆ ព្រលឹងមាសម្ដាយ .............................................................៥២

◆ ដំណើរស្វែងរកម្ដាយមីងដែលបាត់ខ្លួន ......................................៦០



អ៊ឹម បែម នៅប្រាសាទព្រះវិហារ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ លី សុខឃាង, មីន សាណាស់, សោម លាភ, ឆេង ហាក់, ឈួន សុធារ, អែម ណាឃីម, ឡុង ដានី, វ៉ូនិត អារី, ស សារិន, អ៊ុង វណ្ណា, ហេឡែន គ្រាន **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ឆេង វើង, ហូ ថុនា, ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ** ៖ យូ វលក្ខណ៍ **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន, ឡុង ដានី **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, khmerrougehistory.org www.truthcambodia.com**

# អន្លង់វែងៈ ស្រះមោលនៃសាសនា នៅក្នុងដំណើរការនៃការស្វែងរកសន្តិភាព

*ខ្ញុំសូមចែករំលែកមតិរបស់ខ្ញុំអំពីការបែរទៅកាន់គ្រិស្តសាសនារបស់លោកស្រី អ៊ឹម ចែម ក៏ដូចជាតួនាទីរបស់គ្រិស្តសាសនាក្នុងដំណើរការស្វែងរកសន្តិភាពរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។*

*សាសនាមានតួនាទីយ៉ាងសំខាន់ក្នុងដំណើរការស្វែងរកសន្តិភាពនៅស្រុកអន្លង់វែង ដែលជាលំនៅស្ថានរបស់អតីតកម្មាភិបាលខ្មែរក្រហមជាច្រើន ។ សម្រាប់ប្រជាជនកម្ពុជាមួយចំនួនធំ សាសនាផ្តល់នូវសន្តិភាពផ្លូវចិត្តដល់បុគ្គលនីមួយៗ តាមរយៈការជួយឲ្យសះស្បើយរបួសផ្លូវចិត្តរបស់បុគ្គល ការជួយឲ្យបុគ្គលលើកលែងទោសឲ្យបច្ចាមិត្ត និងធ្វើការផ្សះផ្សាជាមួយអតីតកាល ។*

*ព្រះពុទ្ធសាសនានិកាយថេរវាទគឺជាសាសនាដែលនាំមុខក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែសម្រាប់បុគ្គលមួយចំនួន ព្រះពុទ្ធសាសនានិកាយថេរវាទមិនអាចផ្តល់សន្តិភាពផ្លូវចិត្តគ្រប់គ្រាន់ឡើយ ។ ដូច្នេះហើយ ទើបបុគ្គលទាំងនេះតែងតែស្វែងរកប្រភពដទៃដើម្បីទទួលបាននូវសន្តិភាពផ្លូវចិត្តដូចជាគ្រិស្តសាសនា ។ ប្រជាជនកម្ពុជាជាច្រើនបានបែរទៅកាន់គ្រិស្តសាសនា ។ ក្នុងនោះរួមមានបុគ្គលដែលមានកេរ្តិ៍ឈ្មោះអាក្រក់ដូចជា កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ និង អ៊ឹម ចែម ជាអតីតគណៈស្រុកព្រះនេត្រព្រះ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាជនសង្ស័យ*



*អ៊ឹម ចែម អុជធូបនៅប្រាសាទព្រះវិហារ*

នៅក្នុងករណី០០៤ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដោយសារអន្លង់វែងជាអតីតតំបន់កាន់កាប់របស់ចលនាខ្មែរក្រហម ប្រជាជនស្រុកអន្លង់វែងជាច្រើនបានជួបប្រទះនឹងឧបសគ្គក្នុងការស្វែងរកសន្តិភាពផ្លូវចិត្តចាប់តាំងពីបានធ្វើសមាហរណកម្មចូលមកក្នុងរាជរដ្ឋាភិបាលកម្ពុជារយៈពេល២០ឆ្នាំកន្លងមក ។ ប្រមាណជា១០ឆ្នាំមុនសមាហរណកម្មនៅអន្លង់វែងបានជួបប្រទះនូវការផ្លាស់ប្តូរយ៉ាងសំខាន់មួយ គឺការជ្រាបចូលមកវិញនៃព្រះពុទ្ធសាសនា ។ ការផ្លាស់ប្តូរនេះមានភាពផ្ទុយស្រលះអំពីគោលនយោបាយរបស់ខ្មែរក្រហម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) ដែលបានហាមឃាត់ការប្រតិបត្តិសាសនា និងបានចាត់ទុកមេដឹកនាំសាសនាជាគោលដៅនៃការបោសសម្អាតដំបូងនៅពេលដែលរបបខ្មែរក្រហមចាប់ផ្តើម ។ ចលនាខ្មែរក្រហមដែលមានឈ្មោះផ្លូវការថា របបកម្ពុជាប្រជាធិបតេយ្យ បានជ្រៀតចូលទៅក្នុងសតិអារម្មណ៍ និងវិញ្ញាណរបស់ប្រជាជនកម្ពុជាដើម្បីស៊ើបអង្កេតអំពីសាសនា និងជំនឿ ជាពិសេសព្រះពុទ្ធសាសនា ។

របបកម្ពុជាប្រជាធិបតេយ្យមានគោលបំណងបំបែកសាសនាចេញពី "ឋានសួគ៌" បដិវត្តន៍របស់ខ្លួន ។ របបនេះបានហាមឃាត់យ៉ាងតឹងតែងទៅលើការប្រណិប័តន៍សាសនាប្រតិកិរិយាទាំងឡាយ ។ ខ្មែរក្រហមបានបង្ខំឲ្យព្រះសង្ឃទាំងឡាយសឹក ព្រមទាំងប្រែក្លាយវត្តអារាមនានា ទៅជាមន្ទីរឃុំឃាំង និងកន្លែងធ្វើទារុណកម្ម ក្នុងចេតនាប្រមាថមើលងាយទៅលើជំនឿសាសនារបស់ប្រជាជន ។

ក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យត្រង់ជំពូក១៥ អំពីសិទ្ធិខាងជំនឿនិងសាសនា ត្រង់មាត្រា២០ បានចែងថា "ប្រជាជនកម្ពុជាគ្រប់រូប មានសិទ្ធិជឿជំនឿ ឬសាសនាណាក៏បាន ហើយក៏មានសិទ្ធិមិនមានជំនឿអ្វី ឬក៏មិនជឿសាសនាណាក៏បាន ។ មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយាដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនដាច់ខាត" ។

វៀរលែងការផ្តល់និយមន័យច្បាស់លាស់សម្រាប់ពាក្យ "សាសនាប្រត្តិកិរិយា" កម្មាភិបាលរបស់បក្ស និងរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យតែងតែប្រើប្រាស់និយមន័យដែលខ្លួនយល់ថា ត្រឹមត្រូវជំនួស ។ ទោះបីជាយ៉ាងនេះក្តី ភាពបរាជ័យរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការលុបបំបាត់សាសនា បានបង្ហាញថា សាសនាបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ។ ការប្រណិប័តន៍សាសនាមិនអាចបាត់បង់ដោយសារតែការហាមឃាត់របស់រដ្ឋាភិបាលដែលកំពុងតែកាន់អំណាចបានឡើយ ។

ខ្មែរក្រហមមិនត្រឹមតែបានតាំងចិត្តក្នុងការហាមឃាត់សាសនាឡើយក្នុងរបបរបស់ខ្លួន ខ្មែរក្រហមថែមទាំងបានព្យាយាមដកចំលើងឫសគល់របស់ព្រះពុទ្ធសាសនា (ព្រមទាំងសាសនាអ៊ីស្លាម និងគ្រិស្តសាសនា) ទៀត ។ ដោយហេតុថា របបកុម្មុយនីស្តចាត់ទុកសាសនាជាការគាបសង្កត់បែបចក្រពត្តិមួយប្រភេទ អតីតសមាជិកខ្មែរក្រហមមួយចំនួនបានជួបប្រទះនឹងភាពលំបាកក្នុងការប្រកាន់ខ្ជាប់ព្រះពុទ្ធសាសនាឡើងវិញ ។ ដូច្នេះហើយ អតីតសមាជិកខ្មែរក្រហមទាំងនោះបានចាប់ផ្តើមស្វែងរកសាសនាផ្សេងជាទីពឹង ។

បើទោះបីជាខ្មែរក្រហមបានគាបសង្កត់គ្រិស្តសាសនាដែរក៏ដោយ ប៉ុន្តែសាសនានេះមានសាសនិក និងវិហារចំនួនតិច ដូច្នេះហើយខ្មែរក្រហមមិនបានកំណត់គោលដៅលើគ្រិស្តសាសនាដូចដែលខ្លួនបានធ្វើចំពោះព្រះពុទ្ធសាសនាឡើយ ។ ជាងនេះទៀត អតីតកម្មាភិបាលខ្មែរក្រហមអាចមានអារម្មណ៍ល្អចំពោះគ្រិស្តសាសនាជាងព្រះពុទ្ធសាសនា ដោយសារព្រះពុទ្ធសាសនាបង្រៀនបុគ្គលទាំងឡាយអំពី "ការប្រព្រឹត្តល្អ ទទួលបានផលល្អ ការប្រព្រឹត្តអាក្រក់ទទួលបានផលអាក្រក់" ។ សម្រាប់បុគ្គលដូច ឌុច គុណសម្បត្តិរបស់គ្រិស្តសាសនាគឺជាការបង្រៀនថា បុគ្គលនីមួយៗអាចទទួលសេចក្តីសង្គ្រោះបានដោយការសុំក្តីលើកលែងទោសចំពោះអំពើបាបដែលខ្លួនបានប្រព្រឹត្ត ។ វិធីនេះបានផ្តល់ជាផ្លូវសម្រាប់រត់គេចពីការបង្រៀនពីវាលវដ្តសង្សារនៃព្រះពុទ្ធសាសនា ។

នៅពេលដែលសាសនាណាមួយនាំមុខគេក្នុងសង្គមមួយ កុមារនៅក្នុងសង្គមនោះតែងតែប្រណិប័តន៍សាសនានេះតាំងពីពេលចាប់កំណើត ។ ទោះជាយ៉ាងណាក្តី មិនមែនបុគ្គលគ្រប់រូបប្រកាន់ខ្ជាប់ដដែលអស់មួយជីវិតឡើយ ។ បុគ្គលមួយចំនួនជ្រើសរើសសាសនាដោយផ្អែកលើភាពងាយស្រួល និងការចង់បានសន្តិភាពផ្លូវចិត្ត ។

លោកស្រី អ៊ឹម ចែម កើតនៅក្នុងសង្គមដែលប្រកាន់ព្រះពុទ្ធសាសនា ប៉ុន្តែយោងទៅតាមរបាយការណ៍របស់សារព័ត៌មាន

លោកស្រី អ៊ឹម ចែម បានបែរមកកាន់គ្រិស្តសាសនាវិញនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

មុននឹងបែរទៅកាន់គ្រិស្តសាសនាលោកស្រី អ៊ឹម ចែម បានផ្តួចផ្តើមសាងសង់កុដិក្នុងវត្តមួយនៅភូមិអូរអង្រែ ក្នុងឆ្នាំ២០០២ ។ វត្តនោះបានផ្តល់ឱកាសឲ្យប្រជាជនមូលដ្ឋានធ្វើការគោរពដល់ដូនតារបស់ខ្លួន ដោយការយកចង្ហាន់ទៅប្រគេនព្រះសង្ឃ និងអុជធូបដើម្បីឧទ្ទិសកុសលដល់អ្នកជាទីស្រលាញ់ ។

ការផ្លាស់ប្តូរសាសនាដូចករណីរបស់លោកស្រី អ៊ឹម ចែម លើកជាសំណួរយ៉ាងគួរឲ្យព្រួយបារម្ភអំពីតួនាទីរបស់ព្រះពុទ្ធសាសនាក្នុងការជួយដល់បុគ្គលដែលត្រូវការជំនួយផ្លូវអារម្មណ៍ផ្លូវចិត្ត និងផ្លូវកាយ ។ ឧទាហរណ៍ កូនប្រុសរបស់លោកស្រី អ៊ឹម ចែម បានធ្លាក់ខ្លួនឈឺជាទម្ងន់ ហើយសម្រាកព្យាបាលនៅមន្ទីរពេទ្យមួយក្នុងខេត្តបាត់ដំបង ។ មិនអាចជួយកូនគាត់ក្រៅពីស្ថាប័នគ្រិស្តសាសនាមួយដែលបានផ្តល់ប្រាក់សម្រាប់ថ្ងៃសេវាកម្មព្យាបាលកូនរបស់គាត់ឡើយ ។

តើមានស្ថាប័នដែលអាចជួយអ្នកដែលមានជំងឺធ្ងន់ធ្ងរដែរឬទេ? តើគួរតែមានស្ថាប័នប្រភេទនេះដែរឬទេ? តើមានវិធីដើម្បីបង្កើតស្ថាប័នប្រភេទនេះដែរឬទេ? ទាំងនេះគឺជាសំណួរដ៏សំខាន់ដែលត្រូវការការត្រួតពិនិត្យឡើងវិញ ។

ប្រធានបទនេះ ហាក់បីដូចជាបានធ្វើឲ្យមានការពិចារណានៅក្នុងវិស័យព្រះពុទ្ធសាសនាអំពីដែលព្រះសង្ឃ និងប្រព័ន្ធពុទ្ធសាសនាបានធ្វើ និងអ្វីដែលត្រូវធ្វើ ឬគួរតែធ្វើ ។ យោងទៅតាមរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ ប៉ុន្តែប្រជាពលរដ្ឋទាំងឡាយមានសិទ្ធិក្នុងការប្រកាន់ជំនឿរបស់ខ្លួនៈ «សេរីភាពក្នុងការគោរព និងប្រណិប័តន៍ជំនឿ សាសនារបស់បុគ្គលត្រូវបានធានាដោយរដ្ឋ ក្នុងលក្ខខណ្ឌដែលសេរីភាពនោះមិនប៉ះពាល់ដល់ជំនឿសាសនារបស់បុគ្គលដទៃ ឬសន្តិសុខសាធារណៈ» ។

ជាការពិតណាស់ ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងការជួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមួយចំនួនធំទទួលយកអតីតកាល ។ ទោះជាយ៉ាងនេះក្តី ការពិនិត្យឡើងវិញគួរតែធ្វើឡើងចំពោះតួនាទីដ៏មានប្រសិទ្ធភាពរបស់ព្រះពុទ្ធសាសនានេះ ។

យោងទៅតាមប្រវត្តិសាស្ត្រ ព្រះពុទ្ធសាសនាបានបណ្តុះឲ្យមានសន្តិភាព និងសន្តិសុខនៅក្នុងប្រទេសកម្ពុជាតាមរយៈការប្រណិប័តន៍តាមបែបអហិង្សា ។ ក្នុងពេលថ្មីៗនេះ ការកកើតឡើងវិញនៃព្រះពុទ្ធសាសនានៅស្រុកអន្លង់វែងបានបង្ហាញពីភាពចាំបាច់នៃការផ្សះផ្សាប្រជាជនអន្លង់វែងជាមួយនឹងប្រជាជនដទៃនៅក្នុងប្រទេសកម្ពុជាឡើងវិញ ទាំងក្នុងផ្នែកនយោបាយសង្គម និងផ្នែកអត្តសញ្ញាណសាសនា ។

រហូតមកដល់បច្ចុប្បន្ននេះ គ្រិស្តសាសនាបានទាក់ទាញប្រជាជនជាច្រើនទាំងនៅទីប្រជុំជន និងនៅតំបន់ជនបទ ។ នៅពេលដែលខ្ញុំសាកសួរលោកស្រី អ៊ឹម ចែម ក្នុងពេលថ្មីៗនេះអំពីព្រះពុទ្ធសាសនា និងគ្រិស្តសាសនា លោកស្រីបានរៀបរាប់យ៉ាងម៉ឺងម៉ាត់ថា «មួយជីវិត ធ្វើអ្វីក៏ដើរតែផ្លូវកណ្តាល ។ ឥឡូវខ្ញុំជឿទាំងពីរសាសនា» ។ លោកស្រីក៏បាននិយាយបន្ថែមថា ខ្លួនចង់រៀនសូត្របន្ថែមអំពីសាសនាទាំងពីរ ។ លោកស្រី អ៊ឹម ចែម បានសង្កត់ធ្ងន់ថា «សាសនាទាំងពីរមិនមានខុសគ្នាទេ ប៉ុន្តែសាសនាគ្រិស្ត បើកចំហជាង» ។ នាពេលសព្វថ្ងៃ លោកស្រីបានឈប់អុជធូប តែទោះបីជាយ៉ាងនេះក្តី ក៏លោកស្រីនៅតែបន្តទៅវត្តអារាមដដែល ។

ដូចសម្តីរបស់លោកស្រី អ៊ឹម ចែម គ្រិស្តសាសនាអាចជាប្រភពនៃការព្យាបាល ព្រោះថាសាសនានេះមានភាពបើកចំហជាងសាសនាដទៃ ។ គ្រិស្តសាសនាអនុញ្ញាតឲ្យបុគ្គលទទួលកំហុសចំពោះអំពើអាក្រក់របស់ខ្លួន ហើយជាលទ្ធផលទទួលបានការលើកលែងទោស ។

បុគ្គលមួយចំនួនផ្សេងទៀត អាចមើលឃើញគ្រិស្តសាសនាជាវិធីសាស្ត្រក្នុងការរស់នៅប្រចាំថ្ងៃ តាមរយៈជំនួយផ្លូវចិត្ត និងផ្លូវវិញ្ញាណដែលសាសនានេះផ្តល់ឲ្យ ។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងករណីបន្ទាន់ដូចជំងឺកូនប្រុសរបស់លោកស្រី អ៊ឹម ចែម ស្ថាប័នគ្រិស្តសាសនាបានផ្តល់ជំនួយទាន់ពេលវេលា ។ តើស្ថាប័នដទៃនៅឯណាក្នុងពេលនោះ? យើងគួរតែពិចារណាថា តើលោកស្រី អ៊ឹម ចែម បែរទៅរកគ្រិស្តសាសនាដោយសារជំនឿរបស់លោកស្រីចំពោះព្រះ ឬដើម្បីឆ្លើយតបនឹងតម្រូវការសង្គម ។

**លី សុខឃាង**

# ការិយាល័យព័ត៌មានសាធារណៈ

*"ការិយាល័យព័ត៌មានសាធារណៈ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។*

*មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។*

*តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។*

*ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អន វណ្ណារ៉ា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthvannara@dccam.org ។*





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ ៖ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល ៖ truthchenda.s@dccam.org*

# ខៀង វ៉ាន់ទ្រឿង ពលទោផ្កាយមួយអនុសេនាធំលេខ១៥ វរសេនាធំលេខ២៩ កងពល៣០៧ យោធភូមិភាគទី៥ ចាប់ខ្លួនថ្ងៃទី១៩ តុលា ឆ្នាំ១៩៧៨ នៅរតនៈគិរី

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៧១៧២***

ខៀង វ៉ាន់ទ្រឿង ភេទប្រុស អាយុ២១ឆ្នាំ កើតនៅភូមិចិនដាវ ឃុំមីថ ស្រុកភូមី ខេត្តផាប៊ិញ វៀតណាមកណ្ដាល ជាពលទោផ្កាយមួយ យុទ្ធជនរបស់អនុសេនាតូចលេខ១ អនុសេនាធំជាងលេខ១៥ វរសេនាធំលេខ២៩ កងពលលេខ៣០៧ យោធភូមិភាគទី៥ ត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៩ តុលា ឆ្នាំ១៩៧៨ នៅសមរភូមិអូរយ៉ាដាវ ផ្លូវលេខ១៩ ខេត្តរតនៈគិរី ប្រទេសកម្ពុជា ។ ឯកសារចម្លើយសារភាពរបស់ វ៉ាន់ទ្រឿង បានធ្វើចប់នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨ ដោយ វ៉ាន់ទ្រឿង បានរៀបរាប់ឲ្យដឹងពីដំណើរដែលខ្លួនបានចូលឈ្លានពានកម្ពុជាដូចខាងក្រោម ៖

ចាប់តាំងពីឆ្នាំ១៩៦៤មក ភូមិរបស់ វ៉ាន់ទ្រឿង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់យៀកកុងផង និងធីវគីផង តែយៀកកុងក្ដាប់ញឹកញាប់ជាងធីវគី ។ យៀកកុងមិនចេះដឹកនាំប្រជាជនធ្វើអីទេ គឺគិតតែពីផឹកស្រា និងកាប់សម្លាប់ប្រជាជន ។ ពេលទាហានធីវគីចុះមកម្ដងៗ យៀកកុងបានរត់យកតែរស់ខ្លួនឯង ដោយមិនហ៊ានចេញមុខតតាំងជាមួយធីវគីម្ដងណាឡើយ ។

ខែឧសភា ឆ្នាំ១៩៧៥ បក្សវៀតណាម បានក្ដាប់វៀតណាមខាងត្បូង ។ ក្រោយពេលបានក្ដាប់វៀតណាមខាងត្បូងភ្លាម ក៏លក់ដែកកាំភ្លើងឲ្យសូវៀតភ្លាមដែរ ដោយមានកប៉ាល់ចម្បាំងសូវៀតចតនៅដែកកាំភ្លើងជាច្រើន និងបានដឹកកាំជ្រួច កាំភ្លើងធំរថក្រោះមកជាច្រើន ។ ពូរបស់ វ៉ាន់ទ្រឿង ឈ្មោះ ង្វ៉ី វ៉ាន់តូក ជាអ្នកនេសាទនៅកាំរ៉ាញ់ បាននិយាយថា ប្រជាជននៅកាំរ៉ាញ់ បានជេរបក្សវៀតណាម ថាជាចោរលក់ឯករាជ្យជាតិ លក់ប្រទេសជាតិឲ្យសូវៀត ។ ពេលមុន បារាំងជិះជាន់ ។ បន្ទាប់ពីបារាំងចេញចក្រពត្តិអាមេរិកចូល ប្រជាជនរងទុក្ខឥតល្ហែ ត្រូវចាប់ដាក់គុកច្រវ៉ាក់ និងសម្លាប់ចោល ។ បច្ចុប្បន្ន សូវៀតចូលមកជំនួសចក្រពត្តិអាមេរិក ប្រជាជននឹងត្រូវកាប់សម្លាប់ ។

ខែមីនា ឆ្នាំ១៩៧៦ នៅខេត្តផាប៊ិញទាំងមូល ប្រជាជនប្រឆាំងនឹងបក្សវៀតណាមខ្លាំងណាស់ ហើយបានបាចខិត្តបណ្ណពាសពេញ ។ ខិតបណ្ណបានសរសេរថា “បក្សវៀតណាមត្រូវឈប់ទារពន្ធដារ ត្រូវដោះស្រាយជីវភាពឲ្យប្រជាជនភ្លាម ហើយត្រូវឈប់ចាប់យុវជនឲ្យធ្វើជាទាហានឈ្លានពានកម្ពុជាជាបន្ទាន់” ។

ខិត្តបណ្ណនោះបានសរសេរទៀតថា “បដិសេធបក្សវៀតណាម ខ្ញុំកញ្ឆះដាច់ថ្លៃរបស់សូវៀត” ។

អ៊ំម្នាក់នៅព្រៃនគរបាននិយាយថា នៅមាត់ជ្រូក ក្រមួនសឡុងអាន ព្រះត្រពាំង ត្រាយិញ តៃនិញ មានចលនាវ៉ាហាវ ការដាយ កាតូលិក និងចលនាកម្ពុជាក្រោមតស៊ូខ្លាំងក្លាណាស់ ។ ចលនានេះ មានមូលដ្ឋាននៅព្រៃ ហើយបានចាប់អាវុធវាយបក្សវៀតណាមរាល់ថ្ងៃ ។ ចលនាកម្ពុជាក្រោមខ្លាំងជាងគេ ។ ចលនានេះរំដោះបានឃុំជាច្រើននៅអានយ៉ាង ក្រមួនស ព្រះត្រពាំង ពលលាវ និងរោងដំរី ។ ទាហានយួនលែងហ៊ានអើតក្បាលទៅមូលដ្ឋានរំដោះនោះហើយ ។

នៅភាគកណ្ដាលវៀតណាម ប្រជាជនជនជាតិភាគតិចមានបាហា, រ៉ាដែ, កាហោ, ចារ៉ាយ, ញួង, ហាលូ, កាឡៃ បានក្រោកឈរឡើងក្ដាប់អាវុធតស៊ូវាយបក្សវៀតណាមជាបន្តបន្ទាប់ ។ នៅខេត្តដាឡាក់, កន្ទុំ, ផ្លេគូ, ដាឡាត់, ក្វាងឌឹក ចលនាបាយ៉ារ៉ែកកាបានវាយទាហានវៀតណាមបានខ្លាំងក្លា ។ ជនជាតិភាគតិចធ្វើ

បាតុកម្ម កុប្បកម្មដណ្ដើមអាវុធបានជាបន្តបន្ទាប់ ។ សព្វថ្ងៃនេះ ជនជាតិភាគតិចបានក្លាយទៅជាម្ចាស់ព្រៃភ្នំនៅវៀតណាមកណ្ដាលទៅហើយ ។

ខែមករា-ឧសភា ឆ្នាំ១៩៧៧ ប្រជាជននៅខេត្តចាប់ផ្ដើមធ្វើបាតុកម្មទាមទារបាយស៊ី និងប្រឆាំងបក្សវៀតណាម ហើយបានស្ទាក់វាយកម្មាភិបាលជាប់មិនដាច់ ។ ការតស៊ូកាន់តែរីកធំឡើងៗ ធ្វើឲ្យបក្សវៀតណាមនៅខេត្តធៀធៀន វិលក្បាលគ្រប់ធាតុ ។ ចំណែកប្រធានឃុំមីថឈ្មោះ តូ ហុងឡុង និងឈ្លប២០នាក់បានចេញចាប់យុវជនក្នុងភូមិឲ្យធ្វើជាទាហាន ។ បន្ទាប់មក ប្រជាជនបានធ្វើបាតុកម្ម និងស្រែកថា បក្សវៀតណាមត្រូវឈប់ចាប់ទាហានយកទៅឈ្លានពានកម្ពុជា ត្រូវប្រគល់កូនចៅមកឲ្យប្រជាជនវិញ ។ ក្រុមបាតុករបានដេញកាប់ឈ្លបឃុំ ។ ក្រុមឈ្លបមួយចំនួន និងមេឃុំត្រូវរត់គេចខ្លួន ។ ចំណែកប្រជាជនពេលមកដល់ភូមិវិញ ក៏បាននាំគ្នាមួយចំនួនធំរត់ចូលក្នុងព្រៃ ដើម្បីបន្តធ្វើការតស៊ូតទៅទៀត ។ បន្ទាប់មក នៅភូមិ វ៉ាន់ទ្រឿង រស់នៅកើតមានការអត់ឃ្លាន ប្រជាជនស៊ីតែដំឡូង ត្រកួនស្ងោ លុងស្ងោ និងស្លឹកឈើព្រៃ ស្លាប់ជាបន្តបន្ទាប់ ។ ប្រជាជនខ្លះបានក្លាយទៅជាចោរលួចចោរប្លន់ ខ្លះបានក្លាយទៅជាអ្នកសុំទាន រកតែកន្ទបវិណ្ឌស៊ើរមិនបាន ។ ប្រជាជនបានជេរបក្សវៀតណាមថា បក្សវៀតណាមស្អីគេនោះ វាគ្មានសមត្ថភាពដោះស្រាយជីវភាពប្រជាជនទេ ។ បក្សវៀតណាមកំពុងតែឱនក្បាលលក់ឯករាជ្យជាតិ លក់ប្រទេសជាតិឲ្យសូវៀត ។ មួយថ្ងៃៗគិតតែពីចាប់យុវជនដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅ បង្ខំឲ្យធ្វើជាទាហានឈ្លានពានកម្ពុជា ។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ តូ ហុងឡុង បានកោះហៅឪពុកម្ដាយរបស់ វ៉ាន់ទ្រឿង ឲ្យទៅជួបនៅសាលាឃុំ ។ តូ ហុងឡុង បានគំរាមកំហែងឲ្យអ្នកទាំងពីរប្រគល់ វ៉ាន់ទ្រឿង ទៅឲ្យរដ្ឋ បើមិនដូច្នេះទេ នឹងត្រូវចាប់ដាក់គុកអស់មួយពូជ ។ ឪពុកម្ដាយ វ៉ាន់ទ្រឿង បានតបវិញថា «យើងមិនឲ្យកូនយើងទៅធ្វើទាហានឈ្លានពានគេទេ ។ ឈ្លានពានគឺចាញ់គេ វាស្អុយឈ្មោះ វាអាសោចកេរ្តិ៍ណាស់ ។ តើពួកឯងធ្វើអីយើង ។ យើងមិនឲ្យកូនយើងទៅពួកឯងដាច់ខាត» ។ ពេលនោះ តូ ហុងឡុង បានឲ្យឈ្លបទៅចាប់ វ៉ាន់ទ្រឿង ទៅសាលាឃុំ ហើយបានយកឪពុកម្ដាយ វ៉ាន់ទ្រឿង ទៅដាក់គុកនៅកន្លែងមួយ ហើយបានយក វ៉ាន់ទ្រឿង ទៅដាក់នៅកន្លែងមួយផ្សេងទៀតជាមួយនឹងយុវជនចំនួន២០នាក់ ។ បន្ទាប់មក បានបញ្ជូន វ៉ាន់ទ្រឿង និងយុវជនទាំងអស់ទៅស្រុកភូមីរួចហើយទៅស្រុកភូថាញ់ទៀត ។

ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៨ ហុងឡុង បានបញ្ជូនយុវជនទាំងអស់ទៅសាលាបច្ចេកទេសយោធាឌីកឡិប ។ វ៉ាន់ទ្រឿង នៅក្នុងអនុសេនាតូចលេខ១ អនុសេនាធំលេខ៤ ។ សាលានេះនៅក្រោមបញ្ជារបស់វរសេនាធំលេខ២៩ ហើយវរសេនាធំលេខ២៩ បានចូលឈ្លានពានកម្ពុជាចំនួនបីលើករួចមកហើយ ។ ការចូលឈ្លានពានក្នុងមួយលើកៗ ទាហានត្រូវគ្រាប់ផ្លាប់ពី៤០០-៥០០នាក់ ។ នៅវរសេនាធំនេះ មានកម្មាភិបាលមួយចំនួនជាអ្នកល្មោភសង្គ្រាម ហើយក៏មានមួយចំនួនទៀតស្អប់សង្គ្រាមឈ្លានពានរបស់បក្សវៀតណាមដែរ ដោយខ្លះរត់ទៅផ្ទះ អ្នកខ្លះបាញ់ដៃជើងខ្លួនឯងឲ្យរបួស ដើម្បីគេចឲ្យផុតពីការចូលមកឈ្លានពានកម្ពុជា ។

នៅសាលាឌីកឡិបនេះ កម្មាភិបាលដែលជាគ្រូបង្ហាត់ខ្លះបានបង្ហើបឲ្យដឹងថា នៅលើឆាកអន្តរជាតិ នយោបាយឈ្លានពានកម្ពុជារបស់បក្សវៀតណាម ត្រូវបរាជ័យយ៉ាងអាម៉ាស់ណាស់ ។ ឯក្នុងប្រទេសបរាជ័យខាងយោធាក៏កាន់តែធ្ងន់ធ្ងរខ្លាំងណាស់ទៀត ។ នៅរដូវប្រាំងឆ្នាំ១៩៧៨-១៩៧៩នេះ បក្សវៀតណាមមានផែនការវាយកម្ពុជាដោយទ្រង់ទ្រាយធំ ។ យើងនឹងប្រើអ៊ីៗទាំងអស់ដែលយើងមាន ដូចជាគ្រាប់ដែលមានផ្សែងពុល ដែលអាចធ្វើឲ្យយើងយកជ័យជម្នះលើកម្ពុជាបាន ។ ព្រោះដូច្នេះ វ៉ាន់ទ្រឿង និងកូនទាហានបានចោទសួរគ្នាថា តើបានទាហានមកពីណា? បើសព្វថ្ងៃនេះ យុវជនវៀតណាមរត់ចូលព្រៃ ហើយប្រដាប់ដោយអាវុធវាយបក្សវៀតណាមយ៉ាងខ្លាំងក្លា ។ តើបានប្រាក់ខែពីណាមកឲ្យទាហាន បើសូវៀតវាជំពាក់គេសិបពាន់លានដុល្លារ ហើយអត់បាយដូចតែវៀតណាមដែរនោះ ។ តើយើងមានរោងចក្រធ្វើកាំភ្លើង យន្តហោះ រថក្រោះ កប៉ាល់ចម្បាំងទេ? តើសូវៀតវាអាចជួយយើងបានច្រើនតទៅមុខទៀតបានទេ? សូវៀតពិតជារត់ចោលបក្សវៀតណាម ដូចចក្រពត្តិអាមេរិករត់ចោលពួកអាធីវគីដែរ ។ តើវៀតណាមមានដូចចក្រពត្តិអាមេរិកហើយឬនៅ ។ ចម្លើយតែមួយម៉ាត់ គឺមានតែមួយភាគរយមិនបានផង ។ កូនទាហានទាំងអស់បានកំណត់ច្បាស់ថា បើបក្សវៀតណាមហ៊ានលនៅរដូវប្រាំង

នេះ វាមុខជាខ្មោច វាមុខតែខ្មុចខ្មី វាមុខតែអត់ដីនៅ ព្រោះប្រជាជនគ្រប់ជនជាតិនៅវៀតណាម បានក្រោកឡើងតស៊ូនឹងបក្សវៀតណាមគ្រប់ទិសទី ដូចជាចលនាបាយ៉ារ៉ាកា ចលនាសាសនា ខ្មែរកម្ពុជាក្រោម សកម្មភាពបក្សសង្គ្រោះជាតិរបស់ ង្វៀង ភាវគី ជាដើម ។ នៅស្រុកឌឹកឡិបនេះ កងទ័ពជនជាតិភាគតិច វាយប្រហារទៅលើទាហានវៀតណាមជាប់មិនដាច់ ។ ប្រធានឃុំ ប្រធានស្រុក កម្មាភិបាលរដ្ឋអំណាច និងយោធាម្នាក់ៗ សុទ្ធតែភ្នែកប្រាក់កាក់ ។ ពួកវាភ័យខ្លាចណាស់ ទៅណាមកណាមានសុទ្ធតែកងការពារពីមុខពីក្រោយ ។ កាល វ៉ាន់ទ្រឿងហាត់នៅឌឹកឡិប វរសេនាធំលេខ២៩ បានចេញទៅកម្ចាត់កងទ័ពជនជាតិដែលបានក្តាប់កំណាត់ផ្លូវឌឹកឡិប បានមេធ្លូត ជាញឹកញាប់ ។ ក្នុងពេលរាតត្បាតម្តងៗ ទាហានវរសេនាធំនេះត្រូវគ្រាប់ងាប់យ៉ាងតិចណាស់ក៏២០-៣០នាក់ដែរ ។

ខែសីហា ឆ្នាំ១៩៨៨ វរសេនីយផ្កាយមួយ ហួប បញ្ជាការវរសេនាធំលេខ២៩ បាននិយាយថា ទឹកដីបក្សវៀតណាមធំណាស់ គឺឥណ្ឌូចិន និងអាស៊ីអាគ្នេយ៍ ។ ជាជំហានដំបូង បក្សវៀតណាមត្រូវវាយយកកម្ពុជាឲ្យបានសិន ព្រោះកម្ពុជាសម្បូរស្រូវអង្ករ និងសម្បត្តិធម្មជាតិ ។ កម្ពុជាជាគន្លឹះសម្រាប់ឈ្លានពានប្រទេសដទៃទៀតនៅអាស៊ីអាគ្នេយ៍ ។ ប្រសិនយកកម្ពុជាបានហើយ ប្រទេសអាស៊ីអាគ្នេយ៍ឯទៀត នឹងធ្លាក់ក្នុងដៃវៀតណាមយ៉ាងស្រួល ។ នៅរដូវប្រាំងឆ្នាំ១៩៧៨-១៩៧៩នេះ ក្នុងការវាយលុកយកកម្ពុជា បក្សវៀតណាមនឹងប្រើយន្តហោះ រថក្រោះ កប៉ាល់ចម្បាំង កាំភ្លើងធំ គ្រាប់រំសេវ ព្រមទាំងគ្រាប់ផ្សែងពុលផង ។ ជាមួយគ្នានេះ កម្មាភិបាលសូវៀតជាច្រើនដែលនៅក្នុងកងទ័ពវៀតណាម នឹងចូលបញ្ជាយន្តហោះ រថក្រោះ កប៉ាល់ចម្បាំង កាំភ្លើងធំ និងកងថ្មើរជើងផ្ទាល់នៅសមរភូមិកម្ពុជា ។ សព្វថ្ងៃនេះ យោធភូមិភាគទី៥ មានសូវៀត១០០នាក់ជាស្រេចទៅហើយ នៅដាណាំ ។

ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៧៨ អនុសេនាធំរបស់ វ៉ាន់ទ្រឿង បានទទួលកូនទាហានថ្មីទៀតចំនួន១០នាក់ដែលទើបតែចាប់បានមកពីខេត្តផាប៊ិញ ។ កូនទាហានថ្មីបាននិយាយថា ភូមិស្រុកខេត្តផាប៊ិញ និងខេត្តដទៃទៀត ត្រូវទឹកឡើងលិចអស់ហើយ ទ្រព្យសម្បត្តិត្រូវវិនាសហិនហោចអស់គ្មានសល់ ។ ប្រជាជនអត់បាយ និងលង់ទឹកស្លាប់អស់រាប់រយរាប់ពាន់នាក់ ហើយថែមទាំងទាហានវៀតណាមបានលួចឆក់ប្លន់ពីមុខពីក្រោយគ្មានសល់អ្វីទេ ។ ឥឡូវបក្សវៀតណាមកំពុងតែចាត់តាំង ផាម វ៉ាន់ដុង ឲ្យដើរសុំទានសកលលោក ដោយលើកពាក្យស្លោកថា ប្រជាជនវៀតណាមរងគ្រោះដោយទឹកជំនន់ខ្លាំងណាស់ ។ លុះដល់បានជំនួយបន្តិចបន្តួចមក ពួកនេះបានយកជំនួយទាំងនេះដាក់ទុកនៅក្នុងឃ្លាំងយោធាសម្រាប់ធ្វើជាស្បៀងឈ្លានពានកម្ពុជាអស់ ។ ជាមួយនេះ បក្សវៀតណាម បានទៅបោកប្រាស់យកកូនប្រជាជនមកធ្វើទាហានឈ្លានពានកម្ពុជាទៀត ដោយបានសន្យាថា នឹងផ្តល់ជំនួយដល់ឪពុកម្តាយ តែតាមការពិតពួកនេះមិនបានផ្តល់ឲ្យអ្វីសោះ ។

ថ្ងៃ១០ ខែកញ្ញា ឆ្នាំ១៩៧៨ វ៉ាន់ទ្រឿង បានចេញពីសាលាហើយបានទៅក្នុងអនុសេនាធំជាងលេខ១៥ វរសេនាធំលេខ២៩ ។ វរសេនាធំលេខ២៩ បានទៅបោះទ័ពនៅភ្នំម៉ាងយ៉ាង ផ្លេគូ ។ កូនទាហាននាំគ្នារត់គ្មានលោះថ្ងៃណាទេ ។ ខ្លះរត់ទៅផ្ទះ ខ្លះរត់ចូលព្រៃរួមតស៊ូប្រឆាំងនឹងបក្សវៀតណាមជាមួយឪពុកម្តាយរបស់ខ្លួន ។ នៅភ្នំម៉ាងយ៉ាង វរសេនីយផ្កាយមួយ ហួប ស្រវឹងស្រាគ្មានដាច់ ហើយបានរករឿងជាមួយកូនទាហាន វាយដំកូនទាហានស្ទើររាល់ថ្ងៃ ។ លុះដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៨ ហួប បានបញ្ជាឲ្យវរសេនាធំលេខ២៩ ចូលវាយលុកកម្ពុជានៅអូរយ៉ាដាវ ខេត្តរតនៈគិរី មុនគេគឺវាយតាមផ្លូវជាតិលេខ១៩ ។ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៨ វរសេនាធំលេខ២៩ បានវាយចូលដល់អូរយ៉ាដាវ ។ គ្រាន់តែអើតក្បាលមកភ្លាម ក៏ត្រូវកងទ័ពកម្ពុជាប្រជាធិបតេយ្យព័ទ្ធវាយកម្ទេចទាំងស្រុងតែម្តង ។ **ឆេង ខ៉េង**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* និង *truthcambodia.com* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យឥន្ទ្រទេវី

ប្រទេសកម្ពុជាឆ្លងកាត់សង្គ្រាមច្រើនឆ្នាំ ជាពិសេសរបបខ្មែរក្រហម ដែលប្រព្រឹត្តអំពើអមនុស្សធម៌ បង្ខំប្រជាជនឲ្យធ្វើការដូចសត្វធាតុ ផ្តល់របបឲ្យមិនគ្រប់គ្រាន់ ពេលឈឺគ្មានថ្នាំសង្កូវព្យាបាល និងបានសម្លាប់ប្រជាជនស្លូតត្រង់អស់ជាងពីរលាននាក់ ។ នេះគឺជារបត់ប្រវត្តិសាស្ត្រដ៏ជូរចត់មួយដែលប្រជាជនកម្ពុជាបានឆ្លងកាត់ពីឆ្នាំ១៩៧៥ - ១៩៧៩ និងបានបន្សល់ទុកនូវស្លាកស្នាមរហូតមកដល់សព្វថ្ងៃ ។ ដើម្បីបញ្ចៀសរឿងរ៉ាវដែលបានកើតឡើងទាំងនេះ ទើបនៅព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវេទិកាថ្នាក់រៀនថ្មីមួយទៀតនៅវិទ្យាល័យឥន្ទ្រទេវី ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយមានសិស្សានុសិស្សចំនួន២០០នាក់ បានចូលរួម ។ ការរៀបចំបង្កើតឲ្យមានវេទិកាថ្នាក់រៀននេះឡើង គឺមានគោលបំណងសំខាន់ ដើម្បីបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ ការជួយជំរុញឲ្យមានការចងចាំ ការការពារកុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងម្តងទៀត និងបណ្តុះឲ្យមានការគិតត្រិះរិះពិចារណាទៅលើប្រវត្តិសាស្ត្រដល់ក្មេងៗជំនាន់ក្រោយ ដែលជាទំពាំងស្នងឫស្សី ដែលបានធ្វើបទបង្ហាញដោយលោក ផេង ពង្សរ៉ាស៊ី នាយកនៃកម្មវិធីការអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

ដើមឡើយ វិទ្យាល័យឥន្ទ្រទេវីត្រូវបានកសាងឡើងនៅឆ្នាំ១៩៦៣ នៅក្នុងសម័យសង្គមរាស្ត្រនិយមដែលដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ ហើយបានសម្ពោធបើកឲ្យសិស្សចូល




លោក ផេង ពង្សរ៉ាស៊ី ប្រធានគម្រោងអប់រំពីពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ - ៧៩ ដល់សិស្សានុសិស្សនៅវិទ្យាល័យឥន្ទ្រទេវី ។

រៀនជាផ្លូវការដោយមានវត្តមានដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ផ្ទាល់ព្រះអង្គ ។ បន្ទាប់ពីមានព្រឹត្តិការណ៍រដ្ឋប្រហារឆ្នាំ១៩៧០ វិទ្យាល័យឥន្ទ្រទេវី ត្រូវបានប្តូរឈ្មោះទៅជាវិទ្យាល័យទួលគោកវិញ ។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ ប្រជាជននៅទីក្រុងភ្នំពេញទាំងអស់ ត្រូវបានខ្មែរក្រហមជម្លៀសឲ្យចេញពីផ្ទះសម្បែងដោយបង្ខំទៅធ្វើស្រែចម្ការដូចប្រជាជននៅតំបន់ផ្សេងៗទៀតដែរ ។ ចំណែកវិទ្យាល័យនេះ ត្រូវបានខ្មែរក្រហមយកធ្វើជាឃ្លាំងសម្រាប់ផ្ទុកអាវុធយុទ្ធភណ្ឌគ្រប់ប្រភេទ ។ លុះដល់ក្រោយពេលខ្មែរក្រហមដួលរលំទៅ វិទ្យាល័យនេះ ត្រូវបានយកធ្វើជាសាលាបច្ចេកទេសហិរញ្ញវត្ថុយោធា នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា រហូតដល់ឆ្នាំ១៩៨៩ ទើបប្រគល់ឲ្យមកក្រសួងអប់រំ យុវជន និងកីឡាវិញ ។ បន្ទាប់មក ក្រសួងអប់រំ យុវជន និងកីឡា ក៏បានប្តូរឈ្មោះវិទ្យាល័យនេះ មកជាវិទ្យាល័យឥន្ទ្រទេវីវិញ ដោយបច្ចុប្បន្ន វិទ្យាល័យឥន្ទ្រទេវីមានសិស្សានុសិស្សកំពុងរៀន ប្រមាណជាង២៨០០នាក់ រីឯគ្រូបង្រៀនមានចំនួន១៣៩នាក់ ដែលក្នុងនោះមានអ្នកគ្រូចំនួន៩៩នាក់ ។ វិទ្យាល័យឥន្ទ្រទេវី មានទីតាំងស្ថិតនៅចន្លោះផ្លូវលេខ៣១៧ និងផ្លូវលេខ៥៩២ ក្នុង សង្កាត់បឹងកក២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅលើផ្ទៃដីសរុប ចំនួន២.៤៣០៣ម៉ែត្រក្រឡា ។ មុននឹងមានវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានដាក់តាំងពាក្យស្លោកនៅវិទ្យាល័យឥន្ទ្រទេវី តាំងពីឆ្នាំ២០១០ ដែលនិយាយពីរបបខ្មែរក្រហម ។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន លោកគ្រូ នាក់ សុទ្ធា នាយកវិទ្យាល័យឥន្ទ្រទេវី បានបង្ហាញនូវចំណាប់អារម្មណ៍ថា ពាក្យស្លោកដែលសរសេរនៅលើហោជាងនៃអគារសិក្សាដែលនិយាយពីរបបខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យចេះអត់ទិន និងអធ្យាស្រ័យគ្នា ។ ពីមុនលោកគ្រូគិតថា មានសិស្សតិចតួចណាស់ដែលអានហើយបានយល់ពីអត្ថន័យ ព្រោះពាក្យស្លោកមានន័យជ្រៅ ។ ដូច្នេះ ដើម្បីឲ្យសិស្សងាយយល់ចំពោះអត្ថន័យរបស់ពាក្យស្លោកនេះ ទាល់តែយើងធ្វើជាវេទិកាថ្នាក់រៀនដូចថ្ងៃនេះ ។


សិស្សវិទ្យាល័យឥន្ទ្រទេវី ឡើងសរសេររឿងរ៉ាវពីរបបខ្មែរក្រហមដែលខ្លួនបានដឹង បង្ហាញទៅដល់មិត្តភក្តិដែលបានចូលរួមនៅក្នុងវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥-៧៩ ។

វេទិកានេះមានសារសំខាន់ខ្លាំងណាស់ដែលអាចពន្យល់ពាក្យស្លោកទាំងអស់នេះឲ្យសិស្សអាចយល់បាន តាមរយៈការធ្វើបទបង្ហាញនៅក្នុងវេទិកាថ្នាក់រៀន ។ លោកគ្រូបានបន្តថា ក្មេងឥឡូវកើតមិនទាន់របបខ្មែរក្រហមទេ ហើយក្មេងភាគច្រើនមិនសូវជឿថាមានរបបខ្មែរក្រហមដែលមានការកាប់សម្លាប់មនុស្សទេ លុះដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមកធ្វើបទបង្ហាញ មានបង្ហាញជារូបថត និងឯកសារ ទើបជំរុញឲ្យក្មេងមានជំនឿកាន់តែខ្លាំងឡើងថាពិតជាមានរបបខ្មែរក្រហមមែន ហើយក្មេងនឹងមានជំនឿកាន់តែខ្លាំងឡើងៗពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ លោកគ្រូបានបន្តទៀតថា នៅពេលប្រឡង ប្រសិនបើមានចេញជាវិញ្ញាសាទាក់ទងរបបខ្មែរក្រហម នោះរឹតតែធ្វើឲ្យសិស្សមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងថែមទៀត ។

អ្នកគ្រូឈ្មោះ ស៊ិន សុដានី ជាគ្រូបង្រៀនផ្នែកប្រវត្តិវិទ្យា បានឲ្យដឹងថា ការបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ពីមុនសាលាបានឲ្យពេលពីរម៉ោងក្នុងមួយសប្តាហ៍ ប៉ុន្តែដល់ពេលបច្ចុប្បន្នសាលាឲ្យតែមួយម៉ោងក្នុងមួយសប្តាហ៍ ហេតុនេះអ្នកគ្រូមិនមានពេលគ្រប់គ្រាន់ក្នុងការធ្វើបទបង្ហាញ ក៏ដូចជាពិភាក្សាពីរឿងរ៉ាវនៅក្នុងមេរៀនឲ្យបានស៊ីជម្រៅនៅក្នុងថ្នាក់ ។ អ្នកគ្រូបានបន្តថា សិស្សនាពេលបច្ចុប្បន្ននេះ មានការយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យច្រើនជាងមុន ព្រោះកាលពីបង្រៀនដំបូង ពេលដែលអ្នកគ្រូបង្រៀនសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ សិស្សហាក់បីដូចជាស្រពិចស្រពិល ហើយបានគិតថា ការបង្រៀននេះមានលក្ខណៈភូតកុហក ។ បច្ចុប្បន្ន ពេលអ្នកគ្រូបង្រៀន គឺមានសិស្សចូលរៀនពេញៗថ្នាក់ ។ អ្នកគ្រូបានបន្តថា នៅក្នុងថ្នាក់រៀនអ្នកគ្រូតែងមានជាសំណួរសួរទៅកាន់សិស្សជានិច្ច ហេតុនេះហើយបានជាសិស្សមានការចាប់អារម្មណ៍ក្នុងការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ ចំពោះវិធីសាស្ត្រក្នុងការបង្រៀនសិស្ស អ្នកគ្រូបានប្រាប់ឲ្យដឹងទៀតថា អ្នកគ្រូមានឯកសារជាមេរៀនដែលអ្នកគ្រូបានសង្ខេបចេញពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងរូបថត ដើម្បីបង្ហាញទៅកាន់សិស្ស រួមផ្សំនឹងមានការចាក់ផ្សាយពីគ្រប់ស្ថានីយ៍ទូរទស្សន៍ក្នុងស្រុកពីរបបនេះ ទើបសិស្សមានការជឿជាក់ថា ពិតជាមានរបបប្រល័យពូជសាសន៍នៅកម្ពុជាពិនមែន ។

ឈឹម សុវណ្ណ ជាសិស្សរៀននៅថ្នាក់ទី១២D១ បានឲ្យដឹងថា ខ្លួនធ្លាប់បានដឹងឮពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម តែមិនច្បាស់លាស់ទេ ហើយការដឹងឮនេះ គឺបានដឹង-តាមរយៈឪពុកម្តាយនិយាយប្រាប់ និងដឹងតាមរយៈបណ្តាញសង្គមហ្វេសប៊ុក ។ របបខ្មែរក្រហមជារបបមួយដែលប្រល័យពូជសាសន៍ជាតិឯង គ្មានការយោគយល់ និងប្រើអំណាចផ្តាច់ការ ។ សុវណ្ណ យល់ឃើញថា ការបង្កើតឲ្យមានជាវេទិកាបែបនេះ គឺមានសារសំខាន់ណាស់ ប៉ុន្តែ គួរមានពេលវេលាឲ្យបានវែងជាងនេះរឹតតែប្រសើរ ។ ក្រោយពេលសុវណ្ណ បានចូលរួមសិក្សាក្នុងវេទិកានេះ ប្អូនមានការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមបានច្រើនជាងមុន ជាពិសេសគោលការចំនួនប្រាំបីចំណុចរបស់ខ្មែរក្រហម ដូចជាការលុបបំបាត់ផ្សារ ការលុបបំបាត់រូបិយបណ្ណ ការជម្លៀសប្រជាជនដោយបង្ខំ ការផ្សឹកព្រះសង្ឃ ការសម្លាប់មន្ត្រីរាជការក្នុងរបប លន់ នល់ ការបង្កើតសហករណ៍ថ្នាក់ខ្ពស់ ការបណ្តេញជនជាតិវៀតណាមចេញពីប្រទេស និងការបញ្ជូនកងទ័ពទៅព្រំដែន ។ សុវណ្ណ បានបន្តថា គាត់ចង់ឲ្យមានជាវេទិការបែបនេះទៀត និងមានពេលវេលាច្រើនជាងនេះ ដើម្បីឲ្យគាត់ និងសិស្សានុសិស្សផ្សេងទៀត បានទទួលការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានកាន់តែច្រើន ។

ប៉េង រ៉ូហ្សា ជាសិស្សរៀននៅថ្នាក់ទី១២ D១ បានប្រាប់ឲ្យដឹងថា គាត់បានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈឪពុកម្តាយ និងជីដូនជីតានិយាយប្រាប់ ។ រ៉ូហ្សា បានបន្តថា របបខ្មែរក្រហមជារបបមួយដែលប្រល័យពូជសាសន៍ ផ្តាច់ការ ហើយគ្មានការយោគយល់ដល់អ្នកណាឡើយ ។ ដើម្បីការពារកុំឲ្យរបបប្រល័យពូជសាសន៍ខ្មែរក្រហមនេះ វិលត្រឡប់មកវិញ ទាល់តែប្រជាជនត្រូវរួមសាមគ្គីគ្នាជាធ្លុងមួយ មិនត្រូវប្រើអំពើហិង្សា គឺត្រូវយកចំណេះដឹងដែលយើងបានរៀនសូត្រមកពិភាក្សាគ្នា ។ រ៉ូហ្សា បានបន្ថែមថា ចំពោះវេទិកាថ្នាក់រៀនដែលបានរៀបចំនៅព្រឹកនេះ ពិតជាធ្វើឲ្យគាត់ទទួលការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនជាងកាលពីពេលដែលគាត់មិនទាន់បានចូលរួមក្នុងវេទិកាថ្នាក់រៀននេះ ។ **ឆេង ខ៉េង**

# វគ្គបណ្តុះបណ្តាលស្តីពី ការចងក្រង ស្រាវជ្រាវ ប្រវត្តិសាស្ត្រភូមិ សម្រាប់គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរនៅវិចិត្រសាលសិល្បៈ សហសម័យវិទ្យាស្ថានស្ទឹកវីក

នាព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ គម្រោងអប់រំពីអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការចងក្រង ស្រាវជ្រាវ ប្រវត្តិសាស្ត្រភូមិ" សម្រាប់គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរ នឹងប្រព្រឹត្តទៅរយៈពេល បីថ្ងៃ ចាប់ពីថ្ងៃទី២១-២៣ ខែកុម្ភៈ ឆ្នាំ២០១៨ នៅវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្ទឹកវីត ដែលមានទីតាំងស្ថិតនៅក្នុងវិទ្យាស្ថានជាតិអប់រំ ។ នៅក្នុងកម្មវិធីនេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា បានអញ្ជើញលោកគ្រូ-អ្នកគ្រូដែលបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា និងអក្សរសាស្ត្រខ្មែរមកពីខេត្តកណ្តាល ខេត្តតាកែវ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង និងខេត្តកំពង់ឆ្នាំងចំនួនម្ភៃនាក់ រួមជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមាណជាងសាមសិបនាក់ចូលរួម ។

ការបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលនេះឡើង ក្នុងគោលបំណង៖

១) បង្កើតជាគណៈកម្មការស្វែងរកការពិត និងកាផ្សះផ្សា



លោក ផេង ពង្សរ៉ាស៊ី ប្រធានគម្រោងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានឡើងបង្ហាញពីវិធីសាស្ត្រសរសេរ និងប្រមូលព័ត៌មានដើម្បីសរសេរប្រវត្តិសាស្ត្រភូមិទៅដល់លោកគ្រូអ្នកគ្រូ និងសិក្ខាកាមដែលមកចូលរួម ។

មួយនៅកម្ពុជា

២) បង្ហាញពីយន្តការយុត្តិធម៌អន្តរកាលផ្សេងៗទៀត

៣) បង្កើតការចងចាំចេញពីមូលដ្ឋាន

៤) បណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់មូលដ្ឋានឲ្យក្លាយជា "អ្នកប្រវត្តិសាស្ត្រភូមិតាមរយៈការបណ្តុះបណ្តាល" និងបន្តចូលរួមក្នុងការអប់រំ ដោយផ្តល់ឱកាសឲ្យគ្រូបង្រៀនទាំងអស់សរសេរប្រវត្តិសាស្ត្រចេញពីសហគមន៍របស់ខ្លួន និង

៥) ពង្រឹងសមត្ថភាពគ្រូបង្រៀនតាមមូលដ្ឋានឲ្យក្លាយទៅជាគ្រូដែលចេះជំនាញស្រាវជ្រាវ ដែលនឹងអាចមានលទ្ធភាពក្នុងការផ្ទេរចំណេះដឹងនេះទៅកាន់សិស្សរបស់ខ្លួនបន្តទៀត ។

មនុស្សម្នាក់ មានប្រវត្តិសាស្ត្រមួយ ហើយប្រវត្តិសាស្ត្រនេះ នៅមិនទាន់បានកត់ត្រាគ្រប់ជ្រុងជ្រោយនៅឡើយទេ ។ តើមានរឿងរ៉ាវអ្វីខ្លះកើតឡើងនៅក្នុងមូលដ្ឋាន? ហើយមានមនុស្សប៉ុន្មាននាក់បានដឹងពីរឿងរ៉ាវទាំងនោះ? នេះគឺជាមូលហេតុចម្បងដែលវគ្គបណ្តុះបណ្តាលត្រូវស្វែងយល់ និងចងចាំពីប្រវត្តិរឿងរ៉ាវពីអតីតកាល ព្រមទាំងចែករំលែកដល់ក្មេងៗជំនាន់ក្រោយបន្តទៀតក្នុងន័យថែរក្សាប្រវត្តិសាស្ត្រខ្លួនឯង ។ លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងជាអ្នកដឹកនាំវគ្គបណ្តុះបណ្តាល បានធ្វើបទបង្ហាញពីសារសំខាន់ក្នុងការស្រាវជ្រាវប្រវត្តិសាស្ត្រនៅក្នុងសហគមន៍ថា ការសរសេរប្រវត្តិសាស្ត្រភូមិ គឺជាគម្រោងដែលនឹងត្រូវអនុវត្តក្នុងរយៈពេលប្រាំឆ្នាំ គិតចាប់ពីឆ្នាំ២០១៨ តទៅនៅក្នុងខេត្តក្រុងទូទាំងប្រទេស ។ គ្រូបង្រៀនដែលត្រូវទទួលបន្ទុកសរសេរប្រវត្តិភូមិ ត្រូវជ្រើសរើសចេញពីបញ្ជីឈ្មោះគ្រូបង្គោលថ្នាក់ខេត្តដែលធ្លាប់បានទទួលការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើចំណាប់ចំណូលចិត្ត និងការស្ម័គ្រចិត្តរបស់លោកគ្រូ-អ្នកគ្រូ ក្នុងការសរសេរប្រវត្តិសាស្ត្រខ្លួនឯង ។ ចំពោះលទ្ធផលដែលបានមកពីការសរសេរទាំងនេះ នឹងត្រូវធ្វើការបោះពុម្ព រួចប្រគល់ទៅឲ្យលោកគ្រូ-អ្នកគ្រូវិញ ដើម្បីធ្វើជាសម្ភារឧបទេសប្រើប្រាស់ផ្ទាល់ខ្លួន និងបង្រៀនសិស្សានុសិស្សឲ្យស្វែងយល់ពីសាច់រឿងពីអតីតកាលក្នុងភូមិកំណើតរបស់ខ្លួន ។

លោក ផេង ពង្សរ៉ាស៊ី បានបន្តថា បន្ទាប់ពីមានការជ្រើសរើសគ្រូបង្រៀនឲ្យចូលរួមក្នុងដំណើរការនៃការសរសេរប្រវត្តិភូមិមក វគ្គបណ្តុះបណ្តាលរយៈពេលខ្លីមួយ នឹងត្រូវរៀបចំធ្វើឡើងសម្រាប់គ្រូទាំងអស់ ដើម្បីផ្តល់ចំណេះដឹង និងជំនាញពីវិធីសាស្ត្រក្នុងការធ្វើការស្រាវជ្រាវ ។ កិច្ចការនេះ គឺជាបន្ទុករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនឲ្យមានជំនាញស្រាវជ្រាវដូចជា វិធីសាស្ត្រស្រាវជ្រាវ បង្កើតកម្រងសំណួរស្រាវជ្រាវ វិធីសាស្ត្រធ្វើបទសម្ភាស ដំណើរការនៃការសរសេរ និងចំណេះដឹងផ្សេងៗទៀត ដែលនឹងអាចនាំលោកគ្រូ-អ្នកគ្រូទៅកាន់គោលដៅ និងទទួលបានលទ្ធផលល្អ ។ ចំពោះកិច្ចការទាំងនេះ នឹងមិនអនុញ្ញាតិឲ្យធ្វើកិច្ចការស្រាវជ្រាវ ឬធ្វើបទសម្ភាសនៅក្នុងម៉ោងបង្រៀនសិស្សនៅក្នុងសាលាចំណេះទូទៅឡើយ ។ ប៉ុន្តែគ្រូត្រូវបានលើកទឹកចិត្តឲ្យធ្វើការងារនេះ នៅក្នុងពេលវិស្សមកាលរយៈពេលខ្លី (នៅខែមេសា) និងវិស្សមកាលរយៈពេលវែង (ចាប់ពីខែសីហាដល់ខែតុលា) នៃឆ្នាំសិក្សានីមួយៗ ។ គ្រូបង្រៀនដែលជាអ្នកស្រាវជ្រាវ ត្រូវកំណត់ម៉ោងពេលសម្រាប់ធ្វើការស្រាវជ្រាវ និងការសរសេរសំណេររបស់ខ្លួនឲ្យបានច្បាស់លាស់ ដោយយោងតាមរយៈពេលនៃវិស្សមកាលនីមួយៗ ។

បន្ទាប់ពីការធ្វើបទបង្ហាញរបស់លោក ផេង ពង្សរ៉ាស៊ី មក លោកគ្រូ-អ្នកគ្រូ បានសួរសំណួរទាក់ទងទៅនឹងប្រធានបទដែលគាត់ត្រូវចុះធ្វើការស្រាវជ្រាវនៅតាមភូមិរៀងៗខ្លួន ។ ដើម្បីឲ្យកិច្ចការចុះសិក្សាស្រាវជ្រាវ និងការសរសេរអត្ថបទប្រវត្តិភូមិបានចំគោលដៅដែលមជ្ឈមណ្ឌលឯកសារកម្ពុជាចង់បាន លោកគ្រូ-អ្នកគ្រូ បានបង្កើតជាប្រធានបទម្នាក់មួយប្រធានបទៗ ដែលប្រធានបទទាំងនោះរួមមាន ៖ ប្រវត្តិសាស្ត្ររបស់សាលាទេពប្រណម្យ, ភូមិរបស់យើង គឺភូមិព្រែកអំបិល នៅក្នុងខេត្តតាកែវ, ពុទ្ធបដិមាត្រូវបានខ្មែរក្រហមវាយកម្ទេចយកទៅចាក់ក្រាលធ្វើស្ពាន, ភូមិស្វាយឃ្លាំង, ភូមិប្រធាតុក្នុងសម័យខ្មែរក្រហម, រណ្តៅសាកសពនៅភូមិចារ ក្នុងខេត្តស្វាយរៀង, ទំនប់អត់បាយនៅភូមិរបស់ខ្ញុំ ទំនប់កុមារ, ការសម្លាប់ក្នុងលក្ខណៈទ្រង់ទ្រាយធំ, ការហាមឃាត់គោរពប្រណិប័តន៍សាសនាជាដើម ។

ក្នុងឱកាសចូលរួមក្នុងសិក្ខាសាលានេះ លោកគ្រូ-អ្នកគ្រូ

បានបង្ហាញពីចំណាប់អារម្មណ៍ដូចខាងក្រោម ៖

◆ អ្នកគ្រូ ហេន ស្រីនិត គ្រូបង្រៀនផ្នែកអក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យក្រូចឆ្មារ បានបង្ហាញពីចំណាប់អារម្មណ៍របស់គាត់ថា គាត់មានការចាប់អារម្មណ៍ខ្លាំងណាស់នៅពេលដែលគាត់បានចូលរួមវគ្គបណ្តុះបណ្តាល «ការចងក្រង ស្រាវជ្រាវ ប្រវត្តិសាស្ត្រភូមិ» ។ ការណ៍ដែលគាត់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលកិច្ចការស្រាវជ្រាវនេះ គាត់នឹងទទួលបាននូវបទពិសោធថ្មីៗ ក៏ដូចជាវិធីសាស្ត្រក្នុងការស្រាវជ្រាវ ដែលកាលពីមុនគាត់ធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗដែរ ប៉ុន្តែមិនសូវចាប់អារម្មណ៍ខ្លាំងដូចពេលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល នៅពេលនេះទេ ។ អ្នកគ្រូបានបន្តថា វគ្គបណ្តុះបណ្តាលនេះ ពិតជាបានផ្តល់ផលប្រយោជន៍ច្រើនដល់ការបង្រៀនរបស់គាត់ ។ គាត់នឹងធ្វើការផ្សព្វផ្សាយពីប្រវត្តិភូមិដល់សិស្សានុសិស្ស និងសហគមន៍ដើម្បីបង្កើនចំណេះដឹងដែលមានស្រាប់ និងពង្រឹងសមត្ថភាពបន្ថែម ។ មិនត្រឹមតែប៉ុណ្ណោះ គាត់នឹងបានទទួលចំណេះដឹងពីវិធីសាស្ត្រការស្រាវជ្រាវប្រវត្តិភូមិបានមួយកម្រិតថែមទៀត ។

◆ លោកគ្រូ សម វិចិត្រ ជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យានៃវិទ្យាល័យ ហ៊ុន សែន ស្អាង បានឲ្យដឹងថា ការចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ នឹងធ្វើឲ្យសិក្ខាកាមទាំងអស់ ទទួលបាននូវបទពិសោធថ្មីៗ ក្នុងការសរសេរប្រវត្តិសាស្ត្រភូមិរបស់ខ្លួនផ្ទាល់ទុកជាឯកសារ ។ សិក្ខាកាមទាំងអស់ អាចចែករំលែកនូវបទពិសោធឲ្យគ្នាទៅវិញទៅមក និងមានការចងចាំអំពីប្រវត្តិសាស្ត្រភូមិរបស់ខ្លួនបានយូរអង្វែង ។ លោកគ្រូបានបន្តថា ការស្រាវជ្រាវប្រវត្តិសាស្ត្រភូមិ ផ្តល់ប្រយោជន៍ច្រើនដល់គាត់ដូចជា ធ្វើជាឯកសារយោងនៅក្នុងការបង្រៀន ដែលជាប់ពាក់ព័ន្ធកម្មវិធីសិក្សារបស់ក្រសួង ហើយគាត់អាចយកបទពិសោធដែលគាត់ទទួលបាន ទៅធ្វើបទបង្ហាញដល់សិស្ស ដើម្បីឲ្យសិស្សបានយល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រភូមិរបស់ខ្លួន ។

◆ លោកគ្រូប្រវត្តិវិទ្យា មកពីវិទ្យាល័យ ហ៊ុន សែន កំពង់កន្ទួត ឈ្មោះ ឃឹម ស្រស់ បានប្រាប់ឲ្យដឹងថា វគ្គបណ្តុះបណ្តាលនេះជាជំនាញថ្មីមួយសម្រាប់គាត់ ។ វគ្គបណ្តុះបណ្តាលនេះ ពិតជាមានសារសំខាន់ណាស់ ព្រោះផ្តល់ឱកាសឲ្យគាត់បានចុះធ្វើការសិក្សាស្រាវជ្រាវ ពីទីតាំងមួយជាក់លាក់ ។ លោកគ្រូបានបន្ថែមថា ការស្រាវជ្រាវប្រវត្តិសាស្ត្រភូមិ ផ្តល់ផលប្រយោជន៍ច្រើនសម្រាប់ការបង្រៀនរបស់គាត់ដូចជា ផ្តល់ចំណេះដឹងដល់សិស្សឲ្យបានដឹងពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងតំបន់នោះ និងទុកជាឯកសារសម្រាប់ឲ្យអ្នកសិក្សាផ្សេងៗទៀត បានស្វែងយល់ពីប្រវត្តិភូមិរបស់ខ្លួន ។

◆ ចំណែកអ្នកគ្រូ ប្រាសាទ រស្មីពន្លឺ ជាគ្រូបង្រៀនមុខវិជ្ជាប្រវត្តិ និងភូមិវិទ្យា មកពីវិទ្យាល័យ ហ៊ុន សែន តាខ្មៅ និងអ្នកគ្រូ ហុក ដានីន បង្រៀនមុខវិជ្ជាភូមិ និងប្រវត្តិវិទ្យា មកពីវិទ្យាល័យជ័យវរ្ម័នទី៧ បានឲ្យដឹងព្រមគ្នាថា នៅពេលដែលគាត់ទាំងពីរបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ គាត់មានអារម្មណ៍ប្លែក ព្រោះជាបទពិសោធថ្មីសម្រាប់គាត់ ហើយគាត់ក៏មានការលំបាកក្នុងការស្វែងយល់ដែរ ។ ប៉ុន្តែអ្នកគ្រូបានបន្ថែមថា វគ្គ បណ្តុះបណ្តាលនេះបានផ្តល់ផលប្រយោជន៍ច្រើនដល់គាត់ក្នុងការអភិវឌ្ឍជំនាញស្រាវជ្រាវ និងការសរសេរប្រវត្តិភូមិ ហើយថែមទាំងបានពង្រឹងបន្ថែមលើចំណេះដឹងមូលដ្ឋានដែលធ្លាប់បានទទួលពីមុនមក និងអាចចងក្រងឯកសារស្រាវជ្រាវជាសម្ភារឧបទេសជំនួយដល់ការបង្រៀនសិស្សនៅក្នុងថ្នាក់រៀន ។

បន្ទាប់ពីចប់វគ្គបណ្តុះបណ្តាលស្តីពី «ការចងក្រង ស្រាវជ្រាវប្រវត្តិសាស្ត្រភូមិ» រយៈពេលបីថ្ងៃនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងធ្វើការទាក់ទងលោកគ្រូ-អ្នកគ្រូ ដើម្បីសួរព័ត៌មានពីគម្រោងសរសេររបស់គាត់រួចហើយមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងអញ្ជើញលោកគ្រូ-អ្នកគ្រូទាំងអស់មកមជ្ឈមណ្ឌលឯកសារកម្ពុជានៅភ្នំពេញម្តងទៀត ដើម្បីពិភាក្សាទៅលើប្រធានបទរបស់គាត់ម្នាក់ៗ ។ បន្ទាប់មកទៀត មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចុះទៅទីតាំងដែលលោកគ្រូ-អ្នកគ្រូរស់នៅផ្ទាល់ដើម្បីពិនិត្យលើគម្រោងស្រាវជ្រាវរបស់គាត់ ។ ជាចុងក្រោយ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងធ្វើការប្រមូលលទ្ធផលដែលលោកគ្រូ-អ្នកគ្រូបានសរសេរមកកែសម្រួលឃ្លាឃ្លោ និងអក្ខរាវិរុទ្ធ ព្រមទាំងបកប្រែអត្ថបទទាំងអស់ទៅជាភាសាអង់គ្លេស រួចធ្វើការបោះពុម្ពផ្សាយជាភាសាខ្មែរ និងភាសាអង់គ្លេស ។ **ឆេង ឡេង និង មីន សាណាស់**

# អតីតកងទ័ពជើងទឹកខ្មែរក្រហមបានរំឭកពីបទពិសោធ នៅកោះតាង កោះប៉ូឡូវ៉ៃ និងកោះក្រចកសេះ

ឌូ អ៊ុន ភេទប្រុស អាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅខេត្តតាកែវបានរៀបរាប់ឲ្យដឹងថា កាលពីក្មេងគាត់រៀនបានត្រឹមថ្នាក់ទី៩ចាស់ នៅសាលាបឋមសិក្សាអង្គរអណ្ដើក ។ បន្ទាប់ពីមានរដ្ឋប្រហារនៅឆ្នាំ១៩៧០ គ្រូបង្រៀននៅសាលាបឋមសិក្សាអង្គរអណ្ដើកទាំងអស់បានរត់ភៀសខ្លួនទៅទីក្រុងភ្នំពេញ ហើយ អ៊ុន ក៏បានឈប់រៀន មករស់នៅជាមួយឪពុកម្ដាយជួយធ្វើស្រែ ឃ្វាលគោ និងក្របីជាដើម ។




នៅចុងឆ្នាំ១៩៧២ មានយុវជនជាច្រើនបានស្ម័គ្រចិត្តចូលធ្វើជាកងឈ្លបភូមិ និងឃុំរបស់ខ្មែរក្រហម ដោយគិតចូលដើម្បីបម្រើជាតិ ។ អ៊ុន ក៏បានស្ម័គ្រចិត្តធ្វើកងឈ្លបដូចជាយុវជនផ្សេងៗទៀតដែរ ។ ដំបូងឡើយ អ៊ុន បម្រើជាកងឈ្លបនៅឃុំតាយ៉ាប ដែលមានទីស្នាក់ការនៅភូមិដំឡៀខ្ពស់ ។ អ៊ុន ត្រូវបានចាត់តាំងឲ្យដើរមើល និងការពារសុវត្ថិភាពនៅក្នុងភូមិឃុំ ហ្វឹកហាត់យុទ្ធសាស្ត្រកងទ័ព និងទទួលការអប់រំបំពាក់បំប៉នផ្នែកនយោបាយពីអង្គការខ្មែរក្រហម ដែលកាលនោះឈ្មោះ ហឿន ជាប្រធានឃុំតាយ៉ាប ។

បន្ទាប់មកខ្មែរក្រហមបានបញ្ជូន អ៊ុន ឲ្យចូលក្នុងអង្គភាពកងទ័ពវិញ គឺកងវរសេនាតូចលេខ១០៣ តំបន់៣៣ ដែលត្រូវឈរជើងនៅព្រៃល្មាត ខាងជើងផ្លូវជាតិលេខ៤ ។ កឿន ជាប្រធានកងវរសេនាតូចលេខ ១០៣ ប៉ុន្តែក្រោយមក កឿន ក៏បានស្លាប់ ហើយ ហម បានឡើងជាប្រធានជំនួស ស៊ឹម ចំណែកសំណាង ជាអនុប្រធាន ។ នៅតំបន់៣៣មានកងវរសេនាតូចចំនួន៤ គឺកងវរសេនាតូចលេខ១០២, ១០៣, ១០៤ និង ១០៥ ។

នៅឆ្នាំ១៩៧៤ កងវរសេនាតូចលេខ១០២ និង១០៣ ត្រូវបានបញ្ចូលទៅក្នុងកងពលទី៣របស់ភូមិភាគនិរតី និងត្រូវទៅប្រចាំការនៅលង្វែក ។ កងវរសេនាតូចលេខ១០៣ ត្រូវបានប្ដូរទៅជាកងវរសេនាតូច៤១០ ចំណុះឲ្យកងវរសេនាធំលេខ១៦ ។ ប្រធានវរសេនាតូចលេខ៤១០ គឺ ហម និង ស៊ឹម ដដែល ។ រីឯកងវរសេនាធំលេខ១៦ មានឈ្មោះ មៀច ជាប្រធាន ។ អ៊ុន បានត្រូវរបួសចំជើង និងខ្នង នៅពេលប្រយុទ្ធក្នុងសមរភូមិ និងបានចូលសម្រាកពេទ្យអស់រយៈពេលជិត២ខែ ។

នៅចុងឆ្នាំ១៩៧៤ និងដើមឆ្នាំ១៩៧៥ កងពលរបស់ អ៊ុន បានផ្លាស់មកប្រតិបត្តិការនៅតាមផ្លូវជាតិលេខ៤ នៅម្ដុំមហាសាំង (ទំនប់ព្រែកហៅ) ។ ចំណែកកងទ័ពមួយចំនួនបានបន្តមកឈរជើងនៅបែកចាន ដើម្បីវាយប្រយុទ្ធជាមួយទាហាន លន់ នល់ និងអាមេរិក ។ កងពលរបស់ អ៊ុន មិនបានចូលវាយដល់ទីក្រុងភ្នំពេញទេ គឺចូលត្រឹមបែកចានតែប៉ុណ្ណោះ ។

ក្រោយពីរំដោះបានទីក្រុងភ្នំពេញភ្លាម ខ្មែរក្រហមតម្រូវឲ្យកងពលទី៣របស់ អ៊ុន ទៅប្រចាំការនៅកំពង់សោម ។ ពោលគឺថ្ងៃទី ១៩ ខែមេសា ឆ្នាំ១៩៧៥ កងពលទី៣ បានចេញទៅកំពង់

សោម ។ ថ្ងៃទី២០ ខែ និងឆ្នាំដដែល កងពលទី៣ បានទៅដល់រាម ។ លុះដល់រាម កងពលទី៣ ត្រូវបានប្តូរឈ្មោះទៅជាកងពល១៦៤ ដែលជាកងពលរបស់មជ្ឈិម ។ ប្រធាន និងអនុប្រធានកងពល១៦៤ ឈ្មោះ មុត និង ឌឹម ។ ប៉ុន្តែកងវរសេនាតូច៤១០មិនបានប្តូរឡើយ ហើយចំណែកឯប្រធាន និងអនុប្រធានក៏មិនមានការផ្លាស់ប្តូរដែរ ។

បន្ទាប់ពីនៅរាមបាន២ថ្ងៃគឺថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ កងវរសេនាតូចលេខ៤១០ ដែលមានកងទ័ពប្រមាណជា៣០០ ទៅ៤០០នាក់ បានធ្វើដំណើរឆ្ពោះទៅកោះតាង និងកោះប៉ូឡូវៃ ។ អ៊ុន បានឈរជើងនៅកោះតាង ។ នៅកោះតាងនេះមានកងអនុសេនាធំចំនួន២ គឺគ៨ និងគ១០ ដែលមានកងទ័ពសរុបប្រហែល ២០០នាក់ ។ អ៊ុនស្ថិតនៅក្នុងកងអនុសេនាធំគ៨ ដែលមានឈ្មោះ ម៉ែន និង ហួត ជាប្រធាន និងអនុប្រធានកងអនុសេនាធំគ៨ ។ ម៉ន ជាប្រធានកងអនុសេនាធំគ១០ ហើយ ហួន ជាអនុប្រធាន ។ នៅកោះតាង អ៊ុន គឺជាប្រធានក្រុមដែលគ្រប់គ្រងកងទ័ពចំនួន១២ នាក់ ។

ថ្ងៃទី២៤ ខែមេសានិងឆ្នាំដដែល អ៊ុន និងកងទ័ពជាង១០០ នាក់ទៀត ត្រូវបញ្ជូនឲ្យទៅកោះក្រចកសេះ ឬកោះប៉ូឡូប៉ង់សង់ ។ ការធ្វើដំណើរទៅកោះក្រចកសេះនេះ គឺត្រូវជិះទូកម៉ាស៊ីន១២០ សេះ ចំនួនជិត១០គ្រឿង ក្នុងទូកមួយគ្រឿងមានកងទ័ពប្រមាណ ជិត២០នាក់ ។ នៅកោះក្រចកសេះមានប្រជាជនរស់នៅច្រើន និងសម្បូរទៅដោយផ្ទះថ្ម ។ ប្រជាជននៅទីនោះគឺជាប្រជាជនវៀតណាម និងខ្មែរកម្ពុជាក្រោម ដែលមានអ្នកខ្លះចេះភាសាខ្មែរ ។ លើសពីនេះទៀតក៏មានទាហានធីវគី (វៀតណាមខាងត្បូង) នៅកោះក្រចកសេះនេះដែរ ។ ខណៈពេលដែលទាហានវៀតណាមខាងត្បូងបានលើកទង់ជ័យសរនោះ កងទ័ពខ្មែរក្រហមបានចូលទៅដល់កោះក្រចកសេះភ្លាមៗដែរ ។ ប្រជាជនដែលរស់នៅលើកោះក្រចកសេះមានភាពរាក់ទាក់ និងបានដាំបាយឲ្យ អ៊ុន និងកងទ័ពខ្មែរក្រហមផ្សេងទៀតបរិភោគ ។ មេបញ្ជាការខ្មែរក្រហមប្រចាំនៅកោះក្រចកសេះរួមមាន សារឿន, ចាយ, ទង, ម៉ែន និង ហួត ។ កងទ័ពខ្មែរក្រហម បានដើរប្រាប់ប្រជាជន និងទាហានធៀវគី ដែលរស់នៅកោះក្រចកសេះ ឲ្យរៀបចំខ្លួន និងអីវ៉ាន់ផ្សេងៗដើម្បីចាក



យោធាខ្មែរក្រហមនៅសមរភូមិ

ចេញ ព្រោះកងទ័ពខ្មែរក្រហមត្រូវកាន់កាប់កោះនេះ ។ បន្ទាប់ពីឈរជើងនៅកោះក្រចកសេះបានចំនួន២ថ្ងៃ អ៊ុន និងកងទ័ពប្រមាណ ២០នាក់ទៀត ត្រូវទទួលបញ្ជាឲ្យត្រឡប់មកកោះតាងវិញ ។ ចំណែកកងវរសេនាតូចលេខ៤៧០របស់ តាចាយ ដែលបានបញ្ជូនកងទ័ពមកបន្ថែមរហូតដល់ជាង៣០០នាក់បានបន្តឈរជើងនៅកោះក្រចកសេះទៀត ។

អ៊ុន និងកងទ័ព២០នាក់ទៀត មិនបានចូលមកកោះតាងនោះភ្លាមទេ ពោលគឺត្រូវចូលទៅស្នាក់នៅកោះប៉ូឡូវៃមួយយប់សិន ពីព្រោះនៅកោះតាង កំពុងតែមានការវាយប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនឹងទាហានអាមេរិក ។ នៅខណៈពេលប្រយុទ្ធនោះ កងទ័ពអាមេរិកបានប្រើយន្តហោះកន្ទុំរុយជាច្រើនគ្រឿង បោកគ្រាប់បែកផ្សេងជាច្រើនគ្រាប់ និងកាំភ្លើងទំនើបៗផងនោះ កងទ័ពខ្មែរក្រហមអាចទប់ទល់បានតែរយៈប៉ុន្មានម៉ោង ក៏បាននាំគ្នារត់ចូលព្រៃនិងឡើងលើភ្នំអស់ ។ នៅខណៈពេលកំពុងប្រយុទ្ធគ្នានៅលើកោះតាងនោះ ទាហានអាមេរិកក៏បានទម្លាក់គ្រាប់បែកនៅកំពង់សោម រាម និងរោងចក្រប្រេងកាត ។ ការវាយប្រយុទ្ធគ្នានៅកោះតាងបានចាប់ផ្ដើមតាំងពីពេលព្រឹកព្រលឹម ហើយបានបញ្ចប់វិញនៅម៉ោងប្រមាណ៩យប់ ។

បន្ទាប់ពីបញ្ចប់ការប្រយុទ្ធគ្នា អ៊ុន និងកងទ័ពខ្មែរក្រហមផ្សេងទៀត ក៏បានចូលទៅដល់កោះតាងនិងជួយប្រមែរប្រមូលសាកសពកងទ័ពខ្មែរក្រហម និងទាហានអាមេរិកយកទៅកប់ ។ សរុបកងទ័ពខ្មែរក្រហមបានស្លាប់ចំនួន៧នាក់ និងបាត់ខ្លួន៣នាក់ ។ ចំណែកទាហានអាមេរិកក៏បានស្លាប់មានចំនួនប្រហាក់ប្រហែលគ្នានេះដែរ ថែមទាំងបានបន្សល់ទុកនូវខ្មោចយន្តហោះកន្ទុំរុយពីរគ្រឿង និងធុងសាំងចំនួនពីរទៀតផង ។

ការប្រយុទ្ធរវាងកងទ័ពខ្មែរក្រហម និងទាហានអាមេរិកនៅកោះតាងនេះ គឺដើមហេតុមកពីកងទ័ពខ្មែរក្រហមបានចាប់កប៉ាល់ម៉ាយ៉ាហ្គេស ដែលជាកប៉ាល់ដឹកទំនិញរបស់អាមេរិក ហើយអាមេរិកទាមទារឲ្យដោះលែងកប៉ាល់របស់ខ្លួន ។ កប៉ាល់ម៉ាយ៉ាហ្គេសបានដឹកទំនិញឆ្លងកាត់ក្បែរកោះប៉ូឡូវៃ ហើយត្រូវបានកងទ័ពជើងទឹករបស់ខ្មែរក្រហមចេញមកស្ទាក់ចាប់ពីកោះប៉ូឡូវៃយកមកទុកនៅកោះតាង ។

បន្ទាប់ពីរំដោះបានវៀតណាមខាងត្បូងនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៥ ប្រហែល២សប្ដាហ៍កងទ័ពវៀតណាមបានវាយសម្រុកកងទ័ពខ្មែរក្រហមនៅកោះក្រចកសេះ និងកោះប៉ូឡូវៃ ។ កងទ័ពវៀតណាមបានចាប់កងទ័ពខ្មែរក្រហមទាំងអស់យកទៅឃុំឃាំងនៅកោះត្រល់ និងបានបាញ់ពន្លិចទូកម៉ាស៊ីនរបស់ខ្មែរក្រហមអស់ជាច្រើនគ្រឿង ។ ក្រោយមក នួន ជា បានជួបចរចារជាមួយភាគីវៀតណាម ដើម្បីឲ្យដោះលែងកងទ័ពខ្មែរ និងប្រគល់កោះប៉ូឡូវៃមកឲ្យខ្មែរវិញ ។ បន្ទាប់ពីវៀតណាមប្រគល់កោះប៉ូឡូវៃមកវិញ ខ្មែរក្រហម ក៏បានបញ្ជូន អ៊ុន និងកងវរសេនាតូចលេខ៤១០ ទៅប្រចាំការកោះប៉ូឡូវៃ ។

ប្រជាជនវៀតណាម និងថៃតែងតែមកនេសាទត្រីនៅក្បែរៗកោះប៉ូឡូវៃ ហើយត្រូវកងទ័ពខ្មែរក្រហមចាប់ឃាត់ទុក និងបញ្ជូនអ្នកនេសាទទាំងនោះទៅកំពង់សោម ។ លើសពីនេះ ក៏មានជនបរទេសក្រៅពីថៃ និងវៀតណាម បានបើកក្ដោងឆ្លងកាត់ និងត្រូវកងទ័ពខ្មែរក្រហមចាប់បញ្ជូនមកកំពង់សោមដែរ ។

អ៊ុន ធ្លាប់ត្រូវបានចាត់តាំងឲ្យមករៀនសូត្រ និងប្រជុំនៅកំពង់សោមម្ដងម្កាលដែរ គឺប្រជុំម្ដងៗមានរយៈពេលមួយខែកន្លះ អ្នកដឹកនាំប្រជុំមាន មាស មុត, សេង, សុន សេន ហើយការប្រជុំនោះគឺទាក់ទងទៅនឹងការការពារជាតិ និងការការពារដែនដី ។ នៅកោះប៉ូឡូវៃ អ៊ុន និងកងទ័ពផ្សេងទៀតបានដាំបន្លែបង្ការ និងធ្វើដែដើម្បីចតទូក កាណូតជាដើម ។ កងទ័ពខ្មែរក្រហម ហូបចុកមួយថ្ងៃ៣ពេល គឺពេលព្រឹកហូបបបរ ពេលថ្ងៃហូបបាយ និងពេលល្ងាចហូបបាយ ។

នៅឆ្នាំ១៩៧៩ វៀតណាមបានវាយចូលដល់កំពង់សោម អ៊ុន និងកងទ័ពផ្សេងទៀត បានរត់ចេញពីកោះប៉ូឡូវៃ ដោយឆ្លងកាត់តាមចម្លងគោ នៅខាងជើងស្ទឹងហាវ ឆ្ពោះទៅអណ្ដូងទឹក និងឡើងភ្នំអូរដបង ។ បន្ទាប់មក អ៊ុនរួមជាមួយកងទ័ព និងប្រជាជនប្រុសស្រីចំនួន៣៣នាក់បានរត់ត្រឡប់មកកំពង់ស្ពឺ និងបានចូលសារភាពជាមួយវៀតណាម ។ អ៊ុន ត្រូវស្ថិតនៅមន្ទីរអប់រំរយៈមួយខែកន្លះ វៀតណាមបានបញ្ជូនមកកំពង់ត្រាំ ពាមខ្វាវ ។ បន្ទាប់មក អ៊ុន និងមនុស្សជាង៣០នាក់ផ្សេងទៀតបានបែកគ្នាត្រឡប់មកស្រុកកំណើតរៀងៗខ្លួន ។ **សោម លាភ**

# ជីវិតតស៊ូជាមួយខ្មែរក្រហម

ព្រុំ រិន ភេទប្រុស អាយុ៥៨ឆ្នាំ កើតនៅភូមិចាន់ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង ។ សព្វថ្ងៃរស់នៅភូមិទួលពង្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ ឪពុកឈ្មោះ ព្រុំ រ៉ែន និងម្តាយឈ្មោះ ប៉ាវ រូ ។ ក្នុងចំណោមបងប្អូនបង្កើតចំនួនប្រាំពីរនាក់ រិន ជាកូនច្បងគេ ។ មិនមានសមាជិកណាម្នាក់ក្នុងគ្រួសាររបស់ រិន បានស្លាប់នៅក្នុងរបបខ្មែរក្រហមទេ ។ រិន បានរៀបការជាមួយប្រពន្ធឈ្មោះ សន ថុល (បច្ចុប្បន្ន សន ថុល មានអាយុ៥៥ឆ្នាំ) នៅក្នុងឆ្នាំ១៩៨៣ និងមានកូនចំនួន៨នាក់ ។

រិន រៀនបានត្រឹមថ្នាក់ទី១០ នៅសាលាបឋមសិក្សាភូមិចាន់ ។ ក្រោយពេលមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រិន ក៏បានឈប់រៀន និងជួយធ្វើការងារស្រែចម្ការជាមួយឪពុកម្តាយរបស់ខ្លួនវិញ ។ ពីរឆ្នាំក្រោយបន្ទាប់ពីរដ្ឋប្រហារ រិន បានស្ម័គ្រចិត្តចូលធ្វើយោធានៅស្រុកពាមរក៍ ដែលកាលណោះ គណៈស្រុកមានឈ្មោះ វ៉ែង ហៅ រដ្ឋ និងតាចែម ។

ពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ យោធាតំបន់២៤ បានមកវាយនៅសមរភូមិក្បែរអ្នកលឿង មុំខ្ចត វត្តវាលដំបង មានពីរវរសេនាធំ គឺង-១២៤ និង ង-១២៥ ដើម្បីដណ្តើមយកអ្នកលឿងពី ទាហាន លន់ នល់ ។ ប៉ុន្តែយោធាពីរវរសេនាធំនេះមិនបានបន្តដំណើរចូលមកទីក្រុងភ្នំពេញទេ ហើយបានរំសាយទៅវិញ នៅពេលវាយបែកសមរភូមិអ្នកលឿង ។

នៅឆ្នាំ១៩៧៤ រិន បានចេញពីអង្គភាពយោធាថ្នាក់ស្រុកឡើងទៅអង្គភាពយោធាថ្នាក់តំបន់ ។ ប៉ុន្តែនៅពេលនោះមិនទាន់បង្កើតកងពលនៅឡើយទេ គឺមានត្រឹមអង្គភាពវរសេនាធំ «ង-១២៤» និង «ង-១២៥» ដែលប្រធានវរសេនាធំ ង-១២៥ ឈ្មោះ ឈួន ។ រិន ធ្វើយោធានៅកងធំ «គ-១០» ក្នុងវរសេនាតូច «ឃ-៣» ។

បន្ទាប់មក រិន បានចូលក្នុងកងពិសេស ដែលកងពិសេសនោះមានឈ្មោះ សុខ សេន ហៅ សុខ សារឿន ជាប្រធានវរសេនាធំ ជំនួសឲ្យឈ្មោះ ឈួន ព្រោះ ឈួន ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៦ ។ កាលណោះ រិន មានតួនាទីជាប្រធានកងតូចក្តាប់ទាហានប្រមាណជា៣០ទៅ៤០នាក់ ដោយមួយក្រុមៗ មានសមាជិក១២នាក់ ។

ឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងហើយ កម្លាំងរបស់ រិន ដែលមានពីរវរសេនាធំ បានត្រឡប់ទៅឈរជើងនៅតាមព្រំដែនក្នុងភូមិសាស្ត្រមុំទួលតាប៉ុល ក្នុងឃុំទាមទារ ស្រុកព្រះស្តេច និងស្រុកពាមជរ ។ នៅទីនោះ រិន និងសមាជិកឯទៀត ត្រូវបានអង្គការឲ្យធ្វើស្រែផង និងការពារព្រំដែនផង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ ហួយ ប្រធានវរសេនាធំ១៧០ ។ បន្ទាប់មក នៅឆ្នាំ១៩៧៦-១៩៧៧ នៅតាមព្រំដែនកម្ពុជា-វៀតណាម បានកើតមានការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំង ដែលការវាយប្រយុទ្ធគ្នានេះ បណ្តាលឲ្យយោធាខ្មែរក្រហមដែលឈរជើងការពារនៅសមរភូមិព្រំដែន និងយោធាថ្មើរជើង បានស្លាប់អស់ជាច្រើននាក់ ។

បន្ទាប់មកទៀត នៅឆ្នាំ១៩៧៨ កើតមានយុទ្ធនាការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា ដែលការបោសសម្អាតនេះធ្វើឡើងដោយកម្មាភិបាលមកពីភូមិភាគនិរតី ។ ការបោសសម្អាតនេះ បានសម្លាប់បក្ខពួកដែលជាខ្សែរបស់ សោ ភឹម ស្ទើរតែទាំងអស់ ចំណែកឯ រិន និងយោធាដែលឈរជើងនៅតាមព្រំដែនមិនត្រូវបានបោសសម្អាតទេ ។ ក្នុងអំឡុងពេលនោះដែរ មជ្ឈិមបក្សបានបង្កើតកងពល៨០៥ ដែលប្រធានកងពលជាមនុស្សមកពីខាងនិរតី ហើយ សុខ សារឿន ត្រូវបានតម្លើងជាអនុប្រធានកងពល ។ ចំណែក រិន ក៏ត្រូវបានបញ្ចូលទៅក្នុងកងពល៨០៥ នេះដែរ ។

នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ រិន មិនបានវិលត្រឡប់ទៅស្រុកកំណើតដើម្បីជួបជុំសាច់ញាតិ និងក្រុមគ្រួសាររបស់ខ្លួនទេ ព្រោះ រិន បានលង់ខ្លួនតាមការឃោសនា

របស់ខ្មែរក្រហម ដោយបាននិយាយថា យួននឹងសម្លាប់ចោល បើហ៊ានទៅស្រុកវិញ ។ ហេតុដូច្នេះហើយ រិន និងយុទ្ធជនឯទៀត ក៏ចេះតែរត់ទៅដោយគ្មានទិសដៅ ។ រិន និងបក្ខពួក បានធ្វើដំណើរតាមក្បួនធ្វើពីដើមចេក ដើម្បីឆ្លងកាត់ទន្លេមេគង្គ ហើយបានទៅដល់កោះរកា ។ ប៉ុន្តែ ពេលដែលកំពុងឆ្លងទន្លេនោះ កងទ័ពវៀតណាមបានដេញតាមពីក្រោយយ៉ាងប្រកៀកប្រកិត ។ រិន ក៏បានប្រើកាំភ្លើងបេបាញ់សំដៅទៅកងទ័ពវៀតណាមដើម្បីរារាំងផ្លូវ ។ ពេលឡើងដល់ច្រាំងហើយ រិន និងសមាជិកផ្សេងៗទៀត បានការពារ សុខ សារឿន ដែលជាមេកើយរបស់ខ្លួនដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ ។

បន្ទាប់មក ក្រុមរបស់ រិន បានជួបកងទ័ពវៀតណាមនៅក្បែរទន្លេបាសាក់ម្តងទៀត ការវាយប្រយុទ្ធគ្នាក៏កើតមានឡើងម្តងទៀតដែរ តែការវាយប្រយុទ្ធគ្នានេះ ក្រុមរបស់ រិន មិនអាចវាយឈ្នះកងទ័ពវៀតណាមទេ ដូច្នេះក៏នាំគ្នាវាយរំដោះរត់គេចខ្លួនបន្តទៀត ។

រិន បានឆ្លងទន្លេបាសាក់រហូតទៅដល់ឱរ៉ាល់ ហើយបានបន្តដំណើរទៅមុខទៀត ដោយប្រើរយៈពេលអស់ជាច្រើនខែ ។ ការធ្វើដំណើរតាមផ្លូវឆ្ពោះទៅជាយដែន ពេលខ្លះត្រូវពើបប្រទះជាមួយកងទ័ពវៀតណាម និងបានវាយប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាមដើម្បីការពារខ្លួនផង និងរំដោះខ្លួនធ្វើដំណើរផ្លាស់ទីគេចចេញឲ្យឆ្ងាយពីកងទ័ពវៀតណាមផង ។ នៅតាមផ្លូវធ្វើដំណើរ រិន ក៏បានជួបប្រទះសាកសពរបស់ប្រជាជនជាច្រើន ដែលបានស្លាប់ដោយអត់អាហារ និងខ្លះត្រូវវៀតណាមបាញ់សម្លាប់ ។ ការធ្វើដំណើរគេចខ្លួនឆ្ពោះទៅជាយដែនក្រុមរបស់រិនបានជួបខបសគ្គជាច្រើន ជួនកាលត្រូវពើបប្រទះនឹងខ្មែរក្រហមគ្នាឯងខាងនិរតី ហើយបានវាយប្រយុទ្ធគ្នាទៀតផង ព្រោះខាងនិរតីមិនត្រូវគ្នាជាមួយខាងបូព៌ាទេ ជាពិសេសកងពលរបស់ តាម៉ុក ។ នៅទីបំផុត រិន ក៏បានទៅដល់ស្រុកម៉ាឡៃ ។ នៅម៉ាឡៃ មានកងពលលេខ ៤៥០ ដែលគ្រប់គ្រងដោយឈ្មោះ តាភាព, តាឌុល សារឿន ។ ចំណែកប្រពន្ធកូនរបស់ រិន ក៏បានរស់ជួបជុំគ្នានៅម៉ាឡៃដែរ ។

នៅឆ្នាំ១៩៨០-១៩៨១ ប៉ុល ពត និង ខៀវ សំផន មានទំនាក់ទំនងជាមួយប្រទេសថៃ ដោយបានសុំជំនួយពីថៃជាអង្ករយកមកចែកឲ្យប្រជាជនបានម្នាក់បន្តិចបន្តួចដើម្បីបន្តជីវិត ។ លុះដល់ឆ្នាំ១៩៨៥ មានការវាយប្រយុទ្ធគ្នាខ្លាំង រវាងយោធាខ្មែរក្រហមជាមួយកងទ័ពយួន ធ្វើឲ្យប្រជាជន និងយោធាទាំងអស់ដែលរស់នៅតាមជាយដែនរត់ភៀសខ្លួនចូលទៅជ្រកកោនក្នុងទឹកដីថៃ ។ ក្រោយមក តាម៉ុក បានទៅទិញដីរំសម្រាប់កងទ័ពនៅក្នុងទឹកដីថៃ "អណ្តែតមុត" ហើយបានយក រិន ពីម៉ាឡៃទៅរស់នៅក្នុងដីរំនោះ ។ រិន ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ក្នុងអង្គភាពវរសេនាធំឯករាជ្យ ដែលមានឈ្មោះ ចែម ជាអ្នកក្តាប់ផ្ទាល់ ។

បន្ទាប់មក រិន បានចុះទៅធ្វើការងារជាមួយយោធា តាម៉ុក នៅស្រុកតំបែរ ក្នុងខេត្តកំពង់ចាម ដើម្បីបញ្ចុះបញ្ចូលប្រជាជនមិនឲ្យលក់ស្រូវឲ្យយួន និងកុំឲ្យកូនចៅរបស់ខ្លួនទៅចូលរួមក្នុងការងារ "ក-៥" របស់រដ្ឋាភិបាល ។ ក្រោយមក រិន បានទៅនៅក្នុងកងពល៥១៩ ដោយឈរជើងនៅថ្មរយ-ថ្មដូន ស្ថិតនៅក្នុងស្រុកគោកមន ខេត្តបន្ទាយមានជ័យ ។

ឆ្នាំ១៩៨៦-១៩៨៧ សម្តេចព្រះនរោត្តម សីហនុ បានយាងទៅម៉ាឡៃជាមួយភ្ញៀវជនជាតិចិន ក្នុងគោលបំណងឲ្យភាគីខ្មែរទាំងអស់មានការផ្សះផ្សាគ្នាឡើងវិញ ។ កំឡុងពេលដែលសម្តេចព្រះនរោត្តម សីហនុ យាងទៅស្រុកម៉ាឡៃទាំងបីលើកនោះ រិន បានទៅទទួលសម្តេចដោយផ្ទាល់ ។ រិន បានជួបជាមួយមេខ្មែរក្រហមធំៗមានដូចជា អៀង សារី ខៀវ សំផន នួន ជា និង សុន សេន នៅកន្លែងសាតាំងក្នុងស្រុកម៉ាឡៃ ។

នៅឆ្នាំ១៩៩២-១៩៩៣ រិន នៅឈរជើងនៅទីតាំងដដែល ប៉ុន្តែរស់នៅបែកគ្នាពីប្រពន្ធកូនមួយរយៈប្រហែលជាមួយឆ្នាំ ឬពីរឆ្នាំទើបបានជួបគ្នាម្តង ។ ក្រោយពេលដែលកម្លាំងយោធារបស់ខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ការរស់នៅរបស់ រិន មានការប្រសើរជាងមុនមួយកម្រិត ដោយប្រកបរបរកសិកម្ម ធ្វើស្រែចម្ការ ដាំដំឡូង សណ្តែកបាយ និងសណ្តែកសៀង ។ រីឯកូនៗ ក៏បានចូលសាលារៀន និងខ្លះបានរៀបចំគ្រួសារដូចគេឯងដែរ ។

**ដារ៉ារដ្ឋ មេត្តា**

# ពីមេដឹកនាំដែលប្រព្រឹត្តអំពើឃោរឃៅ មកជាមេដឹកនាំដែលប្រព្រឹត្តល្អនៅអន្លង់វែង

អន្លង់វែង គឺជាតំបន់តស៊ូចុងក្រោយបង្អស់របស់ខ្មែរក្រហម ដែលសព្វថ្ងៃបានក្លាយជាតំបន់ប្រវត្តិសាស្ត្រខ្មែរក្រហមអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិឲ្យចូលទស្សនា ។ ប្រជាជនរស់នៅក្នុងស្រុកអន្លង់វែងភាគច្រើនជាអតីតទាហានខ្មែរក្រហម ។ តាម៉ុក ជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំខ្មែរក្រហមធំៗ ដែលគ្រប់គ្រងនៅតំបន់អន្លង់វែងទាំងមូល ។ ប្រជាជនជាច្រើនបានយល់ថា តាម៉ុក ជាមេដឹកនាំសាហាវឃោរឃៅ ប៉ុន្តែ ក៏មានប្រជាជន និងជាអតីតយោធាខ្មែរក្រហមមួយចំនួនតូចដែលធ្លាប់រស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ក្នុងតំបន់អន្លង់វែង នៅតែគោរពស្រឡាញ់ និងដឹងគុណ តាម៉ុក ដូចជា សែម ផា ជាដើម ។

សែម ផា មានអាយុ៦៤ឆ្នាំ កើតនៅភូមិវិវេទ ឃុំរាបស្រុកពារាំង ខេត្តព្រៃវែង ។ សព្វថ្ងៃរស់នៅឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងមានកូនចំនួន៣នាក់ ស្រី២នាក់ និងប្រុសម្នាក់ ។ មុនឆ្នាំ១៩៧៥ ផា រស់នៅក្នុងទីក្រុងភ្នំពេញ លុះក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេសនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ផា ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅឯស្រុកកំណើតវិញ ក្នុងខេត្តព្រៃវែង ។ អំឡុងឆ្នាំ១៩៧៥ ផា ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាប្រធាននារីឈ្លបឃុំ ដោយគ្រប់គ្រងនារីជាង៥០០នាក់ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ផា ត្រូវបានកម្មាភិបាលថ្នាក់លើគាបសង្កត់សព្វបែបយ៉ាង ដោយសារពូរបស់គាត់បីនាក់ត្រូវបានខ្មែរក្រហមស៊ើបដឹងថាជាអតីតទាហានក្នុងរបប លន់ នល់ ហើយយកទៅសម្លាប់ ដោយ ផា បានឃើញផ្ទាល់នឹងភ្នែក ប៉ុន្តែគាត់


សែម ផា និង ឆេង ហាក់ និស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

មិនមានលទ្ធភាពដើម្បីជួយសង្គ្រោះជីវិតពួរបស់គាត់ទេ ។

ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានរួមគ្នា វាយផ្តួលរំលំរបបខ្មែរក្រហម ។ ពេលនោះ ផា បានរត់គេចខ្លួនទៅរស់នៅក្នុងទឹកដីថៃអស់រយៈពេលជិតមួយឆ្នាំ ។ លុះដល់ឆ្នាំ១៩៨០ សែម ផា បានមករស់នៅក្នុងស្រុកអន្លង់វែងវិញ ។ ផា បានប្រាប់បន្តឲ្យដឹងថា នៅពេលដែលគាត់មករស់នៅស្រុកអន្លង់វែងដំបូង កាលណោះ តំបន់អន្លង់វែង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក នៅឡើយ ។ តាម៉ុក បានចែកដីធ្លី និងឈើដល់គាត់សម្រាប់សាងសង់ផ្ទះសម្បែង និងបានចែកស្បៀងអាហារដល់ប្រជាជនជារៀងរាល់ខែ ដោយម្នាក់ៗទទួលបានអង្ករ៤០ កំប៉ុង ត្រីខ ស្ករ ប៊ីចេង អំបិល និងគ្រឿងទេសជាច្រើនទៀត ។ មិនតែប៉ុណ្ណោះ តាម៉ុក បានចែកដូងមួយដើម និងស្វាយមួយដើមដល់គ្រប់គ្រួសារទាំងអស់នៅក្នុងតំបន់នេះ ។ ចំណែកឯប្រជាជនដែលទើបតែរៀបការថ្មីថ្មោង តាម៉ុក បានចែកគោមួយនឹមជាចំណងដៃចំពោះមង្គលការទៀត ។ ផា បានបញ្ជាក់ថា ប្រជាជននៅក្រោមការដឹកនាំរបស់ តាម៉ុក ស្រឡាញ់រាប់អានគ្នា សាមគ្គីគ្នា និងចេះយល់អធ្យាស្រ័យគ្នាទៅវិញទៅមកប្រកបដោយស្នាមញញឹម ។ តាម៉ុក ជាមនុស្សដែលចូលចិត្តប្រើសម្តីអាក្រក់ ប៉ុន្តែគាត់តែងគិតដល់ប្រជាជនជានិច្ច ។ ម្យ៉ាងទៀត តាម៉ុក បានកសាងហេដ្ឋារចនាសម្ព័ន្ធជាច្រើនមានដូចជា ផ្លូវថ្នល់ មន្ទីរពេទ្យ ស្ពាន និងសាលារៀន ជាដើម ។ ផា បានបន្ថែមថា ទោះបីជាការដឹកនាំរបស់ខ្មែរក្រហមពោរពេញដោយអំពើសាហាវយង់ឃ្នង ព្រៃផ្សៃ ការបង្អត់អាហារ ការធ្វើទុក្ខបុកម្នេញ និងការធ្វើទារុណកម្មមកលើប្រជាជនកម្ពុជាយ៉ាងណាក៏ដោយ ប៉ុន្តែ ផ្ទុយពីការដឹកនាំរបស់ ប៉ុល ពត តាម៉ុក ទោះបីជា មានឈ្មោះថាជាមេដឹកនាំផ្តាច់ការបន្តិចមែន ប៉ុន្តែ គាត់មិនដែលឲ្យប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់គាត់ទទួលរងទុក្ខវេទនាដោយការធ្វើទារុណកម្ម ឬបង្អត់អាហារនោះទេ ។

ចំពោះទស្សនលើកឡើងដោយប្រជាជន និងអតីតយោធាមួយចំនួនតូច ដែលធ្លាប់រស់នៅជាមួយ តាម៉ុក និងធ្លាប់ទទួលបានការគាំទ្រ និងឧបត្ថម្ភពី តាម៉ុក ក្រោយពេលរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ នៅក្នុងតំបន់អន្លង់វែង មិនមានការគាំទ្រពីប្រជាជនកម្ពុជាដែលជាជនរងគ្រោះទេ ហើយការលើកឡើងនេះបានធ្វើឲ្យក្មេងជំនាន់ក្រោយ ជាពិសេសសិស្សានុសិស្ស មានការយល់ច្រឡំចំពោះការប្រព្រឹត្តិអំពើឃោរឃៅពីឆ្នាំ១៩៧៥-៧៩ និងអ្វីដែលខ្មែរក្រហមបានអនុវត្តជាមួយប្រជាជនក្រោយឆ្នាំ១៩៧៩ ។ ដោយសារគោលនយោបាយដឹកនាំផ្តាច់ការ នៅអំឡុងពេលគ្រប់គ្រងពីឆ្នាំ១៩៧៥-៧៩ តាម៉ុក បានប្រើអំណាចរបស់ខ្លួនចាប់បញ្ជូនយោធានិងកម្មាភិបាលនៅភូមិភាគនិរតីដូចជា សេក សាត ហៅ និន ហៅ ប្រាក់ លេខាតំបន់២៥ និងប្រពន្ធឈ្មោះ ចាន់ គីមស្រ៊ិន មកឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ ។ តាមការអះអាងរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រធានមន្ទីរសន្តិសុខស-២១ នៅចំពោះមុខសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយបន្សល់ទុកនូវកូនស្រីកំព្រាឈ្មោះ សេក សាយ រស់នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺរហូតមកដល់សព្វថ្ងៃ ។ តាម៉ុក ក៏បានសម្លាប់ប្រជាជន រួមទាំងអតីតយោធា និងកម្មាភិបាលខ្មែរក្រហមជាច្រើនទៀតនៅភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យ ដោយចោទថាក្បត់ដែរ ។ តាម៉ុក ជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំខ្មែរក្រហមដែលបានកាប់សម្លាប់ប្រជាជនស្លូតត្រង់អស់ប្រមាណជាង១.៧លាននាក់ ។




**ឆេង ហាក់**

# ជីវភាពរស់នៅរបស់ប្រជាជននៅអន្លង់វែង មុននិងក្រោយសមាហរណកម្ម

អន្លង់វែង ជាតំបន់មួយស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា និងជាប់ព្រំប្រទល់ជាមួយប្រទេសថៃ ។ អន្លង់វែង ជាតំបន់ដែលមាន សក្តានុពលក្នុងការទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកទស្សនា និងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រនៅក្នុងតំបន់នេះ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏យុវជនជំនាន់ក្រោយមួយចំនួនធំពុំទាន់ស្គាល់ និងដឹងអំពីរឿងរ៉ាវប្រវត្តិសាស្ត្រដែលបានកើតឡើងនៅក្នុងតំបន់អន្លង់វែងច្បាស់លាស់ទេ ។


ចាវ ចាន់ណោត នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ចាប់តាំងពីខ្មែរក្រហមចាញ់សង្គ្រាមនៅឆ្នាំ១៩៧៩ មក ក្រុមយោធាខ្មែរក្រហមខ្លះត្រូវបានចាប់ខ្លួន ខ្លះបានចូលសារភាព ត្រឡប់មករស់នៅស្រុកកំណើត ហើយមួយចំនួនទៀត បានរត់បែកខ្ញែកទៅតំបន់ផ្សេងៗ នៅតាមបណ្តោយព្រំប្រទល់កម្ពុជា-ថៃ ដូចជានៅស្រុកអន្លង់វែង សំឡូត សំពៅលូន ប៉ៃលិន និងម៉ាឡៃ ជាដើម ។ តំបន់អន្លង់វែង គឺជាតំបន់ដែលកាន់កាប់ដ៏រឹងមាំ និងចុងក្រោយរបស់ខ្មែរក្រហម ក្រោមការដឹកនាំរបស់ តាម៉ុក ។ ប្រជាជនដែលរស់នៅក្នុងតំបន់នេះភាគច្រើនជាអតីតខ្មែរក្រហម ។ លុះដល់ឆ្នាំ១៩៩៨ របនាសម្ព័ន្ធរបស់ខ្មែរក្រហមទាំងស្រុងត្រូវបានបញ្ចប់ ដោយកម្លាំងយោធារបស់ខ្មែរក្រហម បានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ ចំពោះ តាម៉ុក ប្រជាជនទូទៅនៅក្នុងប្រទេសបានគិតថា គាត់គឺជាមេដឹកនាំម្នាក់ដែលផ្តាច់ការ និងឃោរឃៅ ប៉ុន្តែសម្រាប់ប្រជាជនមួយចំនួនដែលរស់នៅក្នុងតំបន់អន្លង់វែងក្រោមការដឹកនាំរបស់ តាម៉ុក ពីឆ្នាំ១៩៧៩-ឆ្នាំ១៩៩៨ វិញ នៅតែគោរព និងស្រលាញ់គាត់ ព្រោះប្រជាជនទាំងនោះយល់ថា តាម៉ុក បានបន្សល់នូវស្នាដៃមួយចំនួនទុកឲ្យកូនចៅជំនាន់ក្រោយមានដូចជា អាគារសាលារៀន មន្ទីរពេទ្យ ស្ពាន និងបឹងដែលគាត់ដឹកនាំប្រជាជនជីកដើម្បីរក្សាទឹកទុក ហើយប្រជាជនក៏បានប្រើប្រាស់ទឹកបឹងនេះរហូតមកដល់សព្វថ្ងៃ ។

ចាវ ចាន់ណោត ជាកូនស្រីរបស់អតីតយោធារបស់ តាម៉ុក កើតក្រោយឆ្នាំ១៩៧៩ ហើយបានរស់នៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ផ្ទាល់ បាននិយាយពីរឿងរ៉ាវដែលឪពុករបស់គាត់បានបង្រៀន និងទូន្មានគាត់កាលគាត់នៅវ័យជំទង់ឲ្យចេះតស៊ូរស់ដូចសម័យ តាម៉ុក ។ ចាន់ណោត បានបន្ថែមថា ជីវភាពរស់នៅក្នុងសម័យ តាម៉ុក គ្រប់គ្រង គឺមិនមានការលំបាកខ្លាំងទេ ។ តាម៉ុក បានជួយផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់ប្រជាជនគ្រប់ក្រុមគ្រួសារទាំងអស់ ទោះបីជាទីនោះគ្មានទីផ្សារដើម្បីរកស៊ីលក់ដូរក៏ដោយ ប៉ុន្តែប្រជាជនរស់នៅមានជីវភាពសមរម្យ ដោយអាស្រ័យទៅលើជំនួយ និងអំណោយរបស់ តាម៉ុក ។ គ្រួសារខ្លះ បានបើកសម្ភារមួយខែម្តង ឬកន្លះខែម្តង មានដូចជា អង្ករ ប៊ីចេង ស្ករ ត្រីខកំប៉ុង ទឹក



រូបខាងស្តាំ ៖ ឈួន សុធារ រួមជាមួយនិស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ចុះសម្ភាសប្រជាជននៅក្នុងស្រុកអន្លង់វែង ពីបទពិសោធក្នុងសម័យខ្មែរក្រហម និងអំឡុងពេលមករស់នៅអន្លង់វែងដំបូង ។

ត្រី ជាដើម ។ ប្រជាជន តែងចែករំលែកសម្ភារផ្សេងៗឲ្យគ្នាទៅវិញទៅមក នៅពេលដែលមានការខ្វះខាត សូម្បីផ្ទះក៏មានសម្រាប់ស្នាក់នៅ មិនលំបាកលំបិន ដូចកាលសម័យ ប៉ុល ពត គ្រប់គ្រងអំណាចទេ ។ មិនតែប៉ុណ្ណោះ តាម៉ុក បានបង្រៀនប្រជាជនដែលរស់នៅក្រោម ការគ្រប់គ្រងរបស់គាត់ឲ្យចេះដាំបន្លែ ចិញ្ចឹមសត្វ យកផល ដោយខ្លួនឯង និងកេណ្ឌប្រជាជនទៅជីកស្រះ ធ្វើប្រឡាយទប់ទឹកសម្រាប់ប្រើប្រាស់ទៀតផង ។ និយាយរួម គឺជីវភាពរបស់ប្រជាជននៅពេលនោះ ធម្មតា មិនក្រខ្លាំង ហើយក៏មិនមានខ្លាំង ។ ប្រជាជនមានអាហារហូបចុកដូចគ្នា ការរស់នៅមានលក្ខណៈងាយស្រួល គ្រាន់តែមិនសូវមានសេរីភាពប៉ុណ្ណោះ ។

លុះដល់សម័យកាលក្រោយ តាម៉ុក គ្រប់គ្រង ពោលគឺក្នុងអំឡុងពេលដែលខ្មែរក្រហមធ្វើសមាហរណកម្ម និងក្រោយពេលដែល តាម៉ុក ត្រូវបានចាប់ខ្លួនដោយកងកម្លាំងរបស់រដ្ឋាភិបាល គាត់ក៏ដូចជាអ្នកភូមិដទៃទៀត ត្រូវរស់នៅ និងរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯង ដោយអ្នកខ្លះប្រកបរបររកស៊ីលក់ដូរ ខ្លះធ្វើស្រែចម្ការ និងខ្លះដាំបន្លែបផ្កាជាដើម ។ ពេលនោះ កម្រិតជីវភាពរបស់ប្រជាជន មានការប្រែប្រួលខ្លាំង អ្នករកស៊ីចេះតែមាន អ្នកធ្វើស្រែចម្ការបន្តិចបន្តួចក៏មានជីវភាពលំបាក និងខ្វះខាតខ្វះ ។ ចាន់ណោត បានបន្ថែមថា កាលពីសម័យ តាម៉ុក គ្រប់គ្រង កម្រិតជីវភាពរបស់ប្រជាជនស្មើៗគ្នា ។

ការគ្រប់គ្រងប្រទេសរបស់មេដឹកនាំខ្មែរក្រហមចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានធ្វើឲ្យហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសជាតិធ្លាក់ដល់កម្រិតក្រោមសូន្យ ។ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនគ្រប់ទីកន្លែងដោយបង្ខំឲ្យចេញពីផ្ទះសម្បែងរបស់ខ្លួនទៅរស់នៅតាមទីជនបទដាច់ស្រយាល បំបែកសមាជិកគ្រួសារឲ្យរស់នៅដាច់ដោយឡែកពីគ្នា បង្ខំឲ្យប្រជាជនធ្វើការហួសកម្លាំង ផ្តល់របបអាហារមិនគ្រប់គ្រាន់ ពេលឈឺថ្កាត់មិនមានថ្នាំពេទ្យព្យាបាលត្រឹមត្រូវជាដើម ។

មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមថែមទាំងសម្លាប់ប្រជាជនដោយគ្មានកំហុសអស់ជិតពីរលាននាក់ទៀតផង ក្នុងអំឡុងពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃដែលខ្លួនកាន់អំណាច ។

សោកនាដ្ឋកម្មជាច្រើនបានសន្សល់ទុកសម្រាប់ប្រជាជននិងប្រទេសកម្ពុជា ក្រោយពេលដែលរបបដ៏ឃោរឃៅនេះ បានដួលរលំបាត់ទៅ ។ ប៉ុន្តែទោះជាយ៉ាងណាក្តីសម្រាប់ ចាន់ណោត ដែលបានរស់នៅជំធាត់នៅតំបន់អន្លង់វែង និងមានការយល់ដឹងចំពេលដែលខ្មែរក្រហម បានធ្វើសង្គ្រាមជាមួយកងទ័ពវៀតណាមនៅតាមជាយដែន ចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ និងម៉្យាងទៀត ចំពេលខ្មែរក្រហមបានធ្វើការផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួនពីការរឹតបន្តឹង ធ្វើការរួម ហូបរួម មកធ្វើការតាមលទ្ធភាព និងហូបចុកតាមផ្ទះរៀងៗខ្លួន ហើយថែមទាំងបានជួយទំនុកបម្រុង ស្បៀងអាហារ សម្ភារប្រើប្រាស់ ដីធ្លី គោក្របី ស្រែចម្ការ ដល់ប្រជាជន ទើប ចាន់ណោត យល់ថា តាម៉ុក ជាអ្នកដឹកនាំមួយរូបដែលស្រឡាញ់ ប្រជាជន និងជួយការពារប្រជាជន ។

**ឈួន សុធារ**

# ការបែងចែករបបអាហារក្នុងរបបខ្មែរក្រហម

ខ្ញុំបាទឈ្មោះ អែម ណាឃីម ភេទប្រុស ជានិស្សិតឆ្នាំទី៤ ផ្នែកអភិវឌ្ឍសេដ្ឋកិច្ច នៅវិទ្យាល័យភូមិន្ទភ្នំពេញ ។ ខ្ញុំបានចូលរួមក្នុងដំណើរទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងរយៈពេលបួនថ្ងៃចាប់ពីថ្ងៃសុក្រ ទី១២-១៥ ខែមករា ឆ្នាំ២០១៨ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ក្នុងអំឡុងពេលដំណើរទស្សនកិច្ច ខ្ញុំបានជួបសម្ភាសជាមួយអតីតយោធាខ្មែរក្រហមម្នាក់ឈ្មោះ គី សុភាន់ អាយុ៦២ឆ្នាំ ដែលមានភរិយាឈ្មោះ មី សុខឃាង និងមានកូនចំនួន៧នាក់ ប្រុស៥នាក់ និងស្រី២នាក់ រស់នៅក្នុងភូមិអូរុន ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

សុភាន់ ជាអ្នកស្រុករស់នៅក្នុងខេត្តក្រចេះ ហើយធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមក្នុងពេលដែលគាត់មានវ័យ២១ឆ្នាំ ។ សុភាន់ បានប្រាប់ឲ្យដឹងថា ការរស់នៅក្នុងរបបខ្មែរក្រហម ប្រជាជនមានរបបហូបចុកតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់ និងពេលល្ងាច ។ របបអាហារដែលប្រជាជនទទួលបាននោះ គឺបបរលាយជាមួយត្រកួន ដែលមានចំនួនពីរវែកប៉ុណ្ណោះក្នុងមួយពេលសម្រាប់ប្រជាជនម្នាក់ ។

ដើម្បីទទួលបានអាហារនេះ ប្រជាជនត្រូវឈរតម្រង់ជួរនៅខាងមុខរោងបាយរួម សម្រាប់អ្នកដែលបានបំពេញការងារជូនអង្គការរួចរាល់ហើយ ។ ប៉ុន្តែ ប្រសិនបើអ្នកដែលមិនទាន់បានបំពេញការងារជូនអង្គការរួចរាល់ទេ អ្នកនោះនឹងត្រូវធ្វើការទ្វេរដង បន្ទាប់ពីហូបអាហាររួច ។ បបរចំនួនពីរវែក គឺជាបបររាវដែលមានបរិមាណទឹកច្រើនជាងកាក ។ សុភាន់ បានបន្តថា គាត់បានយកដែកគោលមកចោះបាតចានឲ្យមានប្រហោង ដើម្បីឲ្យទឹកបបរហូរចេញ ។ នៅពេលទឹកបបរហូរចេញអស់ នៅសល់កាកបបរត្រឹមតែពីរទៅបីស្លាបព្រាបាយប៉ុណ្ណោះ ។ ការហូបមិនឆ្អែតបែបនេះបណ្តាលឲ្យសេចក្តីស្រេកឃ្លានកើតឡើងស្ទើររៀងរាល់ថ្ងៃ ដូច្នេះ



រូបកណ្តាល ៖ អែម ណាឃីម និស្សិតស្ម័គ្រចិត្តមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សម្ភាស គី សុភាន់ ពីបទពិសោធក្នុងសម័យខ្មែរក្រហម និងរឿងរ៉ាវនៅក្នុងតំបន់អន្លង់វែងពេលគាត់មករស់នៅដំបូង ។

ដើម្បីចម្អែតក្រពះ សុភាន់ បានចូលទៅក្នុងចម្ការលួចបេះផ្លែត្រប់យកមកហូបជាមួយនឹងអំបិលដើម្បីបំបាត់ការស្រេកឃ្លាន ។ សុភាន់ បានបន្តថា នៅពេលដែលគាត់កំពុងលួចបេះផ្លែត្រប់ ប្រសិនបើអង្គការបានឃើញ ឬក៏មកទាន់ នោះគាត់នឹងត្រូវអង្គការចោទប្រកាន់ថាក្បត់ ហើយនឹងចាប់គាត់យកទៅសម្លាប់ចោលជាក់ជាមិនខានឡើយ ។

នៅឆ្នាំ១៩៧៧ នៅពេលដែល សុភាន់ កំពុងតែដេកនៅក្នុងវត្តមួយ គាត់បានឃើញខ្មែរក្រហមបញ្ជូនយោធាចំនួន១១នាក់ទៅព្រំដែនកម្ពុជា-វៀតណាម ដើម្បីធ្វើសង្គ្រាមទប់ទល់ជាមួយនឹងកងទ័ពវៀតណាម ។ នៅក្នុងឆ្នាំនេះដែរ គាត់ក៏ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើសង្គ្រាមជាមួយវៀតណាមដែរ ។ ជារៀងរាល់ព្រឹក អង្គការបានចែកបាយឲ្យយោធានៅក្នុងអង្គភាពម្នាក់មួយកញ្ចប់ ។ ពេលនោះគឺជាពេលដែល សុភាន់ បានទទួលអាហារហូបចុកគ្រប់គ្រាន់ ហើយក៏ជាពេលមួយគ្រោះថ្នាក់ដែរសម្រាប់ សុភាន់ ព្រោះ សុភាន់ ត្រូវប្រឈមជាមួយនឹងកងទ័ពវៀតណាម ។ ពេលខ្លះ សុភាន់ ថែមទាំងយំទៀតផង ព្រោះតែគាត់ភ័យខ្លាចស្នូរគ្រាប់កាំភ្លើង ។

នៅឆ្នាំ១៩៧៨ សុភាន់ បានបម្រើការងារជាអ្នកដឹកជញ្ជូនស្បៀងឲ្យយោធាខ្មែរក្រហម ។ ពេលខ្លះ យោធាដែលឈរជើងនៅសមរភូមិមុខ មិនបានទទួលរបបបាយទេ ព្រោះជាប់ប្រយុទ្ធតទល់ជាមួយនឹងកងទ័ពវៀតណាម ។ ចំណែក សុភាន់ វិញ បានហូបបាយយ៉ាងបរិបូរណ៍ ព្រោះអាហារសម្រាប់ឲ្យយោធាជួរមុខនៅសល់ច្រើន ។ ពេលធ្វើសង្គ្រាមជាមួយវៀតណាម សុភាន់ ក៏ដូចជាយោធាផ្សេងៗទៀតដែរ មិនមានកន្លែងសម្រាប់ស្នាក់នៅសមរម្យនោះទេ ពេលខ្លះត្រូវដេកផ្ទាល់ដី ហើយពេលខ្លះទៀត ត្រូវដេកនៅក្នុងថ្លុកទឹកភ្លៀងក៏មានដែរ ។

នៅឆ្នាំ១៩៧៩ បន្ទាប់ពីខ្មែរក្រហមធ្វើសង្គ្រាមចាញ់វៀតណាម សុភាន់ និងមិត្តភក្តិពីរនាក់ទៀត បានរត់ត្រឡប់ទៅកាន់ខេត្តក្រចេះវិញ ។ ពេលទៅដល់ទន្លេមេគង្គ គាត់ និងមិត្តភក្តិបានកាប់ដើមចេកមួយដើម និងឫស្សីមួយដើមមកចងបណ្តែតទឹកដើម្បីហែលឆ្លងទន្លេ ។ សុភាន់ និងមិត្តភក្តិ បានចំណាយពេលអស់២០ម៉ោងក្នុងការហែលឆ្លងកាត់ទន្លេ ។ បន្ទាប់ពីបានហែលឆ្លងទៅដល់ត្រើយម្ខាង សុភាន់ បានចូលទៅក្នុងចម្ការនៅជាប់មាត់ទន្លេលួចបេះផ្លែក្រូចថ្លុងរបស់ប្រជាជន ដើម្បីបំពេញសេចក្តីស្រេកឃ្លាន ។ នៅពេលកំពុងបេះផ្លែក្រូចថ្លុង ម្ចាស់ចម្ការបានមកទាន់ ប៉ុន្តែគាត់មិនបានស្តីថាអ្វីឡើយ ថែមទាំងបានអញ្ជើញ សុភាន់ និងមិត្តភក្តិឲ្យទៅហូបបាយនៅផ្ទះរបស់គាត់ទៀតផង ។ បន្ទាប់ពីហូបបាយរួច សុភាន់ និងមិត្តភក្តិ បានជម្រាបលាម្ចាស់ផ្ទះ បន្តធ្វើដំណើរទៅមុខទៀត ។ ក្រោយមក សុភាន់ បានទៅដល់ភ្នំមួយមានឈ្មោះថា ភ្នំ ១០០១ នៅជាប់ព្រំដែនប្រទេសឡាវ ថៃ និង កម្ពុជា ។ នៅទីនោះសម្បូរណ៍អាហារ (ឬអាចនិយាយបានថា ជាឃ្លាំងស្បៀង) ហើយពេលនោះក៏មានជនភៀសខ្លួនជាច្រើនបានស្លាប់បណ្តាលមកពីហូបអាហារច្រើន (ហល់) លើសកំណត់ដែរ ។

ក្រោយមក សុភាន់ បានរៀបការជាមួយ មី សុខឃាង ដែលជាអ្នកស្រុកមកពីក្រចេះដូចគ្នា និងបានបន្តរស់នៅក្នុងស្រុកអន្លង់វែងរហូតដល់សព្វថ្ងៃ ។

**រ៉ែម ណាឃីម**


# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# មិនហ៊ាននៅផ្ទះនាពេលថ្ងៃ

"ខ្ញុំតូចចិត្តនឹងខ្លួនឯងដែលមិនបានរៀនសូត្រចេះដឹងនឹងគេ" ការដែលមិនចេះដឹងនេះហើយបានធ្វើឲ្យខ្ញុំមិនហ៊ាននៅផ្ទះនាពេលថ្ងៃ ។ ខ្ញុំតែងតែចង់ចូលទៅក្នុងព្រៃ ទៅចម្ការ ឬទៅវាលស្រែ ពីព្រោះវាជាមធ្យោបាយដ៏ល្អសម្រាប់ខ្ញុំ ក្នុងការគេចមុខពីយុវជនយុវនារី ឬសិស្សានុសិស្សនាសម័យបច្ចុប្បន្ននេះ ។ នៅពេលជួបអ្នកទាំងនេះ ធ្វើឲ្យខ្ញុំនឹកឃើញដល់យុវវ័យរបស់ខ្ញុំដែលមិនមានសិទ្ធិទៅសាលារៀនសូត្រ និងសិទ្ធិជួបជុំចែករំលែកភាពសប្បាយរីករាយដល់ក្រុមគ្រួសារ ។

ខាងលើជាសំដីរបស់លោកតា យស់ ផាច អាយុ៥៩ឆ្នាំ មានស្រុកកំណើតនៅភូមិពែងមាសជើង ឃុំស្ពឺ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ តា ផាច មានឪពុកឈ្មោះ អ៊ុច អាន និងម្តាយឈ្មោះ នាដុន (ឪពុកម្តាយគាត់ស្លាប់ក្នុងសម័យខ្មែរក្រហម) ហើយគាត់មានបងប្អូនបង្កើត៤នាក់ (ស្រីបីនាក់) ។ ប្រពន្ធឈ្មោះ មុត រី និងមានកូនស្រីបីនាក់ ។ សព្វថ្ងៃតា ផាច និងក្រុមគ្រួសាររស់នៅក្នុងភូមិថ្មី ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ កាលពីនៅក្មេង តា ផាច រៀននៅសាលាបឋមសិក្សាវត្តព្រេង ក្នុងខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៧២ តា ផាច បានឈប់រៀនត្រឹមថ្នាក់ទី៦ចាស់ ដោយសារសង្គ្រាមសាលានៅភូមិវត្តព្រេង និងសាលាផ្សេងទៀតត្រូវបានបិទ និងមិនមានគ្រូមកបង្រៀនឡើយ ។ ដូច្នេះ ទើប តា ផាច បានខកបំណង ដោយកាលពីនៅក្មេង តា ផាច មានក្តីប្រាថ្នាចង់ក្លាយជាអ្នករៀនសូត្របានជ្រៅជ្រះ ដើម្បីយកចំណេះទាំងនោះ មកប្រកបការងារជួយដល់គ្រួសាររបស់គាត់ ។



យស់ ផាច បានឆ្លៀតពេលផ្តល់បទសម្ភាសដល់ ហូ ចុនា អ្នកសរសេរទស្សនាវដ្តីស្វែងរកការពិត ពីបទពិសោធក្នុងរបបខ្មែរក្រហម ពេលគាត់កំពុងឆាបរណារអាឈើនៅក្រោមផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ។

### ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥

នៅឆ្នាំ១៩៧៥ តា ផាច ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ធំ ប្រើឲ្យលើកទំនប់ស្ទឹងជីនិត ហើយគាត់នៅក្នុងកងចល័តដែលមានសមាជិក១៩៣នាក់ ។ តា ផាច បន្តថា កាលណោះគឺជារដូវប្រាំងការកាប់ដីលើកទំនប់មានការលំបាកខ្លាំង ដោយដីរឹងប្រេះក្រហែង ហើយទឹកក៏គ្មានផឹកគ្រប់គ្រាន់ដែរ ។ រីឯការហូបចុកវិញ គឺមានត្រឹមតែបាយលាយជាមួយចេកខ្ចីប៉ុណ្ណោះ ។ ទោះបីលំបាកយ៉ាងនេះក្តី តា ផាច មិនដែលហ៊ានតវ៉ានឹងអង្គការឡើយ ដោយសារតែគាត់យល់ថា ប្រសិនបើតវ៉ាចំពោះការហូបចុក ច្បាស់ជាអង្គការយកទៅសម្លាប់ចោលជាមិនខាន ។ កន្លះឆ្នាំក្រោយមក តា ផាច ត្រូវបានខ្មែរក្រហមជម្លៀសទៅស្រុកចម្ការលើវិញ ដោយឲ្យលើកទំនប់៥កុម្ភៈ ដើម្បីទប់ទឹកបញ្ចូលស្រែ ឬប្រឡាយឲ្យមានទឹកគ្រប់គ្រាន់សម្រាប់ធ្វើស្រែចម្ការ ។ រហូតដល់ឆ្នាំ១៩៧៦ អង្គការបានចាត់តាំង តា ផាច ឲ្យចូលបម្រើអង្គភាពកងទ័ពខ្មែរក្រហម ដោយឲ្យឈរជើងនៅទីក្រុងភ្នំពេញ និងមានភារកិច្ចយាមល្បាតជុំវិញក្រុងភ្នំពេញ ។ ចុងឆ្នាំ១៩៧៨ តា ផាច ត្រូវបានអង្គការបញ្ជាឲ្យទៅប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅអ្នកលឿង ។

## ក្រោយខ្មែរក្រហមដួលរលំ

នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហម ពេលនោះ ពូ ថាច បានរត់ភៀសខ្លួនទៅស្រុកប៉ៃលិន នៅម្តុំខ្សែម ។ ការរត់ភៀសខ្លួន ពូ ថាច ជួបឧបសគ្គជាច្រើនដោយបានប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាមនៅតាមផ្លូវជាច្រើនលើកច្រើនសារ ។ មិនត្រឹមតែប៉ុណ្ណោះ ក្រុមរបស់គាត់ក៏គ្មានអាហារហូបចុកនៅតាមផ្លូវគ្រប់គ្រាន់ដែរ គឺមានត្រឹមតែអង្ករពីរបីក្តាប់ សម្រាប់បបរក្នុងមួយពេលៗប៉ុណ្ណោះ សម្រាប់កងទ័ពប្រហែល៩០នាក់ ។ ក្នុងនោះដែរ ពូ ថាច និងសមាជិកក្រុមមិនដែលបានសម្រាកក្នុងពេលធ្វើ ដំណើរឡើយ ដោយសារកងទ័ពវៀតណាមដេញបាញ់ប្រកិតពីក្រោយ ។ ពូ ថាច បានធ្វើដំណើរមកដល់តំបន់ប៉ៃលិន ហើយរស់នៅទីនោះអស់រយៈពេលបីឆ្នាំ បន្ទាប់មក គាត់បានចាកចេញទៅឈរជើងនៅភ្នំឆត្រ ក្នុងអង្គភាព ក-៥ ហើយបានចូលប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាម ស្ទើរតែគ្មានពេលសម្រាកក្នុងមួយខែៗ ។

ពូ ថាច បន្តថា កាលនៅសមរភូមិប្រយុទ្ធមានកងទ័ពខ្មែរក្រហមជាច្រើនបានជាន់មីនស្លាប់ និងពិការដោយសារនៅអង្គភាព ក-៥ សំបូរទៅដោយមីន ដែលបានដាក់ជាច្រើនសម័យកាលកន្លងមក ។ ក្នុងឆ្នាំ១៩៩៧ ពូ ថាច បានទៅរស់នៅក្នុងតំបន់អន្លង់វែង ដោយកាលនោះ តំបន់អន្លង់វែងត្រូវបានរៀបចំ និងបង្កើតឲ្យមានភូមិឃុំសម្រាប់ប្រជាជនរស់នៅ ។

នៅក្នុងឆ្នាំ១៩៩៨ ពេលដែលខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ពូ ថាច ក៏បានចូលបម្រើកងទ័ពរាជរដ្ឋាភិបាល រហូតដល់ឆ្នាំ២០០៨ ទើបគាត់សម្រេចចិត្តលាឈប់ពីអង្គភាពយោធា ។ ក្រោយសមាហរណកម្មបានពីរឆ្នាំ ពូ ថាច បាននាំប្រពន្ធកូនទៅលេងស្រុកកំណើតរបស់គាត់ ហើយបានជួបបងស្រីគាត់តែម្នាក់ប៉ុណ្ណោះ ។ ពូ ថាច ស្នាក់នៅជាមួយបងស្រីបានមួយរយៈពេលខ្លី ដោយយល់ឃើញថាមិនអាចរស់នៅ និងប្រកបរបររកស៊ីនៅស្រុកកំណើតបានគាត់សម្រេចចិត្តវិលត្រឡប់មករស់នៅក្នុងស្រុកអន្លង់វែងវិញ ដោយប្រកបរបរធ្វើស្រែចម្ការរហូតដល់សព្វថ្ងៃ ។

**ហូ ថុនា**



ផ្ទះរបស់ យស់ ថាច នៅភូមិថ្មី ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

# បទពិសោធដំបូងរបស់ខ្ញុំនៅក្នុងទឹកដីតំបន់ប្រវត្តិសាស្ត្រអន្លង់វែង

កាលពីដំបូង ខ្ញុំធ្លាប់បានយល់ដឹងអំពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែងតាមរយៈការអានសៀវភៅ "ប្រវត្តិសាស្ត្រសហគមន៍អន្លង់វែង" និងការសិក្សាស្រាវជ្រាវតាមឯកសារផ្សេងៗ ។ តំបន់អន្លង់វែង គឺជាតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហម ហើយសព្វថ្ងៃប្រជាជនដែលរស់នៅក្នុងតំបន់នេះភាគច្រើនគឺជាអតីតយោធាខ្មែរក្រហម និងក្រុមគ្រួសារខ្មែរក្រហម ។ មិនត្រឹមតែប៉ុណ្ណោះ ខ្ញុំក៏ធ្លាប់បានឮថា តំបន់អន្លង់វែង គឺជាតំបន់ដាច់ស្រយាលគ្មានប្រជាជនរស់នៅច្រើនទេ ។ ខ្ញុំតែងតែសញ្ជឹងគិតអំពីតំបន់នេះថា គឺជាតំបន់ដែលពិបាករស់នៅសម្រាប់ខ្ញុំ ។

ស្របពេលនេះដែរ ខ្ញុំក៏មានឱកាសមកដល់តំបន់ប្រវត្តិសាស្ត្រអន្លង់វែង ក្នុងគោលបំណងរៀនអំពីកិច្ចការសម្ភាសន៍ប្រជាជនដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ឬអតីតយោធាខ្មែរក្រហមដែលមានរយៈពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃទី១៦-២២ ខែកុម្ភៈ ឆ្នាំ២០១៨ ។ នាពេលព្រឹកថ្ងៃទី១៧ ក្នុងខែឆ្នាំដដែល ខ្ញុំបានចេញពីកន្លែងស្នាក់នៅទៅរកអតីតយោធាខ្មែរក្រហមដើម្បីសាកសួរគាត់ អំពីបទពិសោធន៍តស៊ូរបស់គាត់ក្នុងអំឡុងពេលប្រទេសមានសង្គ្រាមពីសម័យកាលមួយទៅសម័យកាលមួយ ។ នៅពេលនោះដែរ ខ្ញុំបានធ្វើដំណើរចេញពីកន្លែងស្នាក់នៅចម្ងាយប្រហែលមួយគីឡូម៉ែត្រ ក៏បានជួបអតីតយោធាខ្មែរក្រហមម្នាក់ដែលពិការជើងឆ្វេង ។ គាត់កំពុងអង្គុយកើបធ្យូងដាក់បាវ ទុកសម្រាប់ដុតដាំ



ផ្លូវនៅមុខផ្ទះរបស់ ថុនា អ្នកសរសេរទស្សនាវដ្តីស្វែងរកការពិតស្នាក់នៅ ស្ថិតក្នុងភូមិកណ្តាលក្រោម ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។



ស៊ុម ហុង នៅផ្ទះរបស់គាត់ ស្ថិតនៅក្នុងឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

បាយ និងចម្អិនម្ហូបអាហារ ។ ខ្ញុំបានជម្រាបសួរគាត់ និងបានណែនាំខ្លួនខ្ញុំ ។ បន្ទាប់មក ខ្ញុំបានសាកសួរគាត់អំពីសុខទុក្ខ និងពិការភាពរបស់គាត់ថាតើបណ្ដាលមកពីមូលហេតុអ្វី ។ ពេលនោះគាត់ បានឆ្លើយតបមកខ្ញុំវិញទាំងទឹកមុខស្រពោនថា ដោយសារគាត់ទៅសមរភូមិប្រយុទ្ធគ្នាជាមួយកងទ័ពវៀតណាម ។ បន្ទាប់ពីជជែកជាមួយគាត់មួយរយៈខ្លី ខ្ញុំក៏ឆ្លៀតពេលសុំអនុញ្ញាតសម្ភាសគាត់អំពីជីវិតរស់នៅរបស់គាត់ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ហើយគាត់ក៏ព្រមទទួលនូវសំណើររបស់ខ្ញុំ ។

លោកពូមានឈ្មោះ ស៊ុម ហុង អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅភូមិព្រៃកក្តាម ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល ។ ពូ ហុង មានឪពុកឈ្មោះ យិប ហ៊ីវ និងម្ដាយឈ្មោះ ចិត្រ ឡាំ (ឪពុកម្ដាយរបស់គាត់បានស្លាប់ក្នុងសម័យខ្មែរក្រហម) ព្រមទាំងមានបងប្អូនបង្កើត៧នាក់ ។ សព្វថ្ងៃ ពូ ហុង និងប្រពន្ធកូន រស់នៅក្នុងភូមិកណ្ដាលក្រោម ឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ពូហុង មានវ័យ១២ឆ្នាំ ត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តសៀមរាប ហើយក៏ពេលដែលគាត់ព្រាត់ប្រាស់ឪពុកម្ដាយបងប្អូនតាំងពីពេលនោះមកដែរ ។ ពេលទៅដល់សៀមរាបដំបូង ពូ ហុង ត្រូវបានអង្គការចាត់តាំងគាត់ឲ្យធ្វើការក្នុងកងចល័តកុមារ ដោយមានបែងចែកជាច្រើនក្រុម ហើយក្នុងមួយក្រុមៗមានកុមារ១២នាក់ ។ អង្គការបានប្រគល់ភារកិច្ចប្រចាំថ្ងៃឲ្យ ពូ ហុង ធ្វើដោយកាប់ដើមទន្រ្ទានខេត្រ រើសអាចម៍គោ ដើម្បីធ្វើជីដាក់ស្រែ ។

ពូ ហុង បានរៀបរាប់ទាំងអួលដើមកថា គាត់បែកពីឪពុកម្ដាយតាំងតែពីអាយុ១២ឆ្នាំ ហើយប្រសិនបើគាត់ជួបឪពុកម្ដាយគាត់នៅតាមផ្លូវសព្វថ្ងៃ ក៏គាត់មិនអាចចំណាំមុខមាត់ឪពុកម្ដាយរបស់គាត់បានដែរ ។ ជួនកាល ពូ ហុង មានអារម្មណ៍តូចចិត្តនឹងខ្លួនឯងថាហេតុអ្វីបានជាគាត់មិនមានឪពុកម្ដាយ ហៅដូចអ្នកដទៃ គឺដោយសារតែសង្គ្រាមទើបធ្វើឲ្យគាត់បាត់បង់មនុស្សជាទីស្រឡាញ់ជុំវិញខ្លួន ។ ពូ ហុង បន្តថា ក្នុងអំឡុងពេលនោះគាត់មិនដែលបានស្គាល់រសជាតិបាយ ឬម្ហូបឆ្ងាញ់នោះទេ គឺគាត់បានស្គាល់ត្រឹមតែបបរាវកន្ទះកា ក្នុងមួយពេលៗប៉ុណ្ណោះ ។ ទោះបីជាលំបាកយ៉ាងនេះក្ដី ក៏ពូ ហុង មិនដែលគិតចង់រត់ចេញពីកងរបស់គាត់ដែរ ដោយសារគាត់យល់ថា ប្រសិនបើគាត់រត់ចេញច្បាស់ជាមិនអាចគេចផុតពីសេចក្ដីស្លាប់ទេ ។ ពូ ហុង ធ្វើការទាំងស៊ូទ្រាំលំបាកសព្វគ្រប់បែបយ៉ាង រហូតដល់កងទ័ពវៀតណាមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ ។

នៅក្នុងឆ្នាំ១៩៧៩ ពូ ហុង បានរត់គេចខ្លួនទៅតំបន់អន្លង់វែង ហើយបានចូលបម្រើជាយោធាខ្មែរក្រហម ។ មួយឆ្នាំក្រោយមក ពូ ហុង ត្រូវបានថ្នាក់លើចាត់តាំងឲ្យធ្វើការក្នុងកងដឹកជញ្ជូនគ្រាប់ទៅសមរភូមិប្រយុទ្ធ ។ រហូតដល់ឆ្នាំ១៩៨៧ ពូ ហុង បានចូលសមរភូមិប្រយុទ្ធជាមួយកងទ័ពវៀតណាម នៅលើភ្នំដងរែក ហើយពេលនោះក៏បានជាន់មីនទើបធ្វើឲ្យគាត់បាត់បង់ជើងឆ្វេងម្ខាងរហូតមកដល់សព្វថ្ងៃ ។ ក្រោយមក ពូ ហុង ត្រូវបានថ្នាក់លើដកមកសមរភូមិក្រោយវិញ ដោយឲ្យធ្វើជាប្រធានគុកនៅលើភ្នំដងរែក (គុកមិនមានឈ្មោះ) ។ កាលដែលធ្វើជាប្រធានគុក ពូ ហុង មានតួនាទីចាប់ក្រុមសេរី ដោយសំដៅទៅលើអ្នកលួចក្បាលអ្នកតាលក់គ្រឿងអាវុធ ឬដួញដូរសម្ភារពីខាងក្នុងមកលក់នៅក្នុងតំបន់ខ្មែរក្រហម ។ អ្នកទាំងនេះ ត្រូវបានចាប់ដាក់គុក និងត្រូវបានចោទ

ថា ជាខ្លាំង ។

រហូតដល់ឆ្នាំ១៩៩៧ ថ្នាក់លើបានរៀបចំឲ្យ ពូ ហុង រៀបការ ហើយពេលនោះគាត់ក៏មិនហ៊ានប្រកែកតវ៉ាដែរ ដោយគាត់យល់ថា គាត់ក៏ជាអ្នកគោរពវិន័យម្នាក់ដែរ ។ ដូច្នេះទោះបីជាថ្នាក់លើឲ្យគាត់ធ្វើអ្វីក៏គាត់ព្រមដែរ ដើម្បីកុំឲ្យល្មើសនឹងវិន័យ ។ នៅឆ្នាំ១៩៩៨ ខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ពេលនោះ ពូ ហុង សប្បាយរីករាយខ្លាំងណាស់ ព្រោះគាត់យល់ថា ស្រុកទេសមានការបង្រួបបង្រួមជាតិ និងមានសុខសន្តិភាព ហើយប្រជាជនមានសិទ្ធិសេរីភាពពេញបរិបូរណ៍ និងមានការអភិវឌ្ឍទៅថ្ងៃខាងមុខ ។ ក្រោយសមាហរណកម្មពីរឆ្នាំ ពូ ហុង បានទៅសួរសុខទុក្ខឪពុកម្តាយ និងបងប្អូននៅស្រុកកំណើត ប៉ុន្តែពេលនោះ គាត់មិនបានជួបសាច់ញាតិណាម្នាក់ឡើយ រីឯផ្ទះរបស់គាត់ក៏ត្រូវបានប្រជាជនដទៃទៀតរស់នៅដែរ ។ ដូច្នេះហើយទើបពូ ហុង និងប្រពន្ធកូនបានសម្រេចចិត្តមករស់នៅក្នុងស្រុកអន្លង់វែង រហូតមកដល់សព្វថ្ងៃនេះ ។

តាមរយៈរឿងរ៉ាវរបស់ ពូ ហុង បានធ្វើឲ្យខ្ញុំយល់ដឹងពីបទពិសោធជីវិតបែកបាក់ បងប្អូន ឪពុកម្តាយ ភូមិកំណើតតាំងពីនៅកុមារក្នុងអំឡុងរបបខ្មែរក្រហម ការអត់ឃ្លាន ការរត់គៀសខ្លួនពីសង្គ្រាម និងការចូលរួមជាមួយយោធាខ្មែរក្រហមនៅអន្លង់វែង រហូតដល់គាត់ពិការជើងម្ខាង ។ រឿងរ៉ាវជីវិតរបស់ ពូ ហុង នឹងក្លាយជាមេរៀនដំបូងសម្រាប់ខ្ញុំដែលត្រូវស្វែងយល់ និងសិក្សាពីរបបខ្មែរក្រហមនៅអន្លង់វែងនេះ ។

នៅអំឡុងពេលដែលខ្ញុំស្នាក់នៅតំបន់អន្លង់វែងមួយរយៈពេលខ្លីនេះ ខ្ញុំក៏សង្កេតឃើញថាប្រជាជនដែលរស់នៅក្នុងតំបន់នេះមានភាពស្និទ្ធស្នាលរួសរាយរាក់ទាក់ ទោះបីប្រជាជនទាំងនេះដឹងថាខ្ញុំជាអ្នកចម្ងាយក៏ដោយ ។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាជនដែលធ្លាប់ជាអតីតយោធាខ្មែរក្រហម តែងតែនិយាយមកកាន់ខ្ញុំដោយទឹកមុខរីករាយជានិច្ច ។ ខ្ញុំយល់ថាអតីតខ្មែរក្រហមទាំងនេះក៏ជាប្រជាជនធម្មតាដូចជាប្រជាជនដទៃទៀតដែរ ហើយអ្វីដែលខ្ញុំកត់សម្គាល់ គឺមានប្រជាជនមកពីតំបន់ផ្សេងៗ និងស្ទើរតែគ្រប់ខេត្តនៃប្រទេសកម្ពុជា បានចូលមករស់នៅ និងរកស៊ីនៅក្នុងតំបន់អន្លង់វែង ។ បន្ទាប់ពីខ្ញុំបានមកដល់ និងបានឃើញតំបន់អន្លង់វែងផ្ទាល់ ទើបខ្ញុំយល់កាន់តែច្បាស់ថា អ្វីដែលខ្ញុំធ្លាប់បានគិតកន្លងមក គឺវាផ្ទុយនឹងស្ថានភាពជាក់ស្តែងនៅតំបន់នេះ ។ **ហ៊ូ ថុនា**



ផ្ទះរបស់ប្រជាជននៅឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

# អ៊ិន លន មានទោសប្រហារជីវិតដោយសារដេកលក់ជ្រុល ម៉ោងខកខានក្នុងការចូលរួមប្រជុំមហាសន្និបាតអង្គការ សហប្រជាជាតិស្តីអំពីជម្លោះសាហារ៉ា ប៉ែកខាងលិច នៅឆ្នាំ១៩៧៨

អ៊ិន លន ត្រូវបានឃាត់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ បន្ទាប់ពីវិញត្រឡប់ពីការចូលរួមប្រជុំមហាសន្និបាតអង្គការសហប្រជាជាតិនៅចុងខែធ្នូ ឆ្នាំ១៩៧៨ ។ ការចាប់ខ្លួន និងសម្លាប់ អ៊ិន លន នេះគឺដោយសារការដេកលក់ជ្រុលម៉ោងមិនបានបោះឆ្នោតគាំទ្រប្រទេសអាល់ហ្សេរីនៅមហាសន្និបាតអង្គការសហប្រជាជាតិស្តីអំពីជម្លោះសាហារ៉ាភាគខាងលិច ។

អ៊ិន លន មានឈ្មោះបដិវត្តន៍ថា តាណាគ និងមានស្រុកកំណើតនៅភូមិអន្លង់តាសេក ឃុំព្រែកអំបិល ស្រុក២០ តំបន់២៥ ។


ប្រវត្តិរូបអ្នកទោស[illegible]
លេខរៀង :
[illegible] :
មកពី :
១- ឈ្មោះដើម អ៊ិន. លន ឈ្មោះបដិវត្តន៍ ណាគ.
២- អាយុ [illegible] ឆ្នាំ ភេទ ប្រុស ជនជាតិ ខ្មែរ.
៣- [illegible]
៤- កើតនៅភូមិ អន្លង់តាសេក ឃុំ ព្រែកអំបិល ស្រុក ២០ តំបន់២៥.
៥- ឪពុកឈ្មោះ [illegible] ម្ដាយឈ្មោះ [illegible]
៦- [illegible]
៧- ប្ដី ឬ ប្រពន្ធ ឈ្មោះដើម [illegible] ឈ្មោះបដិវត្តន៍ [illegible]
៨- កើតនៅភូមិ [illegible] ឃុំ ស្រុក តំបន់ [illegible]
៩- [illegible]
១០- មានកូនប្រុសចំនួន ១ នាក់ កូនស្រី នាក់
១១- [illegible]
១២- ចាប់ខ្លួន ថ្ងៃទី [illegible] ខែ ១២ ឆ្នាំ ១៩៧៨
ភិនភាគ
កំពស់ :
[illegible] :

អ៊ិន លន មានប្រពន្ធឈ្មោះ អ៊ា ទីម ហៅ គុន និងមានកូនប្រុសម្នាក់ ។ នៅមុនឆ្នាំ១៩៧៥ អ៊ិន លន មាននាទីជាលេខាកងពល១២ ប្រចាំភូមិភាគពិសេស ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងឲ្យ អ៊ិន លន ធ្វើជាប្រធានមន្ទីរសន្តិសុខស-២១ រហូតដល់ដើមឆ្នាំ១៩៧៦ ទើបខ្មែរក្រហមផ្លាស់ អ៊ិន លន មកទទួលជាកម្មាភិបាលជំនួយនៅមន្ទីរអគ្គសេនាធិការកងទ័ព ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានបន្តផ្លាស់ អ៊ិន លន មកធ្វើការនៅក្រសួងការបរទេស (ប១) ផ្នែកកិច្ចការនយោបាយ ។ នៅខណៈពេលនោះ អ៊ិន លន ក៏ជាបេក្ខជនត្រៀមសម្រាប់ទទួលតំណែងជាឯកអគ្គរដ្ឋទូតរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប្រចាំនៅអង្គការសហប្រជាជាតិដែរ ។

នៅចុងឆ្នាំ១៩៧៨ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនគណៈប្រតិភូរបស់ខ្លួនចំនួនបីរូបរួមមាន អ៊ិន លន ជាប្រធានគណប្រតិភូ និងមានសមាជិក២រូបទៀត ទៅចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិនៅបូរីញូវយ៉ក ដើម្បីបោះឆ្នោតគាំទ្រប្រទេសអាល់ហ្សេរីស្តីអំពីជម្លោះសាហារ៉ាប៉ែកខាងលិច "ជម្លោះសាហារ៉ាប៉ែកខាងលិច គឺជាជម្លោះដណ្តើមទឹកដីរវាងប្រទេសម៉ារ៉ុក និងរណសិរ្សប៉ូលីសារីយ៉ូ *(Polisario Front)* ដែលមានប្រទេសអាល់ហ្សេរីជាតំណាងការប្រជុំបោះឆ្នោតនៅមហាសន្និបាតអង្គការសហប្រជាជាតិ" ។ នៅខណៈពេលដែលមហាសន្និបាតអង្គការសហប្រជាជាតិបានចាប់ផ្តើមប្រជុំ អ៊ិន លន ដែលជាប្រធានគណៈប្រតិភូកម្ពុជាប្រជាធិបតេយ្យបានបាត់ខ្លួនពីអង្គប្រជុំនៅសល់តែសមាជិកគណៈប្រតិភូពីររូបទៀតប៉ុណ្ណោះ ។ ការអវត្តមាន អ៊ិន លន

នេះបានបណ្តាលឲ្យសមាជិកគណៈប្រតិភូទាំងពីររូបមិនហ៊ានសម្រេចក្នុងការបុចប៊ីតុងគាំទ្រប្រទេសអាល់ហ្សេរី ។ ដូច្នេះកម្ពុជាប្រជាធិបតេយ្យបានខកខានក្នុងការបោះឆ្នោតគាំទ្រអាល់ហ្សេរីនៅមហាសន្និបាតអង្គការសហប្រជាជាតិស្តីអំពីជម្លោះនេះ ។ ការខកខាននេះបានធ្វើឲ្យប្រទេសអាល់ហ្សេរីមានអាក់អន់ចិត្តយ៉ាងខ្លាំង ពីព្រោះប្រទេសអាល់ហ្សេរីបានចូលរួមគាំទ្រចលនាខ្មែរក្រហម និងរណសិរ្សរួបរួមជាតិកម្ពុជា តាំងពីអំឡុងសង្គ្រាមស៊ីវិលចន្លោះឆ្នាំ១៩៧០-១៩៧៥ មកម្ល៉េះ ហើយនេះជាលើកទីមួយដែលប្រទេសអាល់ហ្សេរីពឹងពាក់កម្ពុជាប្រជាធិបតេយ្យឲ្យជួយគាំទ្រខ្លួនវិញ ។

បន្ទាប់ពីការបោះឆ្នោតមហាសន្និបាតអង្គការសហប្រជាជាតិត្រូវបានបញ្ចប់ ទើបសមាជិកទាំង២រូបបានជួបជាមួយ អ៊ិន លន ដែលជាប្រធានរបស់ខ្លួននៅខាងក្រៅអង្គប្រជុំ ។ នៅខណៈពេលនោះ អ៊ិន លន បានបកស្រាយអំពីមូលហេតុដែលអវត្តមាននេះថា ដោយសារតែម៉ោងខុសគ្នារវាងប្រទេសកម្ពុជា និងបុរីញូវយ៉ករហូតទៅដល់១២ម៉ោង (ប្រទេសកម្ពុជាលឿនជាងប្រមាណ១២ម៉ោង) បានធ្វើឲ្យខ្លួនអស់កម្លាំង និងនឿយហត់ខ្លាំង ក៏បានដើរទៅរកកន្លែងសម្រាកនៅលើកៅអីវែងមួយក្នុងបរិវេណអគារអង្គការសហប្រជាជាតិរហូតដល់ដេកលក់ខកខានមិនបានចូលរួមប្រជុំបោះឆ្នោតនេះ ។

នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមិនមានស្ថានទូត និងឯកអគ្គរដ្ឋទូតប្រចាំនៅអង្គការសហប្រជាជាតិទេ ។ បើតាម សួង ស៊ីគឿន អតីតបញ្ញាជនដែលបម្រើការផ្នែកឃោសនាការ និងព័ត៌មាននៅក្រសួងការបរទេសនៃរដ្ឋាភិបាលកម្ពុជាប្រធិបតេយ្យ បានឲ្យដឹងថា មេដឹកនាំនៃរបបខ្មែរក្រហមបានកំណត់កម្មាភិបាលមូលដ្ឋានដែលមានតួនាទីជាគណៈតំបន់ ឬកងពល ទើបត្រូវបានពិចារណាឲ្យកាន់ដំណែងជាឯកអគ្គរដ្ឋទូតប្រចាំនៅតាមប្រទេសផ្សេងៗបាន ។ ចំណែកក្រុមបញ្ញាជនដែលបម្រើការនៅក្រសួងការបរទេស ឬតាមក្រសួងមន្ទីរផ្សេងៗ ទោះជាមានចំណេះដឹងជ្រៅជ្រះទាំងបច្ចេកទេស និងភាសាបរទេសក៏ដោយ ក៏មិនត្រូវបានពិចារណាសម្រាប់តួនាទីជាឯកអគ្គរដ្ឋទូតតំណាងឲ្យកម្ពុជាធិបតេយ្យឡើយ ពីព្រោះបញ្ញាជនមិនត្រូវបានធានាផ្នែកវណ្ណៈភាព ។

**ឡុង ដានី**


គណៈប្រភូក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ទទួលគណៈប្រតិភូបរទេស នៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង ។

# អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការបិទបញ្ចប់សវនាការសួរដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*(តពីលេខមុន)*

## *ការឈ្លានពាន និងការសហការណ៍ជាមួយវៀតណាម*

មេធាវី កុប៉េ បានចាប់ផ្តើមដោយរំឭកអំពីការគំរាមកំហែងរបស់វៀតណាមមកកាន់កម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងសេចក្តីសង្ខេបមួយនេះ ភាគីដើមចោទបានព្យាយាមពណ៌នាថា នួន ជា គឺជាមនុស្សប្រកាន់ពូជសាសន៍ ដោយសារទង្វើស្អប់ខ្ពើម និងភាពមិនពេញចិត្តរបស់គាត់ទៅលើវៀតណាម ហើយគាត់ក៏បានលុកលុយទឹកដីវៀតណាមវិញជាការសងសឹក ។ ភាគីដើមចោទបានបញ្ជាក់ថា កងទ័ពរបស់កម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបោកបញ្ឆោតកងទ័ពវៀតណាម ដោយបានលើកហេតុផលចរចាជាស្ពានឈានទៅរកការឈ្លានពាននាថ្ងៃខាងមុខ ។

មេធាវី កុប៉េ បានបន្ថែមថា ភាគីដើមចោទ បានពណ៌នាបក្សកុម្មុយនីស្តកម្ពុជាថា ជាមនុស្សដែលមានជំងឺសរសៃប្រសាទ និងខ្វះភាពពិចារណា ពីព្រោះភាគីដើមចោទបានញុះញង់ឲ្យមានការតតាំងរវាងវៀតណាម និង ប៉ុល ពត ។ ក្រុមដែលនៅក្រោមចំណុះបានធ្វើសកម្មភាពប្រៀបបីដូចជាខ្លួនបានទទួលរងនូវការគំរាមកំហែងអំពីវៀតណាម ។ ផ្ទុយទៅវិញ ភាគីដើមចោទបែរជាយល់ឃើញថា វៀតណាមគឺជាអ្នកស្នេហាសន្តិភាព មិនឆេវឆាវ ជាអ្នកជិតខាងមួយដែលមានភាពអត់ធ្មត់ មិនដែលមានចិត្តចង់ធ្វើជាសត្រូវ ហើយមានចិត្តព្យាយាមដោះស្រាយបញ្ហាដោយសុខសន្តិភាព ដោយតែងតែលើកវប្បធម៌ចរចាមកប្រើប្រាស់ក្នុងនយោបាយ ។




មេធាវីចុងចោទបានវែកញែកផ្ទុយពីនេះថា វៀតណាមគឺជាចក្រពត្តិនិយមដែលមានចិត្តឈ្លានពាន និងជាមនុស្សតំណាងឲ្យសហភាពសូវៀត ។ មេធាវីចុងចោទមានភ័ស្តុតាងដែលអាចបញ្ជាក់ថា វៀតណាមបានឈ្លានពាន និងព្យាយាមកាន់កាប់ប្រទេសកម្ពុជាអស់រយៈពេលជាង១០ឆ្នាំមកហើយ ។

មេធាវី កុប៉េ បាននិយាយម្តងទៀតថា រឿងប្រឌិតមួយនេះបានកើតឡើងដោយសារការឃោសនារបស់វៀតណាម ដោយបានព្យាយាមបង្ហាញថា វត្តមានរបស់វៀតណាមនៅប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺធ្វើឡើងដោយស្របច្បាប់ ។ មេធាវីចុងចោទបានបន្ថែមថា អង្គចៅក្រមក៏យល់ស្របចំពោះទស្សនៈខាងលើនេះដែរ ។ តែអង្គចៅក្រមហាក់បីដូចជាមានគំនិតសង្ស័យទៅកាន់វៀតណាមចំពោះវត្តមានរបស់វៀតណាមមកកាន់ប្រទេសកម្ពុជា នាសម័យកម្ពុជាប្រជាធិបតេយ្យ បើយោងទៅតាមរឿងក្តីលេខ ០០២/០១ ។

បក្សកុម្មុយនីស្តកម្ពុជា មិនមែនជាបុគ្គលតែមួយដែលបានកត់សម្គាល់នូវការគំរាមកំហែងផ្ទៃក្នុងរបស់វៀតណាមមកកាន់ប្រទេសកម្ពុជានោះទេ ។ នាឆ្នាំ១៩៦៤ ព្រះបាទ នរោត្តម សីហនុ

មានព្រះបន្ទូលថា គ្មានអ្នកដឹកនាំជនជាតិវៀតណាមណាម្នាក់អាចដេកលក់ស្រួល ខណៈពេលដែលប្រទេសកម្ពុជាមិនទាន់បានកម្ទេចចោល ឬពុំទាន់អាចយកប្រទេសកម្ពុជាជាទាសកររបស់ខ្លួនបានមកវិញនោះទេ ។ ព្រះអង្គមានព្រះបន្ទូលអំពីរឿងនេះជាច្រើនដងជាច្រើនសារ ។ ភាគីដើមចោទ មិនបានអើពើនូវរឿងហេតុដែលវៀតណាមចង់បានប្រទេសកម្ពុជាកាលពីជាង១.០០០ឆ្នាំមុននោះទេ ។ វៀតណាមបានបំពេញក្តីស្រមៃមួយនេះ ដោយបញ្ចូលឧបសម្ព័ន្ធមកលើទឹកដីកម្ពុជា សកម្មភាពមួយនេះគឺដូចទៅនឹងទង្វើដែលខ្លួនបានធ្វើទៅលើប្រទេសចម្ប៉ា កម្ពុជាក្រោម និងកំពុងតែព្យាយាមពង្រីកទឹកដីរបស់ខ្លួនទៅកាន់សមុទ្រចិនខាងត្បូង ។

មេធាវី កុប៉េ បានថ្លែងទៀតថា វៀតណាមមានបំណងបង្កើតសហព័ន្ធឥណ្ឌូចិនដោយមានគំនិតចង់បញ្ចូលប្រទេសកម្ពុជា ប្រទេសឡាវ និងប្រទេសវៀតណាមរួមគ្នា ដោយបានចាត់ទុកថា ប្រទេសឡាវ និងប្រទេសកម្ពុជា ជារដ្ឋទាសភាព ។ ភ័ស្តុតាងមួយក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ បានបញ្ជាក់យ៉ាងច្បាស់ថា វៀតណាមមានគំនិតចង់បង្កើតនូវសហព័ន្ធដែលបានលើកឡើងខាងលើនេះ ។ មេដឹកនាំវៀតណាមបានថ្លែងថា ខ្មែរនឹងមិនមានជម្រើសផ្សេងនោះទេ ខណៈដែលប្រទេសខ្លួនបានធ្លាក់ក្នុងកណ្តាប់ដៃរបស់វៀតណាម ។ ការសុំចរចាអំពីសំណាក់មេដឹកនាំ ត្រូវបានលើកឡើងនាសម័យកម្ពុជាប្រជាធិបតេយ្យខណៈដែលប្រទេសកម្ពុជាត្រូវបានវៀតណាមលុកលុយជាច្រើនលើកច្រើនសារ ។ សូម្បីតែកាសែតដ៏ល្បីមួយឈ្មោះ ញូវយ៉កថែម ក៏បានរាយការណ៍ថា វៀតណាមចង់ក្លាយជាអធិរាជនៅតំបន់នេះនៅក្នុងសម័យនោះ ។

សន្និសញ្ញាបានបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជា និងវៀតណាមខាងជើង គឺជាសម្ព័ន្ធមិត្តនឹងគ្នា ប៉ុន្តែការពិតគឺមានសភាពផ្ទុយពីនេះទៅវិញ ពីព្រោះកម្ពុជានាសម័យនោះ ត្រូវបានមិត្តរួមសម្ព័ន្ធក្បត់ ។ នួន ជា បាននិយាយថា ទង្វើដែលមិនគួរគប្បីរបស់វៀតណាម គឺពេលដែលវៀតណាមបានបង្ខំឲ្យព្រះបាទ សម្តេចព្រះនរោត្តម សីហនុ និងបក្សកុម្មុយនីស្តកម្ពុជាធ្វើការចរចាជាមួយក្រុមសាធារណៈរដ្ឋខ្មែរ ។ ការស្នើសុំមួយនេះត្រូវបានច្រានចោលដែលជាហេតុបង្កឲ្យមានការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិកមកលើទឹកដីកម្ពុជា ។

អាមេរិកបានទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជាប្រមាណ ២០០ថ្ងៃដើម្បីជាការដាក់ទោស ។ ក្នុងពេលនោះដែរ ប្រហែល ៣០ ទៅ៤០ភាគរយនៃចំនួនប្រជាជនសរុប បានស្លាប់ខណៈពេលជម្លៀស ។ មេធាវី កុប៉េ បានថ្លែងថា សាក្សីក៏បានផ្តល់ភ័ស្តុតាងចំពោះការប៉ះទង្គិចរវាង វៀតណាម វៀតកុង និងបក្សកុម្មុយនីស្តកម្ពុជា ។ ក្នុងពេលនោះដែរ វៀតណាមបានលួចគ្រឿងសព្វាវុធពី



រូបខាងស្តាំ ៖ មេធាវីការពារក្តី នួន ជា វិចទ័រ កុប៉េ នៅក្នុងសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

ប្រទេសកម្ពុជា និងបានត្រួសត្រាយផ្លូវដើម្បីបង្កើតសហព័ន្ធឥណ្ឌូចិន ។ រីឯក្រុមកុម្មុយនីស្តកម្ពុជា ត្រូវបានគេប្រគល់សិទ្ធិជ្រកកោន នៅទីក្រុងហាណូយ នាឆ្នាំ១៩៥៥ ។

ភាគីដើមចោទ បានចោទប្រកាន់ក្រុមសហការណ៍ផ្ទៃក្នុងថាជាខ្មាំង នៅក្នុងសេចក្តីសង្ខេបបណ្តឹងរបស់ខ្លួន ។ អ្នកសហការណ៍ផ្ទៃក្នុងទាំងនោះតែងតែទាក់ទងជាមួយទាហានរបស់បក្សកុម្មុយនីស្តកម្ពុជា និងវៀតណាម ។ ទាហានរបស់បក្សកុម្មុយនីស្តកម្ពុជា និងវៀតណាម តែងតែបញ្ជូនព័ត៌មានដែលខ្លួនទទួលបានទៅកាន់ក្រុមវៀតណាម តែមិនដែលផ្ញើមកកាន់មិត្តកម្ពុជានោះទេ ។

មេធាវី កុប៉េ បានបន្ថែមទៀតថា នៅចន្លោះឆ្នាំ១៩៦០-១៩៧៩ វៀតណាមបានប្រើប្រាស់នូវល្បិចកលយ៉ាងសាហាវដើម្បីបំផ្លាញបដិវត្តន៍ ក៏ដូចជាបំផ្លាញការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ។ ទង្វើមួយនេះបានធ្វើឡើងដោយប្រើប្រាស់នូវល្បិចចរចាបញ្ឆោត និងដើម្បីផ្លាស់ប្តូរទស្សនរបស់សាធារណជន ។ ឧទាហរណ៍នាឆ្នាំ១៩៧៦ វៀតណាមមិនបានរក្សានូវពាក្យសន្យាដែលខ្លួនបាននិយាយនាឆ្នាំ១៩៦៧ នោះទេ ។ ការសន្យានោះបានចែងថាខ្លួននឹងគោរពនូវបន្ទាត់ព្រំដែនរវាងប្រទេស និងប្រទេស នៅពេលដែលប្រទេសកម្ពុជារកឃើញរ៉ែប្រេងកាត ។ ឧទាហរណ៍ទី២ គឺការព្រមព្រៀងបញ្ចប់សង្គ្រាមជាមួយប្រទេសកម្ពុជា ។ វៀតណាមបាននិយាយថា រឿងរ៉ាវមួយនេះ គឺបង្កឡើងដោយជនដែលមកពីបក្សកុម្មុយនីស្តកម្ពុជា ឬក្រុមមនុស្សដែលស្ថិតនៅក្រោមការកាន់កាប់របស់របបកម្ពុជាប្រជាធិបតេយ្យ ។ វៀតណាមបានលើកបណ្តឹងមួយថា កម្ពុជាគឺជាភាគីដែលបានលុកលុយមកលើប្រទេសវៀតណាមមុន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយយោងទៅតាមទង្វើនេះហើយទើបខ្លួនមានគម្រោងវាយបកមកកាន់ប្រទេសកម្ពុជាវិញ ។

មេធាវី កុប៉េ បានបន្ថែមទៀតថា គោលនយោបាយជាតិត្រូវបានផ្លាស់ប្តូរខណៈពេលដែលរដ្ឋាភិបាលនាសម័យកម្ពុជាប្រជាធិបតេយ្យ បានប្រកាស់ប្រទេសទៅជារដ្ឋក្នុងសភាពអាសន្ន ។ រឿងនេះត្រូវបានប្រកាសនៅពេលដែលកម្ពុជាត្រូវបានលុកលុយក៏ដូចជាគំរាមកំហែងពីសំណាក់វៀតណាម ។ ការសហការណ៍ផ្ទៃក្នុងត្រូវបានពង្រឹង ដើម្បីឲ្យមានការអភិវឌ្ឍ និងការពារប្រទេសឲ្យមានស្ថិរភាព ។

វាមិនមែនជារឿងចម្លែកនោះទេ ដែលរដ្ឋាភិបាលកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានខិតខំប្រឹងប្រែង និងពង្រឹងនូវសក្តានុពលរបស់ប្រទេស ។ រដ្ឋាភិបាលបានចងសម្ព័ន្ធមិត្តជាមួយប្រទេសចំនួន១០០ ដើម្បីកាត់បន្ថយនូវការគំរាមកំហែងពីសំណាក់ភាគីវៀតណាម ។ ការភ័ន្តច្រឡំត្រូវបានកើតឡើងចំពោះភាគីដើមចោទ នៅពេលដែលបណ្តាប្រទេសនានានិយាយថា កម្ពុជានាសម័យនោះពិតជាត្រូវបានរងសម្ពាធពីសំណាក់ប្រទេសវៀតណាមពិតមែន ។ មេដឹកនាំប្រទេសចិន បាននិយាយថា វៀតណាមបានគំរាមកំហែងប្រទេសកម្ពុជាតាំងពីមុនពេលកកើតនៃរបបកម្ពុជាប្រជាធិបតេយ្យមកម្ល៉េះ ។ មេធាវីបានបន្តថា វៀតណាមគឺប្រៀបបីដូចជាក្មេងពាលប្រចាំតំបន់ភាគខាងកើតអញ្ចឹង ។

ប្រធានាធិបតីអាមេរិក ឆឺរ៉ល ហ្វដ លោក គីហ្ស៊ីងគ័រ និងប្រធានាធិបតីប្រទេសឥណ្ឌូណេស៊ី បាននិយាយថា នេះពិតជាកង្វល់មួយយ៉ាងធ្ងន់ធ្ងរណាស់ ។ បុគ្គលិកការទូតរបស់ប្រទេសអូស្ត្រាលី បានសម្តែងមតិថា នេះគឺជារឿងមួយដែលគួរឲ្យព្រួយបារម្ភ ជាពិសេសសំរាប់ប្រទេសដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសវៀតណាម ។ វៀតណាមបានទទួលជោគជ័យក្នុងការដាក់អំណាចទៅលើប្រទេសឡាវ នៅឆ្នាំ១៩៧៧ ដោយយោងតាមរូបភាពនៃការចុះសន្ធិសញ្ញាមេត្រីភាព ។ ប្រទេសចិនយល់ឃើញថា ទង្វើនេះមិនមែនជាការចុះសន្ធិសញ្ញាមេត្រីភាពនោះទេ ក៏ប៉ុន្តែវាជាការដាក់អំណាចទៅលើប្រទេសឡាវតែម្តង ។ វៀតណាមក៏បានបង្វែរគោលដៅមកកាន់ប្រទេសកម្ពុជាវិញម្តង បន្ទាប់ពីបានសម្រេចគោលដៅរបស់ខ្លួនលើប្រទេសឡាវ ។

ការវាយប្រហាររវាងកម្ពុជា និងវៀតណាមនាសម័យនោះមិនមែនបង្កឡើងដោយភាគីខាងបក្សកម្ពុជាប្រជាធិបតេយ្យនោះទេ ប៉ុន្តែវាត្រូវបានធ្វើឡើងដោយបុគ្គលផ្សេងទៅវិញ ។ យើងគួរតែកត់សំគាល់ថា របាយការណ៍ទាំងអស់ដែលបានសរសេរដោយយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាមានសារសំខាន់ណាស់ ព្រោះពុំដែលសរសេរបង្វែងនូវព័ត៌មានដែលទាក់ទងនឹងជម្លោះរវាងកងទ័ពបដិវត្តន៍កម្ពុជា និងកងទ័ពវៀតណាមនោះទេ ។ ដោយឡែករបាយការណ៍នៃឆ្នាំ១៩៧៧ ពុំបានបកស្រាយនូវបញ្ហានេះទេ

ព្រោះវាមិនធ្លាប់កើតមានឡើង ។

សាក្សីចំនួនបួនទៅប្រាំនាក់ បាននិយាយថា ការឈ្លានពានរវាងប្រទេសទាំងពីរត្រូវបានចាប់ផ្តើមឡើងដោយភាគីវៀតណាម ។ សាក្សីបានបន្តថា ការឈ្លានពានមកកាន់ប្រទេសកម្ពុជា បានចាប់ផ្តើមពីខែមីនា រហូតដល់ខែឧសភា នាឆ្នាំ១៩៧៧ ហើយសកម្មភាពមួយនេះ ត្រូវបានធ្វើឡើងតាមគ្រប់រូបភាព ។ វៀតណាមតែងតែបង្កើតគម្រោងទុកមុនចំពោះការឈ្លានពានទាំងអស់ ហើយប្រជាជនប្រចាំតំបន់ដែលខ្លួនចង់ឈ្លានពានតែងតែត្រូវបានជម្លៀសចេញ មុននឹងសម្មភាពនេះត្រូវបានចាប់ផ្តើម ។

មេបញ្ជាការនៃកងវរសេនាតូចចំនួនពីរ ដែលជាសាក្សីបានឆ្លើយទៅកាន់ករណី លេខ០០២/០១ នៃការិយាល័យអង្គចៅក្រមថា រាល់ការវាយប្រហារទៅកាន់ប្រជាជនវៀតណាមទាំងអស់ បានធ្វើឡើងតែក្នុងករណីចាំបាច់ប៉ុណ្ណោះ ។ គាត់បានបន្ថែមថា ជនជាតិវៀតណាមត្រូវបានបណ្តេញចេញពីព្រំប្រទល់កម្ពុជា ហើយរាល់ការឆ្លងកាត់នានាពុំត្រូវបានបើកឲ្យចេញចូលជាទូទៅនោះទេ ។

គ្មានចម្លើយពិតប្រាកដណាដែលអាចបញ្ជាក់ថា វៀតណាមគឺជាភាគីដែលបានជួយសង្គ្រោះកម្ពុជា ឬជាភាគីដែលបានឆ្លៀតឱកាសឈ្លានពានប្រទេសកម្ពុជាខណៈដែលប្រទេសស្ថិតនៅក្នុងសភាពអាសន្ននោះទេ ។ ភាគីវៀតណាមបានរៀបចំនូវផែនការយ៉ាងហ្មត់ចត់ និងតឹងរ៉ឹងមុនពេលដែលខ្លួនសម្រេចចិត្តលុកលុយប្រទេសកម្ពុជា ។

មេធាវី កុប៉េ បាននិយាយថា វៀតណាមបានប្រើប្រាស់នូវយុទ្ធសាស្ត្រផ្នែកចិត្តសាស្ត្រ ដើម្បីធ្វើការវាយប្រហារមកលើប្រទេសកម្ពុជា ដែលគោលបំណងធំរបស់ខ្លួន គឺការក្តោបក្តាប់ប្រទេសកម្ពុជានេះឯង ។ នាពេលនោះដែរ ក្រុមវៀតណាមក៏បានចាប់ផ្តើមកេណ្ឌមនុស្សដែលមានមុខងារខ្ពស់មកពីបក្សកម្មុយនីស្តកម្ពុជា ដើម្បីមកធ្វើការឲ្យខ្លួនក្នុងគោលបំណងប្រមូលផ្តុំព័ត៌មានសំខាន់ៗនានាអំពីបក្សកុម្មុយនីស្តកម្ពុជាដើម្បីទម្លាក់រដ្ឋាភិបាលស្របច្បាប់មួយនោះ ។

ស្របពេលដែលនិយាយនូវរឿងហេតុមួយនេះ មេធាវីការពារក្តីបាននិយាយថាយុទ្ធសាស្ត្រទី១របស់វៀតណាម គឺការបញ្ចូលរនុកក្នុង រីឯយុទ្ធសាស្ត្រទី២ គឺការឈ្លានពានប្រទេសនេះឯង ។ យុទ្ធសាស្ត្រទី១ដែលវៀតណាមបានប្រើប្រាស់ គឺមិនបានផ្សព្វផ្សាយឲ្យដឹងទូលំទូលាយនោះទេ ក៏ប៉ុន្តែវាត្រូវបានលើកមកនិយាយបន្តិចម្តងៗ ។ មេធាវីដើមចោទបាននិយាយថា មិនមានភស្តុតាងជាក់លាក់ណាមួយដែលអាចបញ្ជាក់ថា មន្ត្រីជាន់ខ្ពស់ណាមួយរបស់បក្សកុម្មុយនីស្តកម្ពុជា បានប្រព្រឹត្តនូវអំពើក្បត់ទៅកាន់មេដឹកនាំរបស់ខ្លួននោះទេ ។ ក្នុងនាមយើងជាមេធាវីចុងចោទយល់ថា ការបញ្ចូលរនុកក្នុង គឺជាការសហការណ៍ផ្ទៃក្នុងយ៉ាងខ្លាំងក្លាមួយ ។ ដោយឡែក ភាគីដើមចោទបាននិយាយថា របនាសម្ព័ន្ធក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាលនាសម័យនោះ គឺមិនមានភាពច្របូកច្របល់ដូចដែលភាគីចុងចោទបានលើកឡើងនោះទេ រីឯព័ត៌មាននានាដែលទាក់ទងទៅនឹងបក្សកម្មុនីស្តកម្ពុជាត្រូវបានបើកបង្ហាញទៅកាន់ទីសាធារណៈទាំងអស់យ៉ាងចំហ ។

ក្នុងនាមយើងដែលជាមេធាវីចុងចោទយល់ឃើញថា ស្ថានភាពនៃប្រទេសកម្ពុជានាសម័យនោះត្រូវបានគ្រប់គ្រងដោយបុគ្គលផ្សេងៗគ្នា ។ ផ្នែកមួយនៃប្រទេសត្រូវបានគ្រប់គ្រងដោយ ប៉ុល ពត និង សុន សេន ហើយផ្នែកមួយទៀតត្រូវបានគ្រប់គ្រងដោយមេដឹកនាំផ្សេងៗទៀត ដែលមានបំណងផ្តួលរំលំរដ្ឋាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ។ ការបែកបាក់ផ្ទៃក្នុងមួយនេះ បានកើតឡើងតាំងពីមុនពេលដែលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាចមកម្ល៉េះ ។

យោងទៅតាមរបាយការណ៍ ដែលបានមកពីមន្ទីស-២១ របស់លោក កុយ ធួន បានសរសេរថា ក្រុមថ្មីចំនួន២ បានបំបែកខ្លួនចេញពីបក្សកុម្មុយនីស្តនៅឆ្នាំ១៩៧៣ ។ បន្ថែមពីនេះទៅទៀត ក៏មានបុគ្គលផ្សេងបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជានាពេលនោះ គឺពិតជាមានការបែកបាក់ផ្ទៃក្នុងពិតមែន ។ បក្សសម្ព័ន្ធចំនួន៣ត្រូវបានបង្កើតឡើងនៅក្នុងពេលនោះ ដោយបក្សនីមួយៗ បានប្រកាន់នូវគោលជំហរខុសៗគ្នា ។ គោលគំនិតចំនួន៣ធំៗទាំងនោះផ្តោតសំខាន់ទៅលើផ្នែកមនោគមវិជ្ជា ការចងសម្ព័ន្ធមិត្តជាមួយបរទេស និងការផ្តោតសំខាន់ទៅលើទីតាំងភូមិសាស្ត្រ ដូចនេះយើងអាចនិយាយបានថា ប៉ុល ពត និង នួន ជា គ្រាន់តែជាភាគីមួយក្នុងចំណោមភាគី៣ នៃបក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ ។

បណ្តាប្រទេសជិតខាងដែលមានដូចជា ចិន វៀតណាម និង

ថៃ ក៏បានដឹងអំពីការបែកបាក់ផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជានៅសម័យនោះដែរ ។ យោងទៅតាមព័ត៌មានមួយនេះ យើងអាចនិយាយបានថា ផ្ទៃក្នុងរបស់បក្សកម្មុយនីសកម្ពុជា គឺមិនដែលមានភាពរួបរួមនោះទេ ។

សាក្សីបាននិយាយថា ការបែកបាក់ផ្ទៃក្នុងកាន់តែមានសភាពធ្ងន់ធ្ងរទៅ បន្ទាប់ពីការរំដោះនាឆ្នាំ១៩៧៥ ។ សាក្សីក៏បានបន្តរៀបរាប់ពីការបែងចែកកងកម្លាំងកំឡុងពេលដែលបក្សកុម្មុនីស្តបានចូលមកកាន់កាប់ទីក្រុងភ្នំពេញ ។ មេធាវី កុប៉េ នឹងបន្ថែមនូវភ័ស្តុតាងថ្មីៗ ថែមទៀតទៅកាន់សំណុំរឿងមួយនេះ បន្ទាប់ពីទទួលបានការអនុញ្ញាតឲ្យមានការប្រើប្រាស់ ។ ភ័ស្តុតាងថ្មីនេះគឺសំដៅទៅលើកិច្ចសម្ភាសរវាងលោក ថេត សម្បត្តិ ជាមួយលោក រ៉ូប៊ឺត លីមគិន ។

អតីតកម្មាភិបាល បានប្រាប់ទៅកាន់លោក ថេត សម្បត្តិ ថា នៅពេលបញ្ចប់នៃការប្រជុំលើកទីមួយរបស់បក្សកុម្មុយនីស្តកម្ពុជា លោកក៏បានចូលរួមប្រជុំនៅភ្នំពេញជាបន្ទាន់នៅក្នុងឆ្នាំ១៩៧៥ ។ ការប្រជុំនេះមានសមាជិកប្រហែល៣០០នាក់ ដែលរាប់បញ្ចូលមេដឹកនាំតំបន់ និងមេដឹកនាំរបស់ក្រសួងនានា ក៏ដូចជាគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២នាក់ផង ។ គណៈកម្មាធិការអចិន្ត្រៃយ៍ទាំងពីរបាននិយាយអំពីគម្រោងប្រឆាំងទៅកាន់ ប៉ុល ពត ហើយគម្រោងនេះដែរ ត្រូវបានរក្សាជាភាពអាថ៌កំបាំង ពីព្រោះវាទាក់ទិនទៅនឹងជំនួយរបស់ប្រទេសវៀតណាម ។

មេធាវី កុប៉េ បាននិយាយថា ភ័ស្តុតាងដែលបាននិយាយខាងលើពិតជាមានសារសំខាន់ណាស់ សម្រាប់យើងដែលជាមេធាវីការពារលោក នួន ជា ។ ព័ត៌មានមួយនេះ ក៏ត្រូវបានអះអាងដោយអ្នកនាំសារនៃតំបន់ខាងកើតនាសម័យនោះ ដោយគាត់ក៏ធ្លាប់បាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតអំពីរឿងហេតុមួយនេះដែរ ។

មេធាវី កុប៉េ បានបន្ថែមថា តុលាការមិនព្រមទទួលយកភ័ស្តុតាងមួយនេះ ក៏ព្រោះតែតុលាការចង់រក្សានូវរឿងមិនពិតឲ្យមានភាពស្ថិតស្ថេរ ក៏ដូចជាមិនចង់អោយលោក នួន ជា មានសិទ្ធិតតាំងក្នុងរឿងក្តីរបស់គាត់ ។ ក្នុងនាមយើងដែលជាមេធាវីការពារក្តីរបស់នួន ជា នឹងសុំឲ្យអង្គចៅក្រមធ្វើការពិចារណាទៅនឹងភ័ស្តុតាង ដែលយើងបានលើកឡើងខាងលើដើម្បីយកមកប្រើប្រាស់ ។ ប្រសិនបើទទួលបាននូវការអនុញ្ញាតនោះ យើងនឹងយកវាមកប្រើប្រាស់នៅក្នុងការពារក្តីរបស់យើង ។

យើងដែលជាមេធាវីចុងចោទ នឹងលើកយករឿងរ៉ាវដែលទាក់ទងនឹងអំពើពុករលួយរបស់បក្សកុម្មុយនីស្តកម្ពុជានាសម័យនោះមកនិយាយ ។ ក្នុងនោះដែរ យើងនឹងរៀបរាប់អំពីអំពើពុករលួយរបស់សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ មេដឹកនាំយោធា មេដឹកនាំតំបន់កណ្តាល និងមេដឹកនាំដែលមកពីតំបន់ផ្សេងៗ លើកលែងតែមេដឹកនាំមកពីតំបន់និរតីតែប៉ុណ្ណោះ ។ មេដឹកនាំនាសម័យនោះ ដែលយើងលើកមកនិយាយ គឺជាសមាជិករបស់រាជរដ្ឋាភិបាលសព្វថ្ងៃនេះឯង ។ មេធាវី កុប៉េ បានបន្ថែមថា មានភ័ស្តុតាងច្រើនណាស់ដែលទាក់ទងនឹងអំពើក្បត់របស់សមាជិករាជរដ្ឋាភិបាលសព្វថ្ងៃ ទៅកាន់រដ្ឋាភិបាលនាសម័យនោះ ។ មានភស្តុតាងមួយបានបង្ហាញអំពីការចូលដៃដើងគ្នាពីសំណាក់មន្ត្រីរដ្ឋាភិបាលនាសម័យនោះ ជាមួយនឹងភាគីវៀតណាម ។ ការរួបរួមគ្នាពីបុគ្គលទាំងពីរបានបន្សល់នូវគណបក្សមួយដែលមានឈ្មោះថា គណបក្សប្រជាជនកម្ពុជា ។

បន្ទាប់មក មេធាវី កុប៉េ ក៏បាននិយាយអំពីគូរកនក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គូរកនរបស់វៀតណាមបានបញ្ចេញសកម្មភាពភ្លាមៗ ដើម្បីទម្លាក់បក្សកុម្មុយនីស្តកម្ពុជាពីការកាន់អំណាច ។ នាពេលនោះដែរ គេបានព្យាយាមធ្វើឃាត ប៉ុល ពត ចំនួន៤ដង ក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៦ ក៏ប៉ុន្តែ គម្រោងការមួយនេះត្រូវបរាជ័យ ។ ស្ថិតនៅក្នុងឆ្នាំនោះដែរ ក៏មានការរើបម្រះប៉ុនប៉ងក្តោបក្តាប់ស្ថានីយ៍វិទ្យុដែលមានទីតាំងស្ថិតនៅតំបន់ភាគខាងកើត បន្ថែមពីនេះទៅទៀត ក៏មានការរង្គោះរង្គើនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម ។ ដោយសារតែផែនការទីមួយត្រូវបរាជ័យ គូរកនរបស់វៀតណាមក៏បានលើកផែនការទី២ មកប្រើប្រាស់ ដោយការធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧៦ នេះឯង ។ យុទ្ធសាស្ត្រទីមួយនៃផែនការថ្មីនេះ គឺការបំផ្ទុះឃ្លាំងរំសេវនៅខេត្តសៀមរាប ។ លេខាប្រចាំតំបន់បានបើកអង្គប្រជុំមួយដែលមានសមាជិក៣០នាក់ចូលរួម ដែលក្នុងនោះនិយាយពីការបះបោរប្រឆាំងរដ្ឋាភិបាលរបស់ខ្លួន ។ ការប្រជុំនេះបានធ្វើឡើងមួយ

ថ្ងៃមុននឹងមានការផ្ទុះឃ្លាំងគ្រាប់កើតឡើង ។ ដូចនេះយើងអាចនិយាយបានថា រឿងរ៉ាវនេះគឺហាក់បីដូចជាមានការរៀបចំទុកអីចឹង ។

មេធាវីចុងចោទ បានធ្វើការស្នើឲ្យការិយាល័យអង្គចៅក្រម ធ្វើការស៊ើបអង្កេតនូវរឿងហេតុដែលបានកើតឡើងខាងលើនេះ ប៉ុន្តែសំណើរមួយនេះត្រូវបានច្រានចោល ។ យើងនឹងស្នើសុំអោយតុលាការពិចារណាជាមួយនឹងសំណើរខាងលើនេះម្តងទៀតបន្ទាប់ពីមានការច្រានចោលលើកទីមួយរួចមក ។

ប្រាំមួយសប្តាហ៍កន្លងមករដ្ឋប្រហារលើកទី២ ក៏បានកើតឡើង ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៦ ។ រដ្ឋប្រហារលើកទី២ នេះបានកើតឡើងស្របពេលដែលអតីតព្រះមហាក្សត្របានប្រកាសលាលែងពីតំណែងជាប្រមុខរដ្ឋរបស់ទ្រង់ ដែលក្នុងពេលនោះគ្រាប់បែកដៃជាច្រើនត្រូវបានគប់ទៅកាន់ព្រះបរមរាជវាំង ។ កម្មាភិបាលម្នាក់ឈ្មោះ យឹម សម្បត្តិ ត្រូវចាប់ខ្លួនរួចបានសារភាពថា ខ្លួនគឺជាអ្នកគប់គ្រាប់បែកដៃពិតមែន ភ័ស្តុតាងនេះត្រូវបានយកមកប្រើប្រាស់ ពីព្រោះចម្លើយសារភាពរបស់ យឹម សម្បត្តិ ។ មេធាវី កុប៉េ បាននិយាយថា សម្បត្តិ ជាអ្នកគប់គ្រាប់បែកដៃពិតមែន ។ មេធាវី កុប៉េ បានយកភ័ស្តុតាងនេះមកប្រើប្រាស់ពីព្រោះចម្លើយសារភាពរបស់ យឹម សម្បត្តិ មិនត្រូវបានមេគុក នៃមន្ទីរស-២១ បង្ខិតបង្ខំឲ្យនិយាយនោះទេ ។

ស្ថិតនៅត្រង់ចំណុចនេះ ចៅក្រម និល ណុន បាននិយាយកាត់ ក៏ដូចជាក្រើនរំឭកទៅកាន់មេធាវី កុប៉េ ថា ការិយាល័យអង្គចៅក្រមស៊ើបអង្កេត មិនបានពឹងផ្អែកទៅលើភ័ស្តុតាងដែលទាក់ទងទៅនឹងការធ្វើទារុណកម្មយកមកប្រើប្រាស់នោះទេ ។ ចៅក្រមឡាវ៉េញ ចៅក្រម និល ណុន និងមេធាវី កុប៉េ បានពិភាក្សានូវគោលការណ៍នៃការយកភ័ស្តុតាងយកមកប្រើប្រាស់តាំងពីថ្ងៃទី១ នៃការកាត់ក្តីមកម្ល៉េះ ។ ក្នុងនោះដែរ មេធាវី កុប៉េ ត្រូវបានអនុញ្ញាតឲ្យយកពាក្យសម្តីរបស់ យឹម សម្បត្តិ និង កុយ ធួន ដែលធ្លាប់ត្រូវបានឃុំឃាំងនៅមន្ទីរស-២១ យកមកប្រើប្រាស់ក្នុងការតវ៉ាក្តីរបស់ខ្លួន ពីព្រោះចម្លើយរបស់ជនទាំងពីរ មិនត្រូវបានឆ្លងកាត់ការធ្វើទារុណកម្មនោះទេ ។ មេធាវី កុប៉េ ក៏បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញចំពោះការបដិសេធន៍មិនស៊ើបអង្កេតលើកំណត់ត្រារបស់ជនក្បត់ព្រោះវាមានសារសំខាន់ណាស់ក្នុងការបង្ហាញអំពីទង្វើក្បត់ជាតិរបស់ ចាន់ ចក្រី ។

ភ័ស្តុតាងមួយបានបង្ហាញថា លេខាតំបន់១០៦ ឈ្មោះ សុទ្ធ បានចូលដៃដើងជាមួយខ្មាំងវៀតណាមឈ្មោះ កុយ ធួន ក្នុងការបំផ្ទុះនៅខេត្តសៀមរាប ។ កុយ ធួន បាននិយាយនៅក្នុងរបាយការណ៍នៃមន្ទីរស-២១ ថា គាត់បានបង្រៀន សុទ្ធ ដែលជាសកម្មជនរបស់ភ្នាក់ងារស៊ើបការណ៍សម្ងាត់សហរដ្ឋអាមេរិក ។ ភ័ស្តុតាងមួយបានបញ្ជាក់ថា ចាន់ ចក្រី គឺជាមនុស្សនៅពីក្រោយការបំផ្ទុះគ្រាប់បែកនៅព្រះបរមរាជវាំងនាពេលនោះ ។ មេធាវីដើមចោទបាននិយាយថា ព្រឹត្តិការណ៍ទាំងពីរនេះមិនទាក់ទងនឹងគ្នាទេ ព្រោះវាអាចទាក់ទិននឹងអំពើលីលារបស់បក្សកុម្មុនីស្តកម្ពុជាដែលជាលទ្ធផលបានបង្កើតនូវការបោសសម្អាតដោយមិនបានគ្រោងទុក ។

មេធាវី កុប៉េ និយាយថា ភ័ស្តុតាងនេះពិតជាមានភាពទាក់ទាញជាខ្លាំង ព្រោះវាទាក់ទងនឹងព្រឹត្តិការណ៍ទាំងពីរ លើកលែងតែវេលានៃការកើតហេតុប៉ុណ្ណោះ ។ ដូចនេះយើងអាចបកស្រាយបានថា ចាន់ ចក្រី និង កុយ ធួន គឺមានទំនាក់ទំនងរវាងគ្នានឹងគ្នា ។ ជាការពិតទៅ ចាន់ ចក្រី គឺជាសមាជិកនៃតំបន់ខាងជើងដែរ កុយ ធួន ជាអ្នកកាន់កាប់ ។ ស្របពេលនោះដែរ កុយ ធួន ក៏ធ្លាប់បានណែនាំ ចាន់ ចក្រី ទៅកាន់បក្សកុម្មុយនីស្តកម្ពុជា ។ មេដឹកនាំធំៗរបស់បក្សកុម្មុយនីស្តជាច្រើនបានបង្កភាពចលាចលទៅកាន់បក្សបន្ទាប់ពីការរំដោះទីក្រុងភ្នំពេញបានរយៈពេលមួយឆ្នាំ ។ នាពេលនោះ កុយ ធួន ត្រូវបានឃុំឃាំងនៅផ្ទះ ដោយប្រើប្រាស់ពេលប្រមាណមួយយប់មួយថ្ងៃ និងកងកម្លាំងពិសេសជាច្រើននាក់ដើម្បីចាប់រូបគាត់ ។

មេធាវី កុប៉េ បានបន្តទៀតថា ពួកគេបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាជាងមុន បន្ទាប់ពីការបរាជ័យលើកទីមួយមក ។ ពួកគេបានលើកគម្រោងម្តងទៀតនៅឆ្នាំ១៩៧៦ ហើយសកម្មភាពត្រូវបានកើតឡើងនៅឆ្នាំ១៩៧៧ ។ ការធ្វើរដ្ឋប្រហារលើកទីពីរ គឺមិនត្រូវបានធ្វើឡើងជាធំដំនោះទេ ហើយជាទូទៅបានយល់ច្រឡំថា វាគឺជាការគំរាមកំហែងពីភាគីវៀតណាមទៅវិញ ។

មេធាវី កុប៉េ និយាយថា មេធាវីដើមចោទបានច្រានចោល

ចំពោះការធ្វើរដ្ឋប្រហារនាឆ្នាំ១៩៧៧ ដោយបាននិយាយថា នេះគឺភ័ស្តុតាងដែលមិនគួរឲ្យជឿជាក់មួយ ។ មេធាវីដើមចោទ ក៏បានពោលថា រាល់នាយទាហានទាំងអស់សុទ្ធសឹងតែនិយាយពាក្យមិនពិត រួចក៏បានច្រានចោលនូវភ័ស្តុតាងទាំងអស់របស់សាក្សីដែលធ្លាប់បានចូលរួមធ្វើរដ្ឋប្រហារ ។ បើទោះជាបែបនេះក្តី ក៏យើងនៅតែប្រើប្រាស់នូវភ័ស្តុតាងមួយនេះ ពីព្រោះវាមានធាតុសមហេតុផលជាច្រើនក្នុងការគាំទ្រទៅនឹងករណីរបស់ នួន ជា ។ ភ័ស្តុតាងទីមួយរបស់យើង នឹងធ្វើការដកស្រង់ចេញពីសាក្សីក្នុងតុលាការ ចំណែកភស្តុតាងទីពីរនឹងដកស្រង់ពីបណ្តាឯកសារនានា រីឯភ័ស្តុតាងទីបី នឹងដកស្រង់ចេញពីបទសម្ភាសរបស់ ថេត សម្បត្តិ និង រ៉ូប៊ឺត លឹមគិន ។

អត្ថបទរបស់មេធាវីដើមចោទ បានកំណត់អត្តសញ្ញាណសាក្សីចំនួន៩រូប ដោយសាក្សីបានបកស្រាយពីការធ្វើរដ្ឋប្រហារនាឆ្នាំ១៩៧៧ ។ សាក្សីទាំង៩ បាននិយាយថា រដ្ឋប្រហារមួយនេះធ្វើឡើងដោយមេបញ្ជាការនៃកងពលលេខ៣១០ ដែលមានតាំងទីនៅតំបន់ដ៏ល្អសម្រាប់ការវាយប្រហារ ។ កងពលមួយនេះត្រូវបានបញ្ជូរជើងនៅជុំវិញទីក្រុងភ្នំពេញ ចាប់តាំងពីថ្ងៃរំដោះភ្នំពេញមកម្ល៉េះ ចំណែកកងកម្លាំងផ្សេងៗគឺស្ថិតនៅតំបន់ខាងកើត និងតំបន់ខាងជើង ។

ដោយឡែក មេធាវីដើមចោទបាននិយាយបកវិញថា រដ្ឋប្រហារដែលមេធាវីចុងចោទបាននិយាយខាងលើ គឺគ្រាន់តែជាការស្រមៃតែប៉ុណ្ណោះ ឬអាចនិយាយបានថា រឿងហេតុមួយនេះគឺមិនបានកើតឡើងនោះទេ ។ យើងយល់ថាគម្រោងដែលបានធ្វើគឺមានគោលបំណងធំៗចំនួនបីគឺ ៖

១) បិទច្រកចេញចូលនានា នៅទីក្រុងភ្នំពេញ រួចកាន់កាប់អាកាសយានដ្ឋានខេត្តកំពង់ធំ និងគ្រប់គ្រងស្ថានីយវិទ្យុ

២) កម្ទេចនូវប្រព័ន្ធការពារ និងយោធា ដោយតម្រង់មុខសញ្ញាទៅកាន់ក្រសួងការពារជាតិ ឃ្លាំងផ្គត់ផ្គង់ និងសម្ភារយោធានានា

៣) កំណត់គោលដៅរួចសម្លាប់ ប៉ុល ពត ចោល

សាក្សីចូលរួម១០នាក់ទៀត បានផ្តល់ចម្លើយរួមទាំងភ័ស្តុតាងដែលខ្លួនបានឃើញផ្ទាល់ភ្នែក ជាពិសេសគឺព័ត៌មានដែលទាក់ទងទៅនឹងគម្រោងទីពីរនេះឯង ។ កំឡុងពេលវាយប្រហារមកកាន់ទីក្រុងភ្នំពេញក៏បានវាយបំបាក់ក្រុមផ្សេងៗដែលជាដៃឆ្វេងនឹងស្តាំរបស់បក្សកុម្មុយនីស្តកម្ពុជា ។ សាក្សីក៏បានបន្តទៀតថា ទីតាំងដែលពួកគេឈរជើង គឺស្ថិតនៅតំបន់ភាគពាយ័ព្យ ។ រស់ ញឹម ដែលជាប្អូនថ្លៃរបស់ សោ ភឹម គឺជាបុគ្គលធំម្នាក់ដែលស្ថិតនៅពីក្រោយរឿងនេះ ។ សាក្សីបានបន្ថែមថា ក្រៅពី រស់ ញឹម ក៏មានបុគ្គលចំនួន៦នាក់ទៀត ដែលមានឈ្មោះ ចាន់ ចក្រី និង វន វើត រួមទាំងអ្នកផ្សេងៗបានចូលរួម ។

តំបន់ពាយ័ព្យ និងកងពលលេខ៣១០ គឺជាទីតាំងដ៏ល្អមួយសម្រាប់ធ្វើការវាយប្រហារ ពីព្រោះវាជាកន្លែងសម្រាប់ខ្មែរក្រហមផលិតស្រូវ និងធ្វើស្រែ ។ ជាមួយគ្នានេះដែរ តំបន់១០៦ និងភូមិភាគខាងកើត ក៏ជាទីតាំងល្អសម្រាប់ការវាយប្រហារ ព្រោះវាមានព្រំប្រទល់លាតសន្ធឹងដល់ព្រំដែនថៃ-ឡាវ និងវៀតណាម ហើយក៏ជាទីតាំងដ៏ល្អមួយសម្រាប់ទន្រ្ទានយក ព្រោះអាចបិទផ្លូវចេញចូលរបស់ខ្មែរក្រហមបាន ។

សាក្សីបានបកស្រាយថា ការវាយប្រហារលើកនេះ គឺមានគោលបំណងធំពីរ គឺបំបាក់កម្លាំងខ្មែរក្រហមទូទាំងប្រទេស និងកាន់កាប់ទឹកដីទាំងមូល ។ ពួកគេបានខិតខំចុះចូលជាមួយក្រុមភូមិភាគខាងកើត និងក្រុមដែលមកពីកងពលលេខ៣១០ ខណៈពេលដែលមកដល់ទីក្រុងភ្នំពេញ ។ គោលបំណងដ៏ធំក្រោយការចុះចូលនេះគឺធ្វើឡើងដើម្បីទម្លាក់បក្សកុម្មុយនីស្តកម្ពុជា ដែលជារដ្ឋាភិបាលស្របច្បាប់របស់កម្ពុជានាសម័យនោះ ។

សាក្សីទាំង១៩ បានបន្តថា ក្រុមនោះបានខិតខំជាខ្លាំងដើម្បីឲ្យគម្រោងការដំណើរការដោយរលូន ។ ពួកគេបានបំផ្លាញបង្ក្រាបប្រមែប្រមូលគ្រឿងសព្វាវុធ បង្កើតការប្រជុំ រួមទាំងបើកនូវការជ្រើសរើសសមាជិកថ្មីដើម្បីជាស្នូលក្នុងការសម្រេចនូវគម្រោងដែលបានលើកឡើង ។ ក្នុងនោះ គេបានសម្គាល់ថា ខ្មាំងរបស់វៀតណាម គឺជាជនដែលបានបំផ្លាញសង្គមរបស់ខ្មែរច្រើនជាងនៅសម័យនោះ ។ ប៉ុល ពត ក៏បានធ្វើការស៊ើបអង្កេតទៅកាន់ក្រុមនៃតំបន់នោះបន្ទាប់ពី អៀង ធីរិទ្ធ កើតមានមន្ទិលសង្ស័យចំពោះសកម្មភាពរបស់ពួកគេ ។

សាក្សីជាច្រើនបានផ្តល់ភ័ស្តុតាងទៅកាន់ការស៊ើបអង្កេត

មួយនេះ ។ សាក្សីម្នាក់បាននិយាយថា គាត់ត្រឹមតែធ្វើតាមការណែនាំរបស់ នួន ជា ប៉ុណ្ណោះ រីឯសាក្សីពីរនាក់ទៀតបាននិយាយថា ខ្លួនបានទុកស្បៀងចោលយូរពេក រហូតដល់វាខូចអស់ មានភ័ស្តុតាងផ្សេងទៀតបានបញ្ជាក់ថា ស្បៀងទាំងអស់ត្រូវបានបំផ្លាញចោលដោយចេតនា ។ លោក រ៉ូប៊ីត លីមគិន និង ថេត សម្បត្តិ បានធ្វើបទសម្ភាសជាមួយបុគ្គលម្នាក់ ហើយបាននិយាយថា ថ្នាំបង្កា រួមជាមួយនឹងរំសេវ ក៏ត្រូវបានបំផ្លាញចោលដោយចេតនាដែរ ។ ក្នុងពេលនោះ រស់ ញឹម ក៏បានចាប់ផ្តើមផ្សព្វផ្សាយនូវសង្គ្រាមចិត្តសាស្ត្រក្នុងការប្រើប្រាស់រូបបីយវត្ថុនាពេលបន្ទាប់វាក៏ត្រូវបានគេប្រើប្រាស់នៅភូមិភាគពាយ័ព្យ ។ អ្នកខ្លះបានក្លែងបន្លំការប៉ះទង្គិចនៅខាងព្រំដែនថៃ ដើម្បីឲ្យគេយល់ថាស្ថានភាពនៅតំបន់នោះពិតជាមានភាពតឹងតែង ដែលកងទ័ពមិនអាចបញ្ជូនទៅកាន់ទីនោះបានទេ រីឯតំបន់ស្វយ័តទៀតសោត ក៏ត្រូវបានឈប់ដាក់មីននៅតាមតំបន់ព្រំដែនដែរ ។

មេធាវី កុប៉េ បានរំពឹកថា ប្រសិនបើអង្គជំនុំជម្រះកោះហៅលោក ហ៊ុន សែន មកធ្វើជាសាក្សី នោះភ័ស្តុតាងសំខាន់នានានឹងអាចយកមកប្រើប្រាស់បាន ។ បន្ទាប់មក មេធាវី កុប៉េ ក៏បានបកស្រាយពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។

សាក្សីដែលមានវត្តមាននៅទីនេះ គឺជាបុគ្គលដែលបានដឹកសព្វាវុធចេញពីតំបន់ ៣១០ ដើម្បីធ្វើរដ្ឋប្រហារ ។ មេបញ្ជាការម្នាក់ និងពលទាហានជាច្រើនបានអះអាងថា ខ្លួនបានរៀបចំរថក្រោះកងទ័ពជើងទឹក និងយន្តហោះចម្បាំងរបស់តំបន់ ៣១០ ។ បរិក្ខារជាច្រើនមានដូចជា គ្រឿងបរិភោគ សព្វាវុធ ប្រេងសាំង និងសម្លៀកបំពាក់នានា ត្រូវបានបញ្ជូនមកកាន់តំបន់ដែលគ្រឿងទាំងនោះត្រូវបានយកមកពីប្រទេសវៀតណាម ។ គេបានបន្តថា ស្ថានភាពមួយនេះគឺមានលក្ខណៈស្រដៀងគ្នាទៅនឹងស្ថានភាពនៅភូមិភាគពាយ័ព្យដែរ ។ សាក្សីបានបញ្ជាក់ថា ការរឹបអូសនូវសព្វាវុធ សម្លៀកបំពាក់ មួក អង្រឹង អង្ករ ស្ករ និងត្រី ត្រូវបានប្រមែប្រមូលមកដើម្បីផ្គត់ផ្គង់កងទ័ព នៅតំបន់ភាគពាយ័ព្យ និងភ្នំពេញ ។

បន្ទាប់មក ក៏បានបើកប្រជុំ និងកេណ្ឌមនុស្សថែមទៀតដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧៧ ។ សាក្សីក៏បានបន្តបកស្រាយអំពីការប្រជុំដែលទាក់ទងនឹងការបះបោរ ។ ការប្រជុំលើកទីមួយមានសមាជិកប្រមាណ៥០០នាក់បានចូលរួម រីឯការប្រជុំលើកទី ២ ត្រូវបានចូលរួមដោយកងវរទាំងមូល ដែលពេលនោះរឿងដ៏សម្ងាត់បំផុតត្រូវបានលើកឡើងក្នុងអង្គប្រជុំ ។

វ៉ន វេត និងមន្ត្រីយោធា មកពីតំបន់នោះប្រមាណ១០០នាក់ទៀត បានប្រជុំយ៉ាងសម្ងាត់ នៅក្នុងព្រៃនាខេត្តបាត់ដំបង និងភូមិភាគពាយ័ព្យ ។ ក្នុងការប្រជុំនោះ រស់ ញឹម បានបកស្រាយនូវផែនការសម្ងាត់ ហើយ វ៉ន វ៉េត ក៏បាននិយាយថា ខ្លួននឹងសុំជំនួយពីខាងក្រៅក្នុងករណីចាំបាច់ ។ ក្នុងពេលនោះដែរ គេក៏បានកេណ្ឌសមាជិកថ្មីប្រមាណ៣០.០០០នាក់ មកពីភូមិភាគពាយ័ព្យ ។ ការធ្វើរដ្ឋប្រហារនៅឆ្នាំ១៩៧៧ ពុំបានទទួលជោគជ័យនោះទេ ក៏ប៉ុន្តែទោះជាបែបនេះក្តី ក៏គណៈកម្មាធិការអចិន្ត្រៃយ៍នៅតែបន្តការស៊ើបអង្កេតយ៉ាងហ្មត់ចត់ចំពោះរឿងនេះដដែល ។ មេបញ្ជាការឈ្មោះ អឿន ត្រូវបានតាមដានអស់រយៈពេល៣ខែមុនចាប់ខ្លួន ។ អ្នកផ្សេងទៀតបាននិយាយថា បន្ទាប់ពីរឿងហេតុនេះកើតឡើង ត្រូវបានថ្នាក់លើចាត់ទៅធ្វើការតាមតំបន់ផ្សេងៗ រីឯអ្នកខ្លះបាននិយាយថា ថ្នាក់លើមិនបានធ្វើអ្វី ឬក៏ត្រូវបានបញ្ជូនទៅតាមតំបន់ផ្សេងៗនោះទេ ។

មេដឹកនាំកងពលប្រចាំតំបន់ និងមេដឹកនាំតំបន់ស្វយ័តបានធ្វើការប្រឆាំង នួន ជា រួមជាមួយគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ។ ទង្វើនេះបានធ្វើអោយបក្សយល់ថា ការដាក់ទោសចំពោះទង្វើក្បត់ជាតិទៅកាន់ពួកគេពិតជាត្រឹមត្រូវនឹងស្របតាមច្បាប់ណាស់ ។ មេធាវី កុប៉េ បានបន្តនូវព័ត៌មានលម្អិតដែលទាក់ទងជាមួយការធ្វើរដ្ឋប្រហារនាឆ្នាំ១៩៧៨នោះ ។ កងពលតំបន់ខាងកើតបានព្យាយាមធ្វើរដ្ឋប្រហារម្តងទៀតនៅខែឧសភា ឆ្នាំ១៩៧៨ បន្ទាប់ពីរដ្ឋប្រហារនៅឆ្នាំ១៩៧៧ បានទទួលបរាជ័យ ។ រដ្ឋប្រហារលើកទី២ នេះបាននាំមកនូវការធ្វើអត្តឃាតរបស់ សោ ភឹម ប៉ុន្តែវាត្រូវបានបកស្រាយដោយប្រើប្រាស់រឿងមិនពិត ដើម្បីបង្ហាញនូវភាពត្រឹមត្រូវរួមជាមួយការខិតខំប្រឹងប្រែងរបស់ចក្រពត្តិវៀតណាម ។

មេធាវីកុប៉េ បានព្យាយាមកែប្រែនូវប្រវត្តិសាស្ត្រមួយនេះឲ្យមានភាពត្រឹមត្រូវឡើងវិញដោយលើកយកនូវចំណុចសំខាន់ៗ

ចំនួន៣ មកប្រើប្រាស់៖

១) រដ្ឋប្រហារឆ្នាំ១៩៧៨ មិនមែនជាជំហរចុងក្រោយក្នុងការតស៊ូប្រឆាំងរបស់ក្រុមកងទ័ពសេរីទៅកាន់របបដ៏សែនកាចសាហាវនោះទេ ពីព្រោះគម្រោងការមួយនេះគឺបានធ្វើឡើងដោយមានជំនួយពីវៀតណាម ។ អ្នកដឹកនាំវៀតណាមបានយល់ព្រមចំពោះការធ្វើរដ្ឋប្រហារដែលដឹកនាំដោយលោក សោ ភឹម ហើយពេលនោះ លោក ហ៊ុន សែន បានវិលត្រឡប់មកប្រទេសកម្ពុជាដោយរថក្រោះ និងអមដំណើរដោយកងទ័ពវៀតណាម ។

២) សោ ភឹម មិនមែនជាមេដឹកនាំមិនល្អនោះទេ ប្រសិនយើងធ្វើការប្រៀបធៀបជាមួយមេដឹកនាំផ្សេងៗទៀត ក៏ប៉ុន្តែគាត់ធ្លាប់ទម្លាក់រដ្ឋាភិបាលស្របច្បាប់ចោលដោយប្រើប្រាស់នូវអំណាចដ៏សែនមហិមា និងឃោរឃៅ ដែលគាត់មាន ។ ដោយសារតែមូលហេតុនេះ ទើបរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជាប្រជាធិបតេយ្យ មានសិទ្ធិជំទាស់នូវរាល់ការរៀបចំទាំងឡាយរបស់ សោ ភឹម ។ ភស្តុតាងមួយបានបង្ហាញពីការយល់ព្រមរបស់វៀតណាមចំពោះការធ្វើរដ្ឋប្រហាររបស់ សោ ភឹម ។

៣) រដ្ឋប្រហារឆ្នាំ១៩៧៨ គឺមិនបានធ្វើឡើងដោយការស្ម័គ្រចិត្តនោះទេ ប៉ុន្តែវាបានធ្វើឡើងដោយការណែនាំយ៉ាងប្រិតប្រៀងពីវៀតណាម ។ កងទ័ពនៅតំបន់ខាងកើតបានត្រៀមខ្លួនយ៉ាងរួចរាល់សម្រាប់រដ្ឋប្រហារឆ្នាំ១៩៧៧ ។ នាពេលនោះគេបានចាប់ផ្ដើមសាងសង់លេណដ្ឋាន សម្រាប់ទុកស្បៀង អាវុធ និងថ្នាំសង្កូវ ហើយក៏បានកេណ្ឌកងទ័ពថ្មីៗ ។

វៀតណាមក៏បានសម្រេចចិត្តចាត់ការរឿងនេះដោយខ្លួនឯងបន្ទាប់ពីរនុកក្នុងរបស់ខ្លួនធ្វើរដ្ឋប្រហារបរាជ័យ ។ វៀតណាមបានខិតខំប្រឹងប្រែងលុកលុយការងាររផ្ទៃក្នុងជាច្រើន ហើយបន្ថែមពីនេះក៏បានឈ្លានពានមកកាន់ប្រទេសកម្ពុជានាឆ្នាំ១៩៧៨ ។

វៀតណាមបានធ្វើសកម្មភាពមួយនេះដោយប្រើយុទ្ធសាស្ត្រជាច្រើន ។ យុទ្ធសាស្ត្រទី១ គឺការចងសម្ព័ន្ធមិត្តជាមួយសហភាពសូវៀត ខណៈដែលកម្ពុជានាសម័យនោះមានសម្ព័ន្ធមិត្តជាមួយចិនដែលជាប្រទេសផ្ដល់ជំនួយ ។ យុទ្ធសាស្ត្រទី២ វៀតណាមបានជ្រើសរើសជនភៀសខ្លួនកម្ពុជានៅប្រទេសវៀតណាម មកធ្វើជាភ្នាក់ងាររបស់ខ្លួន ហើយក៏បានបង្កើតកម្លាំងទ័ពជួរមុខផង ។ ទង្វើទាំងអស់នេះបានធ្វើឲ្យវៀតណាមកាន់កាប់ប្រទេសកម្ពុជាយ៉ាងពេញលេញ ប៉ុន្តែជាលក្ខណៈដោយប្រយោល ។ បន្ទាប់ពីទទួលបានអំណាចនេះរួចមក វៀតណាមក៏បានបង្កើតរដ្ឋាភិបាលអាយ៉ងមួយនៅទីក្រុងភ្នំពេញដើម្បីបម្រើផលប្រយោជន៍ដល់ខ្លួន ។ អតីតព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ បានដាក់ឈ្មោះរដ្ឋាភិបាលនោះថា អាយ៉ង ដ៏គួរឲ្យអាណិត ពាក្យនេះឯងគឺសំដៅទៅកាន់ លោក ហេង សំរិន តែម្ដង ។ យុទ្ធសាស្ត្រទី ៣ វៀតណាមបានទប់ស្កាត់ការឃោសនារបស់ខ្លួន ផ្សព្វផ្សាយនូវទង្វើអាក្រក់របស់ប្រជាជនកម្ពុជា ហើយទម្លាក់កំហុសទៅកាន់ ប៉ុល ពត រួចព្យាយាមបង្ហាញថា អំពើដែលខ្លួនបានធ្វើមកលើប្រទេសកម្ពុជា គឺជាសកម្មភាពមនុស្សធម៌ បន្ថែមពីនេះ វៀតណាមក៏បានព្យាយាមបង្ហាញថាបក្សកុម្មុយនីស្តកម្ពុជា បានព្យាយាមផ្ដាច់ខ្លួនចេញពីលោកខាងក្រៅដែរ ។

វៀតណាម ត្រូវបានអ្នកផងផ្ដន្ទាទោសដោយសារការបំពានមកកាន់ប្រទេសកម្ពុជា ដែលនេះជាទង្វើល្មើសទៅនឹងច្បាប់អន្តរជាតិ ។ ប្រទេសទូទាំងពិភពលោកបានគាំទ្រក្នុងការផ្ដន្ទាទោស ក៏ប៉ុន្តែសហភាពសូវៀត បានបដិសេធចំពោះការលើកឡើងមួយនេះ ដូចនេះដំណោះស្រាយ ឬការសម្រេចចិត្តមិនអាចឆ្លងផុតដំណាក់កាលរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិបាននោះទេ ។ សមាជិកនៃក្រុមប្រឹក្សាសន្តិសុខអន្តរជាតិបានចេញសេចក្ដីដំណោះស្រាយព្រាងដើម្បីស្នើសុំឲ្យកងទ័ពបរទេសដកខ្លួនចេញពីប្រទេសកម្ពុជាក៏ដូចជាផ្ដល់សិទ្ធិពេញលេញមកកាន់ប្រទេសកម្ពុជាវិញ ។ អង្គការសហប្រជាជាតិបានទទួលស្គាល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យថាជារដ្ឋាភិបាលស្របច្បាប់ ។ បន្ទាប់ពីមានរឿងរ៉ាវមួយនេះមកប្រទេសនានាក៏បានដាក់ទណ្ឌកម្មទៅលើប្រទេសវៀតណាមរហូតដល់ពេលវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា ។ ក្នុងពេលនោះសហគមន៍អន្តរជាតិ បានមើលមកវៀតណាមថា ជាប្រទេសដែលថោកទាប ។ ទាំងនេះគឺជាប្រវត្តិសាស្ត្រដ៏សំខាន់មួយសម្រាប់រឿងក្ដីមួយនេះ ដូចនេះការិយាល័យអង្គចៅក្រមគួរតែពិនិត្យរឿងនេះឡើងវិញបន្ថែមទៀត ។

***(តទៅលេខក្រោយ)***

**រ៉ូនិត អារី**

# សិល្បៈក៏ជាឧបករណ៍សម្រាប់ការព្យាបាល និងធ្វើឱ្យជាសះស្បើយ

ប្រវត្តិសាស្ត្រមិនអាចដោះស្រាយបញ្ហាបច្ចុប្បន្ន ច្រើនជាងសិល្បៈដែលអាចព្យាបាលលក្ខខណ្ឌលំបាកមនុស្សយើង ប៉ុន្តែរវាងអ្នកទាំងពីរ ការព្យាយាមសិក្សា និងបង្កើតក្តីស្រមៃដែលចង់បាន អាចជួយឲ្យអារ្យធម៌របស់ប្រទេសយើងឆ្ពោះទៅរកភាពថ្កុំថ្កើងថ្មីមួយបាន ។

មនុស្សគ្រប់រូបសុទ្ធតែមានសិល្បៈរៀងខ្លួន ហើយមនុស្សក៏ត្រូវការសិល្បៈទោះស្ថិតនៅក្នុងស្ថានភាពរីករវរ សង្គ្រាម និងសន្តិភាពក៏ដោយ ។ សិល្បៈត្រូវបានមនុស្សយកទៅប្រើប្រាស់តាមវិធីផ្សេងៗ ទាំងការធ្វើឲ្យសប្បាយរីករាយ ធ្វើឲ្យកើតទុក្ខ ធ្វើឲ្យមានការចងកំហឹង ស្អប់ និងគុំគួន ។ នៅក្នុងសម័យខ្មែរក្រហម មេដឹកនាំខ្មែរក្រហមបានបង្កើតក្រុមសិល្បៈឡើងដើម្បីសម្តែង និងផ្សព្វផ្សាយពីការតស៊ូ ការលះបង់របស់ប្រជាជនចូលរួមជាមួយចលនាបដិវត្តន៍របស់ខ្លួន ។ សិល្បៈរបស់ខ្មែរក្រហមទាំងនេះមិនបានបង្ហាញ និងលើកឡើងពីខ្លឹមសារ ជាសាកលរបស់សិល្បៈនោះទេ ។ ខ្មែរក្រហមបានបដិសេធចោលទាំងស្រុងនូវតួនាទីអប់រំផ្លូវអារម្មណ៍ជាសកលរបស់សិល្បៈ ប៉ុន្តែខ្មែរក្រហមបែរជាយកសិល្បៈទៅបម្រើគោលនយោបាយ មាគ៌ារបស់បក្ស ការរើសអើង នៅក្នុងរបបគ្រប់គ្រងរបស់ខ្លួនទៅវិញ ។ ខ្មែរក្រហមបានបង្កើតសិល្បៈ ចម្រៀង (មាន



និស្សិតសាលាហ្វាពន្លឺសិល្បៈនៅខេត្តបាត់ដំបង មកធ្វើទស្សនកិច្ចសិក្សានៅវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត នៅក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ ក្រុងភ្នំពេញ ។

ចំណងជើង ឈាមក្រហមឆ្អៅ, វីរភាពយុទ្ធមិត្ត និងចម្រៀងជាច្រើនទៀត) រួមទាំង ល្ខោន ក្នុងគោលបំណងបណ្តុះគំនិតឲ្យមានការសងសឹក និងចងគំនុំ ។ បន្ទាប់មក ខ្មែរក្រហមបានយកសិល្បៈទាំងនេះទៅសម្តែង និងផ្សព្វផ្សាយមិនត្រឹមតែក្នុងចំណោមប្រជាជន តែក៏បានយកទៅផ្សព្វផ្សាយជាពិសេសក្នុងចំណោមយោធាដែលស្ថាប័នអនុវត្តនូវបទបញ្ជាដ៏តឹងរ៉ឹងរបស់ខ្លួន ដើម្បីបណ្តុះស្មារតីក្លាហានការឈឺចាប់ និងហ៊ានប្រព្រឹត្តអំពើឃោរឃៅចំពោះអ្នកដែលត្រូវបានអង្គការចោទថា ខ្មាំង ។ ជាមួយការបណ្តុះគំនិតស្អប់ខ្ពើម គំគួនតាមរយៈសិល្បៈ រួមជាមួយការសង្ស័យ និងការមិនទុកចិត្ត ខ្មែរក្រហមបានកាប់សម្លាប់ជនរងគ្រោះស្លូតត្រង់ប្រមាណជាង១.៧លាននាក់ ដោយបន្សល់ទុកនូវអ្នករស់រានមានជីវិតជាមួយជំងឺផ្លូវចិត្ត ។

សិល្បៈអាចក្លាយជាឧបករណ៍នៃការព្យាបាល និងជាស្ពានដើម្បីផ្សះផ្សា ។ សិល្បៈបង្កើតនូវទស្សនវិស័យថ្មីៗទៅលើភាពអមនុស្សធម៌ ដែលផ្តល់ពន្លឺទៅលើធាតុផ្សំនៃលក្ខខណ្ឌរបស់មនុស្សដែលជារឿយៗត្រូវបានកប់ក្រោមភាពអាក្រក់ និងភាពគ្មានគុណធម៌ ។ តាមរយៈគោលជំហរនៃវីរភាពប្រឆាំងការគាបសង្កត់, ទង្វើសប្បុរសធម៌រវាងជនរងគ្រោះ ឬភាពមិនស្ថិតស្ថេរនៃមនសិការក្នុងក្រមសីលធម៌នៅក្នុងសមុទ្រនៃអំពើទុច្ចរិត, សិល្បៈបង្ហាញពីភាពស្រស់ស្អាតនៅចំកណ្តាលនៃភាពរន្ធត់ ។ សិល្បៈផ្តល់នូវអំណាចកាន់តែខ្ពស់ជាងបទពិសោធ, ការត្រិះរិះពិចារណា, បញ្ហាប្រឈម និងការយល់ឃើញនៃមនុស្សជាតិ តាមរយៈប្រព័ន្ធផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដែលផ្តល់អត្ថន័យដល់ការរងទុក្ខវេទនា យ៉ាងច្រើនដូចការលេងសើចសប្បាយ ។ ប៉ុន្តែភាពទទួលរងការឈឺចាប់នៃភាពអមនុស្សធម៌ មិនមែនជាសិល្បៈនោះទេ ។ ភាពអមនុស្សធម៌មិនត្រូវបានបង្កើតទៅជាទម្រង់នៃភាពស្ងើចសរសើរ ឬការសង្កេតមើលដោយភាពអើពើ ។ យើងមិនត្រូវព្រងើយកន្តើយទៅលើផ្នត់គំនិតនៃអំពើអមនុស្សធម៌ឡើយ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ រដ្ឋាភិបាលបានធ្វើការដោយផ្តោតសំខាន់ទៅលើការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់ជនរងគ្រោះ និងអ្នកដែលមានជំងឺផ្លូវចិត្ត រួមទាំងយន្តការនៃការផ្សះផ្សា និងការអត់ឱនតាមរយៈការចូលខ្លួនមកសារភាពពីទោសកំហុសរបស់អតីតខ្មែរក្រហម និងក្រោយមកតាមរយៈយន្តការបង្កើតតុលាការអន្តរជាតិដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្រៅពីនេះក៏មានស្ថាប័ន និងអង្គការផ្សេងៗ បានយកព្រះពុទ្ធសាសនាដើម្បីរំសាយការឈឺចាប់ និងការផ្សះផ្សាផ្លូវចិត្ត តាមរយៈធម៌អប់រំផ្លូវចិត្ត ការតាំងសមាធិ និងការធ្វើធម្មយាត្រា រួមជាមួយការព្យាបាលដោយការប្រឹក្សាយោបល់ ។ កន្លងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាស្ថាប័នស្រាវជ្រាវ និងចងក្រងឯកសារពីរបបខ្មែរក្រហម បានសហការជាមួយអង្គការហ្វារពន្លឺសិល្បៈដែលមានទីតាំង នៅក្នុងខេត្តបាត់ដំបង បង្កើតជាស្នាដៃសិល្បៈទាក់ទងនឹងរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមដើម្បីសម្តែង និងដាក់តាំងពិព័រណ៍នៅសាលសហសម័យវិទ្យាស្ថានស្លឹករឹត ក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំក្នុងក្រុងភ្នំពេញ ក្នុងគោលបំណងអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ នៅពេលថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏បានអញ្ជើញនិស្សិតឆ្នាំទី១នៃសាលាហ្វារពន្លឺសិល្បៈមកទស្សនកិច្ច ដែលភាគច្រើនមិនដែលបានមកភ្នំពេញឲ្យមកទស្សនកិច្ចសិក្សានៅសារមន្ទីរជាតិ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងទស្សនាខ្សែភាពយន្តឯកសារដែលមានចំណងជើងថា «កុំស្អានបងភ្លេច» ដើម្បីជាការអប់រំ និងការផ្តល់គំនិតថ្មីៗទាក់ទងជាមួយសិល្បៈ និងប្រវត្តិសាស្ត្រខ្មែរក្រហម ។ ក្រៅពីទស្សនកិច្ចសិក្សា និស្សិតទាំងនេះក៏មានការធ្វើការងាររចនាប្លង់របស់ក្រុងភ្នំពេញ ដោយផ្សារភ្ជាប់ជាមួយការអប់រំសិល្បៈ និងប្រវត្តិសាស្ត្រដែរ ៖

◆ ហ៊ឹម ស្រីអូន ជានិស្សិតឆ្នាំទី១ នៃសាលាហ្វារពន្លឺសិល្បៈដែលបានចូលរួមកម្មវិធីតាំងពិព័រណ៍បានឲ្យដឹងថា គាត់អរគុណសម្រាប់ការអនុញ្ញាតឲ្យគាត់និយាយពីអារម្មណ៍ដែលបានទៅភ្នំពេញចូលរួមសិក្ខាសាលា និងទស្សនកិច្ចសិក្សា ។ សម្រាប់គាត់ពិតជាសប្បាយចិត្តណាស់ដែលបានមកភ្នំពេញ ហើយបានយល់ដឹងនិងទទួលបានមេរៀនថ្មីៗក្នុងជីវិត ។ ទាំងនេះជារឿងល្អសម្រាប់គាត់ក្នុងការស្វែងយល់ពីសង្គមខាងក្រៅ ។ ស្រីអូន ពេញចិត្តក្នុងកម្មវិធីទស្សនកិច្ចសិក្សានៅភ្នំពេញ ព្រោះធ្វើឲ្យគាត់បានចងចាំរឿងច្រើន ដូចជាការចងចាំពេលពិសេសជាមួយមិត្តរួមថ្នាក់ គ្រូនិងបានចំណាយពេលជួបជាមួយលោក ឆាំង យុ នាយកមជ្ឈ

មណ្ឌលឯកសារកម្ពុជា និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ស្រីអូន ក៏អរគុណសម្រាប់ការចំណាយពេលរបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយក្រុមរបស់គាត់ និងជូនក្រុមរបស់គាត់ទៅមើលសារមន្ទីរជាតិ និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។ នៅពេលគាត់ទៅទួលស្លែង គាត់មានអារម្មណ៍សោកស្តាយ និងឈឺចាប់ចំពោះរឿងនៅទីនោះ ។ ស្រីអូន សង្ឃឹមថា នឹងមិនមានរឿងដូច្នេះកើតឡើងម្តងទៀតសម្រាប់ប្រទេសកម្ពុជាទេ ។ ស្រីអូន បានបញ្ជាក់ថា គាត់ខ្លាចការបែកបាក់គ្រួសារ កាប់សម្លាប់ និង ការធ្វើទារុណកម្ម ។

ប៉ុន្តែ នៅពេល ស្រីអូន ទៅទស្សនាសារមន្ទីរជាតិ បានធ្វើឲ្យស្រីអូន មានអារម្មណ៍ធូរស្បើយ និងសប្បាយចិត្តក្នុងការដើរមើលរូបបដិមាតំណាងឲ្យព្រះ និងស្វែងយល់បានខ្លះ ។

◆ លឹម ស្រីឈីង ដែលបានចូលរួមកម្មវិធីតាំងពិព័រណ៍បានឲ្យដឹងថា នេះគឺជាលើកទីមួយហើយដែលឪពុកម្តាយរបស់គាត់អនុញ្ញាតឲ្យគាត់មកភ្នំពេញតែម្នាក់ឯង ព្រោះកន្លងមកខ្ញុំមិនដែលដើរទៅណាឆ្ងាយពីផ្ទះទេ ។ នេះជាលើកទីមួយសម្រាប់គាត់ដែលសាលាហ្វារពន្លឺសិល្បៈ បានឲ្យសិស្សឆ្នាំទី១ បានធ្វើការទាក់ទងជាមួយនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងបានធ្វើដំណើរទៅធ្វើទស្សនកិច្ចសិក្សាសារមន្ទីរជាតិ និងសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងដើម្បីស្វែងយល់ពីប្រវត្តិសាស្ត្រនេះ ។ គាត់មានការភ្ញាក់ផ្អើលពេលដែលបានទស្សនាខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "កុំស្មានបងភ្លេច" ក្នុងវគ្គមុនខ្មែរក្រហមចូលមក គាត់សង្កេតឃើញមានការសប្បាយរីករាយ និងមានការរីកចម្រើនជឿនលឿនជាមួយនឹងផ្នែកសិល្បៈ ។ ប៉ុន្តែបន្ទាប់ពីសង្គ្រាមចូលមក និងការលុកលុយពីក្រុមខ្មែរក្រហម បណ្តាលឲ្យសិល្បៈខ្មែរមានការធ្លាក់ចុះ និងស្ទើរតែសាបសូន្យ ។ នៅពេលអាន និងស្តាប់រឿងរ៉ាវសម័យខ្មែរក្រហម ធ្វើឲ្យគាត់មានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំងដោយសារប្រជាជនក្នុងសម័យនោះ បានបាត់បង់បងប្អូន ញាតិសន្តានរបស់ខ្លួន ។ ឈីង បានបន្តថានៅសម័យនោះ ប្រសិនបើនរណាហ៊ាននិយាយថា ខ្លួនជាអ្នកចម្រៀងពីសង្គមចាស់ ឬអ្នករៀនសូត្របានខ្ពង់ខ្ពស់ គឺត្រូវបានយកទៅសម្លាប់ចោលមិនខាន ។ នៅពេលគាត់បានទស្សនាខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "កុំស្មាន


និស្សិតសាលាហ្វារពន្លឺសិល្បៈនៅខេត្តបាត់ដំបង មកធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរជាតិ ក្រុងភ្នំពេញ ។

បងភ្លេច» គាត់មានអារម្មណ៍ សោកស្តាយស្រណោះជាខ្លាំង ហើយមិនគួរមានរឿងដូច្នេះកើតឡើងនៅក្នុងប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជាទេ ។ ជាចុងបញ្ចប់ ឈើង បានសម្តែងនូវអារម្មណ៍សប្បាយរីករាយយ៉ាងខ្លាំងដែលបានដើរទស្សនកិច្ចនៅទីក្រុងភ្នំពេញ ព្រោះបានធ្វើឲ្យគាត់ស្គាល់ការរស់នៅក្នុងសង្គម ហើយសូមអរគុណយ៉ាងខ្លាំងលោក ឆាំង យុ ដែលបានផ្តល់ការងារក្នុងការលើកកម្ពស់ប្រវត្តិសាស្រ្ត និងសិល្បៈខ្មែរឲ្យមានការរីកចម្រើន និងមានកេរ្តិ៍ឈ្មោះឡើងវិញ ។

◆ ព្រះតេជគុណព្រះនាម យ៉េន ស៊ីណា ជាសិស្សហ្វារពន្លឺសិល្បៈ ឆ្នាំទី១ សូមចម្រើនពរលោក ឆាំង យុ ស្ថាបនិកវិទ្យាស្ថានស្លឹករឹត និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព្រះតេជគុណមានសេចក្តីរីករាយជាពន់ពេក ដែលលោកនាយកបានសហការជាមួយសាលាហ្វារពន្លឺសិល្បៈ ដើម្បីរៀបចំគម្រោងរចនាប្លង់អាគារនៅរាជធានីភ្នំពេញ ឲ្យប្រែក្លាយទៅជាអាគារមួយដែលផ្សារភ្ជាប់ទៅនឹងសិល្បៈខ្មែរ ។ ព្រះតេជគុណគិតថា ប្រសិនបើគម្រោងនៃការរៀបចំទីក្រុងភ្នំពេញ ដែលបានផ្តោតទៅលើការរចនាអាគារខ្ពស់ៗ ដោយភ្ជាប់ទៅនឹងអត្តសញ្ញាណរបស់ជាតិបានសម្រេចដោយរលូនមែននោះ ពិតជាល្អប្រសើរខ្លាំងណាស់ ។ ការរចនាប្លង់ក្រុងភ្នំពេញនេះ មានសារសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ទី១) បានធ្វើឲ្យប្រទេសកម្ពុជារបស់យើងបានទទួលស្គាល់ពីភ្ញៀវជាតិ និងអន្តរជាតិដែលមកកម្សាន្តនៅទីក្រុងរបស់យើង ។ ទី២) បានផ្សព្វផ្សាយសិល្បៈ និងអរិយធម៌ដ៏រុងរឿងនាសម័យបុរាណ ។ ទី៣) បានបន្សល់ទុកនូវស្នាដៃនៃការរចនាប្លង់ដោយកូនខ្មែរនៅសម័យមុន ។

ការធ្វើទស្សនកិច្ចសិក្សារយៈពេលមួយថ្ងៃដែលគាំទ្រដោយលោកនាយក ឆាំង យុ ព្រះតេជគុណពិតជាទទួលបានចំណេះដឹងច្រើនទាក់ទងសង្គម យល់ដឹងអំពីសិល្បៈ គំនូរ និងឧក្រិដ្ឋកម្មឃោរឃៅក្នុងរបបខ្មែរក្រហម ។ ព្រះតេជគុណយល់ពីគោលបំណងរបស់លោក ឆាំង យុ ដែលចង់ឲ្យសិស្សឃើញពីសន្តិភាពក្នុងប្រទេស និងភាពរីកចម្រើនគ្រប់វិស័យ ។ ព្រះតេជគុណ មានការចាប់អារម្មណ៍យ៉ាងខ្លាំងលើគម្រោងមួយនេះ អាត្មានឹងខិតខំធ្វើឲ្យល្អដើម្បីឲ្យគម្រោងមួយនេះទទួលបានជោគជ័យ ។ ព្រះតេជគុណមិនភ្លេចដែលលោកនាយកបានលើកយកទ្រឹស្តីរបស់លោក ពីកាសូ មកថ្លែងក្នុងអង្គប្រជុំថា «ការស្រមើលស្រមៃ គឺជាការពិត» ។

◆ និស្សិតម្នាក់ទៀតបានឲ្យដឹងថា គាត់បានទស្សនារឿងរ៉ាវពីអតីតកាលក្នុងអំឡុងទសវត្សរ៍៦០ និងដើមទសវត្សរ៍៧០ ធ្វើឲ្យគាត់នឹកដល់ទិដ្ឋភាពនាពេលនោះដែលសិល្បៈហាក់ដូចជារស់រវើកនៅចំពោះមុខគាត់នៅឡើយ ហើយបានអន្ទងដួងចិត្តសាធារណជនទាំងអស់ឲ្យលង់លក់ក្នុងសុបិន្ត រហូតនឹកស្រមៃទៅដល់ទិដ្ឋភាពនៃបទចម្រៀងនីមួយៗ ដែលភាគច្រើនអ្នកនិពន្ធបានបង្កប់អត្ថន័យតាំងពីទីតាំងភូមិសាស្រ្ត អាកាសធាតុពេលវេលា ទំនៀមទម្លាប់ ។ សូរសំឡេងដ៏ក្រអួនក្រអៅរបស់អ្នកចម្រៀងជំនាន់ដើមជាចំណុចទាក់ទាញចំពោះគាត់ដែលបានស្តាប់បទចម្រៀង ពេលកំពុងធ្វើការងារឬឈប់សម្រាកពីការងារ ។ នៅពេលស្តាប់បទចម្រៀងទាំងនេះប្រជាជនតែងតែរំសាយអស់នូវទុក្ខកង្វល់ទាំងឡាយ និងបង្កនូវបរិយាកាសសប្បាយរីករាយមិនចេះជិនណាយ ។ ប៉ុន្តែ នៅពេលដែលសង្គមខ្មែរជាពិសេសតន្ត្រីករវ័យក្មេងទទួលយកវប្បធម៌បស្ចិមប្រទេស ហើយបានវិវឌ្ឍខ្លួនក្រោមឥទ្ធិពលនៃវប្បធម៌នេះដែលមិនមានលក្ខណៈជាខ្មែរតាំងពីការស្លៀកពាក់ ការធ្វើខ្លួនឡូយឆាយដូចបរទេស ការរាំរែក ការច្រៀងធ្វើដូចបរទេស ហើយគិតតែរឿងសប្បាយរីករាយ និងភ្លើងពណ៌ ធ្វើឲ្យប្រទេសកម្ពុជាធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាមយ៉ាងឆាប់រហ័ស ។ សិល្បៈខ្មែរក៏ចាប់ផ្តើមបាត់បង់ជាបណ្តើរៗដោយសារសង្គ្រាម ដែលខ្មែរក្រហមបានបង្រួបបង្រួមប្រជាជនតាមជនបទឲ្យប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលដែលបណ្តេញសម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែង បានធ្វើឲ្យប្រជាជនខ្មែរជួបប្រទះសង្គ្រាម ធ្វើឲ្យខ្ទេចខ្ទាំហេដ្ឋារចនាសម្ព័ន្ធរបស់ជាតិ បាត់នូវធនធានមនុស្ស និងសិល្បៈ ។

ក្រោយរបបខ្មែរក្រហម វិស័យសិល្បៈរបស់ខ្មែរស្ទើរតែបាត់បង់ទាំងស្រុង ហើយសិល្បករជាច្រើនត្រូវបានខ្មែរក្រហមសម្លាប់ ។ ទោះបីយ៉ាងណា រហូតមកដល់បច្ចុប្បន្ន សិល្បៈនៅតែបម្រើតួនាទីក្នុងការអប់រំទាំងអារម្មណ៍ និងផ្លូវចិត្តក្នុងសង្គមដែលបែកបាក់ ហើយបានធ្វើឲ្យប្រជាជនដែលប៉ះពាល់ផ្លូវចិត្តបានធូរស្បើយ និងឈានទៅរកការផ្សះផ្សាជាតិទាំងមូល ។

**សោម ប៊ុនថន**

# ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ជាថ្ងៃកំណើតជីវិតទី២របស់ខ្ញុំ បាន៣៩ឆ្នាំហើយ

*មនុស្សសំណាងមួយនាក់ ក្នុងចំណោមមនុស្ស៥.០០០នាក់ ដែលមានជីវិតរស់នៅ រួចផុតពីការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម*

*ប្រវត្តិពិតៗជាច្រើនឆ្នាំមកហើយ ដែលខ្ញុំលាក់ទុកក្នុងចិត្ត...*

***(តពីលេខមុន)***

**មកដល់ភ្នំពេញ**

យើងបានធ្វើដំណើរតាមផ្លូវព្រះមុនីវង្សឆ្ពោះមកវិមានឯករាជ្យ និងទៅខាងឆ្វេងវាំង ក្រោយមកទើបខ្ញុំស្គាល់ថាកន្លែងនេះជាមន្ទីរក-៧ ដែលជាមន្ទីរទីរសាររបស់គណៈមជ្ឈិមបក្ស៨៧០ ។ កងទ័ព៣៥.០០០ នាក់បានឈរជាពីរជួរ ហើយមានបងៗឈរចាំធ្វើការជ្រើសរើស ក្នុងចំណោមនោះខ្ញុំបានស្គាល់ តាភុំ តាព្រហ្ម តាគី តាវុយ និងបងៗផ្សេងទៀត ដែលជ្រើសរើសយកកម្លាំងចំនួន៣០០នាក់ក្នុងចំណោម ៥.០០០នាក់ ។ រីឯអ្នកផ្សេងៗទៀតដែលមិនបានជ្រើសរើសត្រូវទៅធ្វើការតាមរោងចក្រ និងក្រសួងផ្សេងៗក្នុងរដ្ឋធានីភ្នំពេញ ។ តាភុំ បានចាប់ដៃខ្ញុំ ហើយបានសួរខ្ញុំថា “មិត្តឯងចេះបើកឡានអត់?” ខ្ញុំឆ្លើយតបទៅគាត់វិញថា “ខ្ញុំអត់ចេះទេ



រូបថតអតីតបុគ្គលិក នៅមន្ទីរ ក-១២ ថតនៅដើមឆ្នាំ១៩៧៨ នៅពេលទៅទស្សនាសិល្បៈ ដែលសម្តែងដោយក្រុមសិល្បៈរូម៉ានី នៅសាលមហោស្រពទន្លេបាសាក់ ។ រូបថតរាប់ពីឆ្វេង ៖ មិត្តនារី ខី មិត្តនារី អឿន មិត្ត សារិន (ម្ចាស់អត្ថបទ) មិត្ត សាន មិត្ត រី ហៅ រី ឆ្លុក មិត្ត សារុន ហៅ តាសាច់បុក និង មិត្ត សំ បើកឡានឲ្យទូតគុយបា ។

បង។» គាត់បន្តថា ចេះបររទេះគោដែរអត់? «ខ្ញុំក៏ឆ្លើយតបថា ចេះ។» ។ គាត់ក៏បានឲ្យខ្ញុំទៅមុំដែលមានយុទ្ធជន ប្រហែលជា៣០០ នាក់ រួចហើយបានបញ្ជូនយើងទាំងអស់គ្នាឲ្យទៅនៅមុខវាំង ត្រើយ ខាងក្បាលជ្រោយឲ្យកាប់ដីដាំបន្លែ ។ ធ្វើការនៅទីនោះបានប្រហែល ជា១០ថ្ងៃ បងវុយ ដែលជាគណៈមន្ទីរក-១២ បានទៅទីនោះ រើសយកកម្លាំងប្រហែល៣០នាក់ មកក-១២ ហើយបានសួរ ក្រុមរបស់ខ្ញុំថា មានមិត្តណាដាក់ពាក្យចូលបដិវត្តន៍មុនថ្ងៃ១៧ មេសា ទេ រួចគាត់ឲ្យលើកដៃ ខ្ញុំក៏បានលើកដៃ ។ គាត់ក៏បានរើស យកខ្ញុំម្នាក់ក្នុងក្រុមរបស់ខ្ញុំ ហើយឲ្យរៀបខោអាវមកចាំនៅកំពង់ ដរ ។ ការដែលទៅជ្រើសរើសនៅពេលនោះ បានយុទ្ធជនប្រហែល ៣០នាក់ សុទ្ធតែអ្នកមកពីភូមិភាគបូព៌ា ។ ចំណែកឯអ្នកមកពីភូមិ ភាគឧត្តរ ភូមិភាគឦសាន្ត ភូមិភាគនិរតី ភូមិភាគបស្ចិម ក៏បានមួយ ចំនួនដែរ សរុបទាំងអស់បានប្រហែលជាង១០០នាក់ ។ សូមបញ្ជាក់ ថា កន្លែងនេះជាទីជួបជុំរបស់កម្លាំងមកពីតាមបណ្តាភូមិភាគនៅ ទូទាំងប្រទេស ។ យើងទាំងអស់គ្នា ក៏បានមកចំការមន (ទល់មុខទី ស្នាក់ការរបស់គណបក្សប្រជាជនសព្វថ្ងៃ) កាលណោះហៅថា វិទ្យាល័យចាក់អង្រែលើ នៅទល់មុខមានឃ្លាំងឆេះមួយ ។ ពេល មកដល់អង្គការឲ្យកាប់ដីដាំបន្លែនៅមាត់ទន្លេជិតមន្ទីរក-៣ និង មន្ទីរក-១ ។ នៅត្រើយម្ខាងជាក្រុមសិល្បៈវិទ្យុជាតិកម្ពុជាប្រជា ធិបតេយ្យ ហៅក-៣៣ ។ ខ្ញុំនៅដាំបន្លែបានប្រហែលជាកន្លះខែ អង្គការក៏បានចាត់តាំងឲ្យចេញប្រមូលឡាន ដែលប្រជាជនចេញពី ទីក្រុងភ្នំពេញទុកចោលរាយប៉ាយនៅតាមផ្លូវជាតិលេខ១ ភ្នំពេញ អ្នកលឿង ច្បារអំពៅ ខាងស្រុកកោះធំ និងស្រុកស្អាង តាមផ្លូវ ជាតិលេខ៤ទៅកំពង់ស្ពឺ តាមផ្លូវជាតិលេខ៥ទៅព្រែកក្តាម តាមផ្លូវ ជាតិលេខ៣ ទៅត្រាំខ្នា-តាកែវ ដើម្បីយកមករៀបទុកដាក់ក្នុង ឃ្លាំងនៅក្នុងទីក្រុងភ្នំពេញ ដែលកាលណោះចែកចេញជា៥ក្រុម ។ យើងដើរប្រមូលឡានបានប្រហែល១ខែ បានរថយន្តរាប់ពាន់ គ្រឿងយកទៅទុកដាក់នៅក្នុងឃ្លាំងក្បាលថ្នល់ ដែលជាបន្ទាយ ទាហាន នល់ នល់ ទល់មុខរោងចក្រម្សៅមី និងបន្ទាយទាហានការ ពារ លន់ នល់ នៅចំការមនដាក់នៅបរិវេណក្រសួងកសិកម្ម ដាក់នៅ ឃ្លាំងលេខ៤ ឃ្លាំងលេខ៥ នៅក្នុងមន្ទីរ ក-៣ ខាងកើតទូតអាមេរិក ចាស់ និងដាក់នៅហ្គារាសហ្សង់កុងផ្សារថ្មី ដាក់នៅបរិវេណវត្ត ស្វាយដង្គំ ក្រោយប៉ុស្តិ៍លេខ៣សព្វថ្ងៃ ហើយទៅខាងលិចដែលគេ ហៅផ-១ ខាងផលិតថ្នាំសង្គមកិច្ច ទៅពីហ្នឹងទៀត ហៅមន្ទីរប-១ និងស្នាក់ការកណ្តាលរបស់ក-១២ ដែលមានទីតាំងនៅបរិវេណ ធនាគារមេគង្គសព្វថ្ងៃ ខាងជើងទល់នឹងទូតកូរ៉េ (សព្វថ្ងៃ ទូតអាល្លឺម៉ង់) ខាងត្បូងទល់នឹងផ្លូវកែង សាលាយុគន្ធរ ផ្លូវកែងពេទ្យចិន និងចុះមក ខាងលិចពផ្លូវទៀតដែលជាកន្លែងទុកដាក់រថយន្តរបស់ថ្នាក់ដឹកនាំធំៗ ដូចជា ប៉ុល ពត អៀង សារី ខៀវ សំផន នួន ជា និងឡាន សម្រាប់ ដឹកទទួលគណៈប្រតិភូបរទេស ។ រថយន្តទំនើបៗដែលថ្នាក់ដឹកនាំ កំពូលៗជិះ ទុកនៅមន្ទីរក-១២ ទាំងអស់ ។ ថ្នាក់ដឹកនាំជិះតែឡាន ឡុំប្រឹតា ហុងដា ស៊ុយស៊ុយគីដាក់ដំបូល ក្រណាត់ គឺកម្រមានអ្នក ណាស្គាល់ពីអត្តសញ្ញាណរបស់ថ្នាក់ដឹកនាំធំៗទាំងនេះណាស់ លើក លែងតែអ្នកនៅជាមួយទើបបានស្គាល់ដូចជារូបខ្ញុំជាដើម ។ មន្ទីរក -១២ នេះជាមន្ទីរបើកបររបស់អង្គភាពបរទេស គឺសម្រាប់ដឹក ភ្ញៀវបរទេស និងថ្នាក់ដឹកនាំធំៗមកពីបណ្តាស្រុក តំបន់ និងភូមិភាគ ទូទាំងប្រទេស របស់គណៈមជ្ឈិមបក្ស៨៧០ ព្រោះក្នុងលិខិតបើក ផ្លូវរបស់ខ្ញុំ មានដាក់ឈ្មោះថា អង្គភាពបរទេស និងហត្ថលេខា ក្នុងលិខិតបើកផ្លូវ ដាក់ថា គណៈមន្ទីរ៨៧០ ឈ្មោះ សមមិត្ត ខាង តែខ្ញុំអត់ស្គាល់មិត្ត ខាង នោះជានរណាទេ ។ ក្រោយមកមានការ ចាត់តាំងពីគណៈមន្ទីរក-១២ ឲ្យខ្ញុំ និងមិត្តដទៃទៀតនៅក្នុងកងរបស់ បង ថេន ទៅរុះយកស័ង្កសី និងឈើនៅមន្ទីរបឹងត្របែកដែលជា សាលាភាសារបស់គណៈមន្ទីរ៨៧០ ដោយនៅទីនេះសម្បូរទៅ ដោយសំណង់អនាធិបតេយ្យតូចៗជាច្រើន នៅពាសពេញបឹង ត្របែកដែលមានប្រធានមន្ទីរបឹងត្របែក ឈ្មោះបង សាវ៉ន ។ បង សាវ៉ន មានរាងស្តើង កម្ពស់ប្រហែល ១.៦០ ទៅ១.៦៥ម៉ែត្រ ។ ដែកស័ង្កសី និងឈើទាំងអស់ត្រូវយកទៅធ្វើជារបងនៅវាំងនៅ ប្រាសាទខេមរិនសព្វថ្ងៃ ដែលការធ្វើរបងនេះ មានកម្ពស់ឡើងទៅ លើតដែកបីសន្លឹកឯណោះ មានដែកខ្លះចាស់ ដែកខ្លះថ្មី មើលទៅ ដូចជាមិនល្អមើលសោះ ។ ប្រធានខ្ញុំបាននិយាយថា និងបង សាំ បាននិយាយប្រាប់ខ្ញុំថា ខៀវ សំផន ក៏ជាមនុស្សជាប់និន្នាការ នយោបាយ តំណាងរាស្ត្រពីសង្គមចាស់ដែរ អ៊ីចឹងអង្គការយក អ្នកទាំងពីរដាក់នៅក្នុងហ្នឹង ហើយបង សារូ ក៏និយាយថា រាជវង្ស ស្តេចទាំងអស់ ដែលគស៊ូនៅក្នុងសម័យសង្គ្រាម ។ ក្រុមអ្នកដឹកនាំ

ដែលមកពីភាគខាងជើងវៀតណាម និងក្រុមអ្នកតស៊ូផ្ទៃក្នុងជាមួយ លន់ នល់ បានត្រូវអង្គការបដិវត្តន៍សម្លាប់ចោលទាំងអស់ ។ ឧទាហរណ៍ជាក់ស្តែងដូចជា ហ៊ូ យន់ ដែលជំទាស់នឹងការដែលមិនឲ្យជម្លៀសប្រជាជនចេញ ពីទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧៥ និងឲ្យប្រជាជនមានការចាយវាយ ជារូបិយបណ្ណ ដូចជាក្រដាស់ប្រាក់រូបគោ និងប្រជាសប្រាក់ផ្សេងៗទៀត ក៏ត្រូវអង្គការយកទៅសម្លាប់ចោលក្នុងទន្លេសាបដែរ ។ ដល់មក ឥឡូវនេះ អង្គការយើងយកសម្តេច នរោត្តម សីហនុ និង ខៀវ សំផន មកដាក់គុកនៅទីនេះទៀត អីចឹងពួកមិត្តត្រូវធ្វើរបងនេះឲ្យមាំ ឲ្យជាប់ ។ តាមប្រវត្តិរបស់បង សារ៉ូ និងបង ជីម ធ្លាប់បានដឹកសម្តេច នរោត្តម សីហនុ ពេលដែលព្រះអង្គយាងមកទស្សនកិច្ចតនៅក្នុងទឹកដី តំបន់រំដោះកាលពីឆ្នាំ១៩៧៣ ពេលនោះផ្លូវលោក់ផង ផុងដីខ្សាច់ផងបង សារ៉ូ ជាន់ហ្គាឡានគ្មានប្រណីទេ ពេលនោះសម្តេច សីហនុ ក៏ត្រូវទង្គិចបែកឈាម មាត់ សម្តេចក៏ មានបន្ទូលថា សម្តេចបានបូជាឈាមស្រស់ជូនមាតុភូមិកម្ពុជាខ្ញុំហើយ ។ នេះតាមគាត់តំណាលរឿងប្រាប់ខ្ញុំ គាត់ក៏អស់សំណើច ហើយបន្តថា គ្រាន់តែឈាមមាត់បន្តិចក៏មានបន្ទូលថា បូជាឈាមស្រស់ជូនមាតុភូមិដែរ រួចហើយក៏នាំគ្នាសើច ។ យើងធ្វើការរួចក៏មក ហូបបាយនៅផ្ទះសម្តេច ហ៊ុន សែន សព្វថ្ងៃផ្នែកខាងជើងដែលកាលណោះ សម្តេច ប៉ែន នុត ស្នាក់នៅ ។ រីឯផ្ទះបាយនៅផ្ទះសម្តេច ស ខេង ដែលប្រពន្ធ សម្តេច ប៉ែន នុត ធ្វើចុងភៅដោយផ្ទាល់ ។ គាត់មានសម្បុរស ហើយនៅក្មេង ចំណែកសម្តេច ប៉ែន នុត ចាស់ហើយ ។ នាសម័យកាលនោះ មានតែអ្នកបើកបររថយន្តនៅក្នុងមន្ទីរក-១២ នេះទេ ដែលមានសេរីភាពបានដើរតាមបណ្តាភូមិភាគ តំបន់ ស្រុកទូទាំងប្រទេស ក៏ដូចជានៅក្នុងទីក្រុងភ្នំពេញ ។

ខ្ញុំបានជូនភ្ញៀវតាមមន្ទីរ ក្រសួង ជុំវិញមន្ទីរ៨៧០នេះ និងជុំវិញ មន្ទីរស-៧១ ដែលមានឈ្មោះមន្ទីរដែលមានអក្សរ “ក” នៅពីខាងមុខ ។ តាមខ្ញុំចាំ ក-១ ជាកន្លែង ប៉ុល ពត នៅ ក-៣ ជាកន្លែងដែល នួន ជា នៅ ហើយក្រោយមក ខៀវ សំផន ក៏នៅទីនោះដែរ ។ នេះ ក-១ និងក-៣ មានទីតាំងពីវិមានឯករាជ្យទៅដល់ទូតអាមេរិកចាស់ ឡើងទៅខាងកើត ដល់មហោស្រពទន្លេបាសាក់ ។ អគារប៊ូឌីញទឹករលក ហើយខាងត្បូងជាកន្លែងវិទ្យុទាក់ទងប្រហែលជាក-៨ ឬ ក-១៨ របស់មិត្ត សួស ខាងក្រោយទូតអាមេរិក ។ ក-២ នៅខាងជើងរោងកុនវិមានទិព្វ ក្រោយមុំស្ពានទូតដែលប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ ។ ក-៤ នៅបឹងកេងកង ដែលមានអ្នកគ្រប់គ្រងឈ្មោះ តាព្រហ្ម ខាងកាត់ដេរ របស់មន្ទីរស-៧១ ។ ក-៥ នៅសាលានយោបាយបច្ចេកទេសសូវៀត បង្រៀនដោយសមមិត្ត ភុំ ។ កាលពីចុងឆ្នាំ១៩៧៥ ខ្ញុំបានរៀននៅទីនេះ រៀនវគ្គនយោបាយ មានន័យថា រៀនត្រឹម១០ថ្ងៃចុះ ហៅថាវគ្គនយោបាយ ។ ក-៦ ជាសាលានយោបាយមជ្ឈិមដែរ ដែលមានទីតាំងនៅបុរីកីឡា តាមខ្ញុំដឹងគឺសម្រាប់បង្រៀនកម្មាភិបាលមកពីគ្រប់បណ្តាភូមិភាគ តំបន់ ស្រុក ឃុំ នៅទូទាំងប្រទេសមករៀននយោបាយនៅទីនោះ ។ ក-៧ ដែលជាមន្ទីរនីរសារ របស់មជ្ឈិមបក្ស៨៧០ មានទីតាំងនៅមុខវាំងផ្នែកខាងឆ្វេងរហូតដល់សួនច្បារ វាលព្រះមេរុ ។ ក-៣២ មានទីតាំងនៅព្រែកព្នៅជាកន្លែងចិញ្ចឹមត្រី និងចិញ្ចឹមជ្រូកដែលមានប្រធានឈ្មោះសមមិត្ត ឌឹម ហើយក្រោយ មក ឌឹម មកកាន់មន្ទីរក-១ និងក-៣ ហើយឡើងសមមិត្ត មួន ជំនួស វិញ ។ បន្តបន្ទាប់ទៀតកន្លែងលត់ដំមាននៅព្រែកព្នៅមួយ នៅព្រែកប្រា ខាងជើងវត្តជំពុះក្អែកមួយកន្លែង និងនៅតាឡី (បច្ចុប្បន្នក្បែររោងចក្រស្រាបៀរ) មួយកន្លែង និងកន្លែងលត់ដំរបស់ក្រសួងការបរទេស នៅ ប-២០ នៅខាងស្រុកស៊ីងគ្រន់ ។ កន្លែងលត់ដំមួយទៀត នៅវត្តស្លែង ខាងលិចពោធិ៍ចិនតុង វត្តជ័យឧត្តមតាមផ្លូវទៅកំពង់កន្ទួតផ្លូវជាតិលេខ៣ ។ រីឯមកខាងលិចវាលព្រះមេរុវិញ គឺទីស្នាក់ការពាណិជ្ជកម្មតាម បណ្តាភូមិភាគបូព៌ា និរតី ឧត្តរ ពាយ័ព្យ ឦសាន្ត ឡើងទៅជួរមាត់ទន្លេមុំផ្សារចាស់ រហូតដល់រង្វង់មូលវត្តភ្នំ គឺជាបរិវេណរបស់ឃ្លាំងរដ្ឋ ។ នៅតាមទន្លេជាអគ្គភាពដឹកជញ្ជូនជើងទឹកមុំស្ពានជ្រោយចង្វារ រហូតដល់ឃ្លាំងប្រេងប៊ុស្សីកែវ ជារបស់ក្រសួងថាមពល ។

## ការជូនដំណើរគណៈប្រតិភូ

នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ខ្ញុំបានជូនដំណើរគណៈប្រតិភូដែលជាកម្មាភិបាលមក សិក្សានយោបាយនៅសាលាបុរីកីឡាដែលជាសាលានយោបាយមជ្ឈិម ។ ក្រោយពីគាត់បានសិក្សាចប់ ខ្ញុំ និងមិត្តដទៃទៀត នៅក្នុងមន្ទីរក-១២ បានជូនដំណើរពួកគាត់ដើរទស្សនកិច្ចនៅតាមបណ្តាភូមិភាគមាន ភូមិភាគបូព៌ា ភូមិភាគឧត្តរ តំបន់

សៀមរាប-ឧត្តរមានជ័យ ភូមិភាគពាយ័ព្យ បានឡើងទៅភូមិភាគនិរតី និងទៅទស្សនកិច្ចឆ្នេរសមុទ្រ និងក្រុងកំពង់សោម ដែលកាលណោះបក្សកុម្មុយនីស្តកម្ពុជាបានឲ្យទង់កិត្តិយសចំនួនបីស្រុក ដើម្បីឲ្យសិក្ខាកាមដែលជាកម្មាភិបាលមកពីតាមបណ្ដាស្រុក តំបន់ និងភូមិភាគដែលរៀនសូត្រ តាមគំរូវីរភាព និងភាពជឿនលឿនក្នុងវិស័យបង្កបង្កើនផលបានគ្រប់ផែនការរបស់បក្ស ដែលកាលណោះខ្ញុំនៅចាំមតិរបស់សមមិត្ត ភុំ ដែលជាអ្នកដឹកនាំគណៈប្រតិភូ បាននិយាយថា ការដែលឲ្យសិក្ខាកាមមករៀនសូត្រនេះគឺ ដើម្បីឲ្យរៀនសូត្រយកតាមគំរូស្រុកទាំងបី ទី១ ស្រុកប្រសូត្រ នៅក្នុងតំបន់២៣ ក្នុងភូមិភាគបូព៌ា ទី២ ស្រុកកំពង់ត្រឡាចលើ ស្ថិតក្នុងតំបន់៣៣ ភូមិភាគបស្ចិម និងទី៣ ស្រុកត្រាំកក់ ស្ថិតនៅក្នុងភូមិភាគនិរតី ។ នៅក្នុងពិធីជប់លៀងមួយរបស់គណៈប្រតិភូដែលជាកម្មាភិបាលដឹកនាំមកពីទូទាំងប្រទេស ធ្វើនៅឃ្លាំងប្រាក់ក្រុងកំពង់សោម ដែលមានអ្នកគ្រប់គ្រងឈ្មោះសមមិត្ត គ្រិន ។ ក្រោយពីដើរទស្សនកិច្ចតាមបណ្ដាភូមិភាគដែលមានរយៈពេលកន្លះខែចប់មក ក៏ត្រឡប់មកភ្នំពេញវិញ ហើយក៏បែកគ្នាទៅតាមភូមិភាគរៀងៗខ្លួន ។

នៅឆ្នាំ១៩៧៧ មានគណៈប្រតិភូបរទេសជាច្រើនដែលបានមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ មានដូចជា ប្រធានាធិបតីភូមា ឈ្មោះ អ៊ូនីវិន ប្រធានាធិបតីលាវ ឈ្មោះ សុផានុវង្ស លេខាបក្សកុម្មុយនីស្តចិនឈ្មោះ ឆឹង យុងគួយ ហៅតា ចាយ បានមកទស្សនកិច្ចនៅកម្ពុជា ប្រជាធិបតេយ្យនាសម័យនោះ ដែលខ្ញុំបានជួបផ្ទាល់ជាមួយមិត្តរួមការងារនៅក-១២ ។ ស្លាកលេខរថយន្តសម្រាប់ជូនភ្ញៀវកាលណោះ ផ្នែករថយន្តតូចដែលជារថយន្តប្រភេទទេសចរមានអក្សរ "ប" "ទ" នៅខាងដើម ចំណែកឯរថយន្តធំដែលជារថយន្តដឹកជញ្ជូន ដូចជា GMC (អាមេរិក) អាវីនរបស់ចិនមានស្លាកលេខដាក់អក្សរថា "ន" "ស" "ក" នៅខាងដើម ។

មុននឹងទៅទទួលគណៈប្រតិភូថ្នាក់ប្រធានាធិបតី អ៊ឹ អៀង សារី ហៅ វ៉ាន់ បានហៅ កម្មាភិបាល និងបណ្ដាមិត្តទាំងអស់ទាំងបីអង្គភាព ដែលអង្គភាពទី១ គឺអង្គភាពបើកបររថយន្តមានឈ្មោះ មៀល ជាប្រធាន អង្គភាពទី២ ជាអង្គភាពការពារភ្ញៀវ និងថ្នាក់ដឹកនាំ ប្រធានឈ្មោះ ខា មី និងភាគីអ្នកបម្រើមានធ្វើម្ហូប សណ្ឋាគារ និងខាងទីផ្សារដែលមានឈ្មោះ យាយ ស៊ីម ជាប្រធានក្រុមបម្រើ និងធ្វើម្ហូប និងសមមិត្ត ជៀម ជាប្រធានមន្ទីរប-១ ។ កាលណោះរៀនមួយកំណាត់ថ្ងៃនៅបរិវេណប-១ ដែលសព្វថ្ងៃជាទីស្ដីការគណៈរដ្ឋមន្ត្រី ។ អ៊ឹ អៀង សារី បាននិយាយថា យើងឈប់ស្លៀកពាក់ខោអាវខ្មៅៗទៀតទៅនៅពេលទៅទទួលភ្ញៀវបរទេស ត្រូវនាំគ្នាទៅកាត់ខោអាវដែលមានឯកសណ្ឋានដូចៗគ្នា នៅអូរឫស្សី (កន្លែងកាត់ដេររដ្ឋ) មានខោពណ៌ខៀវ អាវពណ៌ពងមាន់ ចាស់ក្នុងម្នាក់ពីរកំប្លេរ ទាំងអ្នកការពារ និងអ្នកបើកឡាន រួចឲ្យកាត់ស្បែកជើងជាស្បែកជើងសង្រែក ។ រីឯអ្នកបម្រើតាមសណ្ឋាគារ និងកន្លែងទីផ្សារបរទេស ត្រូវស្លៀកសំពត់ហូល ឬសំពត់ខៀវ អាវពណ៌ស ឬផ្កាឈូកដូចៗគ្នាជាលក្ខណៈសមូហភាព ។ តាមខ្ញុំចាំកាលសម័យហ្នឹង មានផ្សារបរទេសមួយសម្រាប់អង្គទូតប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ និងគណៈប្រតិភូបរទេស គណៈប្រតិភូដែលមកទស្សនកិច្ចសម្រាប់ភ្ញៀវបរទេសមកទិញ ។ ផ្សារនេះមានទីតាំងនៅសណ្ឋាគារស ខាងលិចផ្សារធំថ្មីផ្នែកខាងក្រោម ។ អ៊ឹ អៀង សារី បានលើកពីព្រឹត្តិការណ៍នយោបាយនៅក្នុង និងក្រៅប្រទេសមកនិយាយក្នុងអង្គប្រជុំថា ប្រទេសជាច្រើននៅលើសកលលោកចង់មកដាក់ទូតចងស្ពានមានមេត្រីជាមួយកម្ពុជាប្រជាធិបតេយ្យយើង ប៉ុន្តែប្រទេសខ្លះក៏យើងទទួលយក ប្រទេសខ្លះក៏យើងមិនទទួលយកដែរ ។ ប្រទេសកម្ពុជាយើងសព្វថ្ងៃ មិនមែនសម្បូរវុងរឿងសម្បូរហូបចុក ដូចដែលវិទ្យុផ្សាយនោះទេ តែនេះជានយោបាយរបស់បក្សយើង នៅខាងក្រៅប្រទេសក៏ដូចក្នុងប្រទេស ។ ប្រជាជនយើងកំពុងតែមានការខ្វះខាត ខ្វះសព្វខ្វះគ្រប់ តាំងពីជម្រក ទាំងស្បៀងអាហារ ទាំងថ្នាំសង្កូវ ។ អ៊ឹ អៀង សារី ក៏បានផ្ដាំផ្ញើថា សមមិត្តទាំងអស់ត្រូវប្រុងប្រយ័ត្នបដិវត្តន៍ថែមទៀត ពិសេសអ្នកបើកបរកុំឲ្យមានបុក ធ្លុះធ្លាយ ឬក្រឡាប់ ដែលជាហេតុប៉ះពាល់ដល់សុវត្ថិភាពរបស់ភ្ញៀវ ។ គណៈប្រតិភូ ប្រធានាធិបតីភូមា អ៊ូនីវិន មកទស្សនកិច្ចចំនួន៣ថ្ងៃដែលមានភាគីខាងកម្ពុជា មានអ៊ឹ ខៀវ សំផន ហៅ ហែម ជាអ្នកទទួលភ្ញៀវ ដោយមានអ្នកបើករថយន្តផ្ទាល់ខ្លួនឈ្មោះ ហឿន ហើយពិធីការបើកទ្វាររថយន្ត ឈ្មោះ ឈាន ដែលជាអតីតអភិបាលខេត្តប៉ៃលិនសព្វថ្ងៃ ។ ចំណែកគណៈប្រតិភូប្រធានាធិបតីលាវ សុផានុវង្ស បានមកទស្សនកិច្ចចំនួន ៣ថ្ងៃ ដែលមានអ៊ឹ ខៀវ សំផន ហៅ ហែម ជាអ្នកទទួលភ្ញៀវ ។

គណៈប្រតិភូបក្សកុម្មុយនីស្តចិនឈ្មោះ ឆឹង យុងគួយ ហៅ តាចាយ ដែលជាអ្នកបច្ចេកទេសខាងសេដ្ឋកិច្ចមកទស្សកិច្ចនៅកម្ពុជា មានរយៈពេល១៦ថ្ងៃ ដែលភាគីកម្ពុជា មាន ប៉ុល ពត ជាអ្នកចាំទទួលដោយផ្ទាល់ ។ គណៈប្រតិភូដែលមកទស្សនកិច្ចនៅកម្ពុជាចំនួនបីលើក មានរដ្ឋមន្ត្រីគ្រប់ក្រសួងទៅទទួលនៅព្រលានយន្តហោះពោធិ៍ចិនតុង រួចហើយនាំមកសម្រាកនៅវិមានរដ្ឋាភិបាលនៅមុខវត្តភ្នំ ។ មានការជប់លៀងនៅដំណាក់ចំការមន និងមើលសិល្បៈនៅមហោស្រពទន្លេបាសាក់ ទស្សនកិច្ចអង្គរវត្ត រាជវាំង ប្រសាទវិហារព្រះកែវមរកត ។

គណៈប្រតិភូចិនបានធ្វើដំណើរទៅភូមិភាគបូព៌ា ដោយមានរថយន្ត ប្រហែលជា៥០-៦០គ្រឿងជូនដំណើរគណៈប្រតិភូចិន ។ ខ្ញុំបាន បើកឡានទី១១ ពីភ្នំពេញទៅដល់ទន្លេបិទ-សួង ។ ពេលទៅដល់ទន្លេបិទ និងសួង មានតា សោ ភឹម ជាប្រធានភូមិភាគបូព៌ាមកទទួលគណៈប្រតិភូដោយឆ្លងតាមកប៉ាល់ និងមានរថយន្តពីរខ្សែមកទទួល ដែលមួយខ្សែមកពីកំពង់ចាម និងមួយខ្សែទៀតមកពីខាងទន្លេបិទ ។ រួចពីនេះក៏បន្តដំណើរទៅទស្សនកិច្ចនៅចម្ការកៅស៊ូជប់ ។ មើលចម្ការ កៅស៊ូមើលការដាំដុះ និងមើលរោងចក្រកិនដំរ និងបន្តទៅមើល តាមសហករណ៍ដូចជា សហករណ៍ជ្រោយបិទមាស នៅក្នុងភូមិស្រឡប់ ភូមិចិញ្ចើម នៅតាមដងផ្លូវធ្វើដំណើរ និងមើលវាលស្រែដែលស្រូវកំពុងតែចេញផ្លែផ្កានាខែវិច្ឆិកា ។ បន្ទាប់មកក្បួនរថយន្តគណៈប្រតិភូ បានមកសម្រាកនៅមន្ទីរភូមិភាគបូព៌ា (សាលាស្រុកត្បូងឃ្មុំ) ។

បន្ទាប់ពីនោះមក ថ្នាក់លើបានផ្លាស់ខ្ញុំឲ្យមកបើកឡានដឹកក្រុមកុន ដោយថ្នាក់លើយល់ឃើញថា ខ្ញុំប៉ិនប្រសព្វបើកឡានចល័តចុះឡើង ។ ការថតនេះ គឺថតសម្រាប់ទុកជាឯកសារអំពីថ្នាក់ដឹកនាំបរទេសដែលមកទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ហើយគណៈប្រតិភូបរទេសក៏បានថតយករូបភាព ដើម្បីយកទៅផ្សព្វផ្សាយនៅប្រទេសខ្លួនវិញដែរ ។ ពេលបើកឡានថតកុន ខ្ញុំបានមកសម្រាកនៅមន្ទីរភូមិភាគមួយយប់ ។ កាលណោះ ប៉ុល ពត សម្រាកជាន់លើ ខ្ញុំសម្រាកក្រោម ព្រោះពេលនោះ មិនមានផ្ទះសំណាក់ទេ រីឯភ្ញៀវចិនស្នាក់នៅផ្ទះខាងជើងដែលកាលណោះ មានផ្ទះសម្រាប់ស្នាក់នៅ៤ទៅ៥ខ្នង ។ ប៉ុល ពត ធ្លាប់បានដំណាលប្រាប់ភ្ញៀវចិនពីការរងគ្រោះថ្នាក់របស់ភូមិភាគបូព៌ាមានច្រើនជាងគេ ក្នុងអំឡុងពេលដែលផ្តល់បទសម្ភាសជាមួយអ្នកកាសែតចិន ។ ខ្ញុំមិនបានចាំថា អ្នកកាសែតនោះឈ្មោះ អ្វីទេ គ្រាន់តែដឹងថា ជាអ្នកដើរតាមគណៈប្រតិភូចិន ។ ប៉ុល ពត បានប្រាប់ទៀតថា ភូមិភាគបូព៌ាត្រូវរងគ្រោះដោយសារការទម្លាក់គ្រាប់បែក ។ សូមបញ្ជាក់ថា ប៉ុល ពត បានអមដំណើរប្រតិភូចិនឈ្មោះ ឆឹង យុងគួយ រហូតដល់ថ្ងៃបញ្ចប់នៃដំណើរទស្សនកិច្ច ហើយខ្ញុំក៏មានឱកាសបានឃើញ និងនៅក្បែរ ប៉ុល ពត ក្នុងចម្ងាយប្រហែល៤ ទៅ៥ម៉ែត្រពីប៉ុល ពត ។ ការណ៍បានឈរនៅក្បែរនេះដោយសារតែខ្ញុំនៅជាមួយក្រុមថតកុន ជាអ្នកជួយកាន់សម្ភារថតកុនដូចជាភ្លើងហ្វារ និងសម្ភារផ្សេងៗទៀត ។ ពេលនោះ ប៉ុល ពត បានលើកឡើងអំពី វិនាសកម្មសង្គ្រាម៥ឆ្នាំដែលអាមេរិកបានបំផ្លិចបំផ្លាញនៅក្នុងប្រទេសកម្ពុជា ដូចជានៅទីក្រុងសួង ត្រូវបានបាក់រាបដល់ដី ដោយសារការទម្លាក់គ្រាប់បែក ហើយភូមិនីមួយៗនៅសល់តែផេះផង់ ។

ក្រោយពីសម្រាកនៅទីនោះបានមួយយប់ ព្រលឹមឡើងក្បួនគណៈប្រតិភូបានបន្តធ្វើដំណើរមកភូមិភាគកណ្តាល ដើម្បីពិនិត្យមើលភាពជឿនលឿន ដូចជានៅរោងចក្រតម្បាញដែលជាស្នាដៃជំនួយរបស់មិត្តចិន ហើយក៏បានស្នាក់នៅភូមិភាគកណ្តាលមួយយប់ទៀត ។ អំឡុងពេលឈប់សម្រាកនៅភូមិភាគកណ្តាលនេះ សមមិត្ត កែ ពក ដែលជាគណៈភូមិភាគកណ្តាលជាអ្នករៀបចំទទួលខុសត្រូវ ។ ខ្ញុំចំណាំរូបរាងរបស់ កែ ពក បានខ្លះដែរ ។ កែ ពក មានមាឌធំដំបង មុខមានស្នាមសម្លាកដូចរលាកភ្លើង (មិនចាំច្បាស់ថាខាងឆ្វេងឬខាងស្តាំទេ) ហើយមានកម្ពស់ប្រហែលមួយម៉ែត្រចិតសិបប្រាំទៅមួយម៉ែត្រប៉ែតសិប ។ ក្រោយពីបានសម្រាកនៅទីនោះមួយយប់រួចមក ក្បួនគណៈប្រតិភូចិនក៏ចេញដំណើរបន្តទៀតទៅទស្សនកិច្ចនៅស្រុកចម្ការលើ ហើយបានស្នាក់នៅព្រៃចម្ការតាប្រុក ។ នៅតាប្រុក គឺនៅក្នុងព្រៃ មានចម្ការកាហ្វេ និងជាមូលដ្ឋានតស៊ូរបស់ថ្នាក់ដឹកនាំភូមិភាគកាលពីសម័យសង្គ្រាម ។ បន្តមកទៀតគណៈប្រតិភូចិនបានបន្តដំណើរទៅ ទស្សនកិច្ចនៅទំនប់៦មករា ។ ទំនប់នេះបានកសាងឡើងដើម្បីរម្លឹក ដល់ការវាយឈ្នះកងទ័ពយួន ហើយតាមអ្វីដែល កែ ពក បានលើកឡើងថា កងទ័ពកម្ពុជាប្រជាធិបតេយ្យ បានវាយឈ្នះទ័ពយួននៅឆ្នាំ១៩៧៦ នៅថ្ងៃ៦មករា

ហេតុនេះទើបដាក់ឈ្មោះទំនប់នេះថា «ទំនប់៦មករា» អ៊ីចឹងទៅដើម្បីឲ្យមានជាប់ជាប្រវត្តិសាស្ត្រ ។ ទំនប់នេះធំណាស់ ត្រូវបានធ្វើឡើងដោយកម្លាំងមនុស្សយ៉ាងច្រើន ។ មនុស្សជាច្រើនត្រូវបានអង្គការបញ្ជូនមកពីកងចល័តផ្សេងៗ ហើយនៅការដ្ឋានមានគ្រឿងចក្រតែពីរទេ គឺមានអាបុលកិនបង្ហាប់មួយ និងអាបុលរុញមួយ ក្រៅពីនោះមនុស្សជាអ្នកធ្វើទាំងអស់ បើមើលពីចម្ងាយទៅឃើញដូចជាសត្វស្រមោចកំពុងវារអ៊ីចឹង ។ ក្បួនរថយន្តរបស់គណៈប្រតិភូបានធ្វើដំណើរតាមខ្នងទំនប់ទៅស្ទឹងជីនិត និងវាលកំពង់ធំ ហើយបានសម្រាកនៅខេត្តកំពង់ធំ ។ ពេលនោះគណៈប្រតិភូបានសម្រាកនៅសណ្ឋាគារផ្ទះទឹក នៅពីលើបឹងមួយនៅក្រុងកំពង់ធំ ។ ព្រឹកឡើងក្បួនគណៈប្រតិភូចិន បានបន្តដំណើរមកដល់ស្ពានបុរាណស្ថិតនៅក្នុងស្រុកកំពង់ក្តី ខេត្តសៀមរាប និងបានចុះមើលស្ពាននោះទៀតផង ។ បន្ទាប់មក គណៈប្រតិភូបានបន្តដំណើរទៅតំបន់សៀមរាប-អង្គរ ដោយបានទស្សនកិច្ចអង្គរវត្ត អង្គរតូចអង្គរធំ វង់តូច វង់ធំ បារាណ៍ទឹកថ្លា ហើយបានសម្រាកនៅខេត្តសៀមរាបប្រហែលពីរយប់ ទើបបន្តដំណើរទៅភូមិភាគ ពាយ័ព្យបន្តទៀត ។

នៅភូមិភាគពាយ័ព្យ គណៈប្រតិភូទៅទស្សនកិច្ចនៅអាងទំនប់ត្រពាំងថ្ម ។ អាងត្រពាំងថ្មនេះធំណាស់ អាចបើកកប៉ាល់បាន ។ ខ្ញុំឃើញមានកប៉ាល់ពីរបីដែរនៅក្នុងទំនប់អាងត្រពាំងថ្មនោះ ។ បន្ទាប់មក គណៈប្រតិភូចិនបានបន្តដំណើរទៅទស្សនកិច្ចនៅកន្លែងធ្វើសូត្រ និងតម្បាញសូត្ររបស់តំបន់៥ ។ កាលនោះ មានសមមិត្ត រស់ ញឹម លេខាភូមិភាគពាយ័ព្យជាអ្នកទទួល ហើយខ្ញុំក៏បានចាំពីមុខមាត់ និងរូបរាងរបស់ រស់ ញឹម ខ្លះដែរ ។ រស់ ញឹម មានទឹកមុខញញឹមជាប់ និងមានកម្ពស់ប្រហែលមួយម៉ែត្រហុកសិប ឬហុកបីប៉ុណ្ណោះ មានរាងខ្ពស់ជាងខ្ញុំបន្តិច និងមានរាងធាត់ខ្មៅស្រអែម ។ ចំណែកគណៈតំបន់៥ វិញមានឈ្មោះ ជាល គឺជាកូនរបស់ រស់ ញឹម ។ បន្ទាប់ពីទស្សនកិច្ចនៅ តំបន់៥រួចរាល់ហើយ គណៈប្រតិភូបានទៅសម្រាកនៅស្វាយស៊ីសុផុន ហើយពេលនោះ ឆឹង យុងគួយ ក៏បានធ្លាក់ខ្លួនឈឺ ។ តាមការកត់សម្គាល់របស់ខ្ញុំឃើញថា ឆឹង យុងគួយ ហាក់មានវ័យចាស់ជាង ប៉ុល ពត ទៅទៀត ប៉ុន្តែមានមាឌធ្លោរធំជាង ប៉ុល ពត ។

តមក ក្បួនគណៈប្រតិភូចិនចេញមកខាងខេត្តបាត់ដំបង ដោយជិះ មើលវាលស្រែ តាមភូមិភាគពាយ័ព្យនេះ រួចបន្តដំណើរមកសម្រាក នៅផ្ទះភ្ញៀវម្តុំសាលាខេត្តបាត់ដំបង ។ សូមរម្លឹកថា ក្បួនគណៈប្រតិភូ ចិនទៅដល់ទីណា តែងតែមានមហាជន ប្រជាជនចាំទទួលយ៉ាងគគ្រឹកគគ្រេង ។ ចេញពីភូមិភាគពាយ័ព្យ ក្បួនបានបន្តដំណើរទៅខាងភូមិភាគបស្ចិម មកដល់ខាងក្រុងពោធិ៍សាត់ និងសម្រាកនៅពោធិ៍សាត់មួយយប់ ។ ព្រលឹមឡើង ក្បួនគណៈប្រតិភូចិនបានចេញដំណើរពីខេត្តពោធិ៍សាត់ ប៉ុន្តែលើកនេះ គណៈប្រតិភូចិនមិនបានជិះរថយន្តទេ គឺបានផ្លាស់ប្តូរដោយធ្វើដំណើរតាមរថភ្លើងម្តង ហើយក្បួនរថយន្តទាំងអស់ដែលមានពីរខ្សែបាននាំគ្នាទៅចាំនៅរ៉ាមាសនៅក្នុងខេត្តកំពង់ឆ្នាំង ដែលគណៈប្រតិភូត្រូវឈប់សម្រាក ។ បន្ទាប់ពីនេះមក គណៈប្រតិភូចិនបានបន្តដំណើរដោយជិះរថភ្លើងបន្តទៀត ទៅខាងខេត្តតាកែវភូមិភាគនិរតីម្តង ។ តាម៉ុក ដែលជាគណៈភូមិភាគនិរតី ជាអ្នកដឹកនាំគណៈប្រតិភូចិនដើរធ្វើទស្សនកិច្ច ។ កាលណោះ បានសម្រាកនៅតាកែវមួយយប់ ហើយក្រោយមកទៀត បានបន្តដំណើរទៅរោងចក្រចក្រី២ ដែលជាកន្លែងផលិតស៊ីម៉ង់ត៍ ដែលជាជំនួយរបស់មិត្តចិន និងទៅមើលទេសភាពវាលស្រែវាលស្រូវតាមតំបន់នេះ ។ បន្តមកក្បួនគណៈប្រតិភូចិនបានបន្តដំណើរទៅទស្សនានៅស្រែអំបិល បន្ទាប់មក គណៈប្រតិភូ ក៏បានបន្តដំណើរទៅកំពង់សោម ។ ទៅដល់កំពង់សោម ភ្ញៀវទាំងអស់បានស្នាក់នៅសណ្ឋាគារ៧ជាន់ ភ្ញៀវខ្លះស្នាក់នៅផ្ទះលើភ្នំដំណាក់ស្តេច ។ បន្ទាប់មក ភ្ញៀវទាំងអស់បានទៅទស្សនាឆ្នេរអូរឈើទាល និងទៅទស្សនានាវាពិឃាតដែលជាជំនួយរបស់មិត្តចិនដែរ ។ ជិះនាវាពិឃាតមានគណៈប្រតិភូចិន ឆឹង យុងគួយ ខាងខ្មែរមាន ប៉ុល ពត អៀង សារី និងរដ្ឋមន្ត្រីជាច្រើននាក់ទៀត បានជិះមើលឆ្នេរសមុទ្រខ្មែរ ។ នាវាពិឃាតនេះ មានល្បឿនលឿនណាស់ ដូចជាយន្តហោះអ៊ីចឹង បើតាមខ្ញុំស្មានល្បឿននាវានេះ ប្រមាណជាង១០០គីឡូម៉ែត្រក្នុងមួយម៉ោង ។ គណៈប្រតិភូបានចំណាយពេលនៅលើនាវាពិឃាតយូរគួរសមដែរ ចំណែកក្រុមខ្ញុំដែលជាអ្នកបើកបរ មិនត្រូវបានអនុញ្ញាតឲ្យឡើងជិះនាវានោះទេ គឺត្រូវធ្វើការរង់ចាំនៅឯប្រាំង ។ យើងជាអ្នកបើកសម្រាប់ផ្ទាក់ដឹកនាំមិនអាចដើរចោលរថយន្តបានទេ ។

**(តទៅលេខក្រោយ) ស សារិន**

# ព្រលឹងមាសម្តាយ

***(តពីលេខមុន)***


អ៊ុន វណ្ណា ម្ចាស់អត្ថបទ

ម៉ោងប្រមាណ៧យប់ ប្អូនតូចៗខ្ញុំលង់លក់មួយស្រឡឹតទៅហើយ ។ ខ្ញុំ និងអ្នកម្តាយនៅឡើយ យើងកំពុងតែព្រួយចិត្តនឹងដំណើរគេចខ្លួនរបស់លោកឪពុក ស្រាប់តែស្នូរក្រិកៗ រ៉ោករ៉ាកឮឡើងជុំ វិញផ្ទះខ្ញុំ យើងជ្រួលពោះវៀនឡើងដូចគេស្រាវ យើងក្រោកអង្គុយយ៉ាងប្រុងប្រយ័ត្ន ទាហានម្នាក់លូនមកដល់មុងយើង (តាំងពីសង្គ្រាមមក គ្រួសារណាក៏សម្រាន្តក្រោមផ្ទះដូចគ្នា ពីព្រោះវាងាយរត់ចូលលេណដ្ឋាន ម្នាក់និយាយថា យើងចាំតែមាត់រូងដូចសត្វកណ្តុរ) ។ ពុទ្ធោ! តើនរណា ព្រលឹងហើរចេញបាត់ពីខ្លួនយើងអស់ហើយ អ្នកម្តាយខ្ញុំ ទ្រហោយំងោងដោយប្រវាទឹបប្អូនពៅខ្ញុំជាប់នៅដៃគាត់ ចំណែកខ្ញុំប្រវាទឹបប្អូនពីរទៀតនៅដៃម្ខាងមួយ ។

ខ្ញុំទេតើ មីងកុំភ័យអី! ពូនៅឬទេ? វរសេនីយ៍ឯក ហម ពោលបណ្តើរដៃចាប់មុងសំឡឹងរកលោកឪពុកខ្ញុំបណ្តើរ ។

បង ហម ៖ ខ្ញុំគ្រាន់តែទទួលបញ្ជាពីមេបញ្ជាការខ្ញុំ ឲ្យខ្ញុំមកអញ្ជើញមីងឲ្យទៅរស់នៅឯព្រៃវែងជាមួយខ្ញុំទេតើ ។

ម្តាយខ្ញុំ ៖ ពូក្មួយឯងគាត់មានធុរៈទៅសួរលោកបង ឡាច ឈឺធ្ងន់ឯភូមិពាមស្តីតាំងពីម្សិលមិញ មិនទាន់ឃើញត្រឡប់មកវិញសោះ មីងព្រួយណាស់ ។ ស្រុកគេធ្វើសង្គ្រាម អង្ករឡើងថ្លៃដូចគេបោះពួយ ទំនិញសព្វសារពើឡើងថ្លៃដូចបោះពួយ តើឲ្យមីងទៅរស់នៅព្រៃវែងបានអីឲ្យកូនហូប?

បង ហម ពន្យល់ ចេះតែខំរកដូចគេឯងទៅ គេយ៉ាងណាយើងក៏យ៉ាងនោះដែរ បើពូមីងទៅ មារយាទ នឹងបានរៀនសូត្របើមីងមិនទៅទេ ប្អូនស្រីខ្ញុំច្បាស់ជាដាច់ចេញពីការសិក្សាហើយ ។ បើពូយល់ព្រមចូលទ័ព លោកមេបញ្ជាការខេត្តសន្យាថា បំពាក់ស័ក្តិជូនលោកពូជាអនុសេនីយ៍ឯក ។

ម្តាយខ្ញុំ ៖ ពូគ្មានចង់បានបុណ្យស័ក្តិប្រាក់ខែអ្វីទាំងអស់ គាត់ចង់តែរស់ដោយស្មោះត្រង់តាមសមាជីវៅ ។

ចំពោះខ្ញុំវិញ ឮពាក្យថាបានរៀន ខ្ញុំចង់ណាស់ តែខ្ញុំមិនហ៊ានជំទាស់នឹងម៉ែ ។

បង ហម លាចេញទៅ ទាហានរាប់សិបនាក់បានចាកចេញពីគុម្ពឈើជុំវិញផ្ទះយើង យើងញ័រព្រួចក្នុងពោះ ។ ឱ! មិនដឹងខ្លួនសោះថា បង ហម បាននាំទ័ពមកព័ទ្ធផ្ទះយើងជុំជិត យ៉ាងនេះសោះ បើកុំតែពុកគេចខ្លួនទាន់ច្បាស់ជាគេចាប់ហើយ ។ ឱ! ពេលនេះអ្វីទៅជាសាច់ឈាម អ្វីទៅមនោគមន៍វិជ្ជានៃនិន្នាការនយោបាយ? ខ្ញុំលួចសួរតែក្នុងចិត្តម្នាក់ឯង ។

តាំងពីដើមឆ្នាំ១៩៧២មក ព្រឹត្តិការណ៍កាន់តែលេចចេញប្លែកឡើងៗ តាមមិនទាន់ទាយមិនត្រូវ ស្មានមិនដល់គិតមិនយល់ទេ! ខ្ញុំចង់តែស្រែកឲ្យបែកផែនដី ។ ទោះបីខ្ញុំជាគ្រូពេទ្យបដិវត្តន៍នឹងគេដែរនេះ ខ្ញុំហាក់មិនយល់អ្វីទាំងអស់ ។ សង្គ្រាមឈ្លបដ៏ស្មៀមស្ងាត់នេះ ធ្វើឲ្យប្រជាជនកាន់តែភិតភ័យជ្រួលច្របល់ កាន់តែខ្លាំងឡើងៗ យុទ្ធសាស្ត្រសង្គ្រាមកាន់តែពិបាកយល់ ។ ស្ទើររាល់យប់មេបញ្ជាការកងទ័ពរំដោះបានប្រាប់មកប្រធានភូមិឲ្យដឹកនាំអ្នកស្រុកភៀសចេញពីតំបន់ប្រទាញប្រទង់ ទៅរស់នៅឯតំបន់រំដោះសិប ។ ប៉ុន្តែ រាល់ពេលមានសំណូមពរនេះ ឪពុកខ្ញុំតែងបានជោគជ័យជាដរាប ដោយការពន្យល់ថា សមរភូមិមុខ មិនអាចខ្វះសមរភូមិក្រោយបានទេ បើប្រជាជនរត់ចោលភូមិធ្វើស្រែលែងកើត តើបានស្បៀងអ្វីជួយជូនទៅទ័ព? ម្យ៉ាងទៀត នៅពេលយន្តហោះប្រុងទម្លាក់ម្តង គឺបានប្រជាជន នេះហើយជាជម្រកជាព្រៃម៉ាកគីរបស់កងទ័ពរំដោះ ព្រោះក្រោយពីបាញ់ប្រហារទៅលើទ័ពខ្មាំងចក្រពត្តិ

*រួច កងទ័ពរំដោះនៅពេលដែលមិនអាចរត់ចូលព្រៃទាន់ តែងតែរត់ចូលជ្រក ពួនក្នុងភូមិអ្នកស្រុកដែលអាចគេចផុតពីគ្រាប់បែក គ្រាប់ផ្លោងបាន តើពូនិយាយនេះត្រូវឬខុស? នេះជាសម្តី និងគោលជំហរជាក់លាក់ដែលលោកឪពុកខ្ញុំតែងតែបញ្ជាក់ជារឿយៗ ទៅកាន់កងទ័ពរំដោះ រាល់ពេលដែលពួកគេប៉ុនប៉ងជម្លៀសអ្នកស្រុកចេញពីភូមិ ។*

*ដោយភាគច្រើនសុទ្ធសឹងជាអតីតសិស្សវត្តរបស់អតីតព្រះចៅអធិការរូបនេះផង អ្នកទាំងនោះ ក៏ទទួលយកយោបល់លោកទាំងទើសទាល់ ។*

*មួយអាទិត្យក្រោយមក ទ័ពរំដោះបានវាយរុញច្រានទាហានឲ្យដកទ័ពចេញពីព្រៃកណ្តៀងជាថ្មីទៀតហើយ លោកឪពុកក៏មានឱកាសត្រឡប់មកផ្ទះវិញ ។*

*រាត្រីថ្ងៃទី៧ កុម្ភៈ វេលាម៉ោង១រំលងអធ្រាត្រ ស្រាប់តែមីង១៧នាក់ ក្នុងនោះមានជា អាទិ៍ គឺភរិយាពូ ហុង ភរិយាពូ សាយ ភរិយាពូ ថាន់ ដើរជាមួយគ្នាទាំងទ្រហោយំដង្ហក់មក ផ្ទះខ្ញុំ ។*

*លោកបងអើយ! គេចាប់ឪវាទៅបាត់ហើយ យកទាំងម៉ូតូទៅផង! មានតែលោកបងទេ ដែលអាចជួយបាន ។ សំឡេងខ្សឹកខ្សួលស្ទើរប្រេះដើមទ្រូងរបស់ភរិយាអភ័ព្វនៃអ្នកមាន ម៉ូតូជិះទាំង ៧នាក់ នៅភូមិខ្ញុំនៅពេលនេះលាន់ឮឡើងយ៉ាងតឹងបំពង់កស្ទើរប្រេះធ្លាយ ។*

*ឪពុកខ្ញុំ ៖ ហ៊ឺ! ពេលនេះសភាពការណ៍ស្មានមិនទាន់បានទេ ប្រហែលជាគេត្រូវការ ម៉ូតូជាយានប្រាស្រ័យការងារបដិវត្តន៍ ឬយ៉ាងណា ថាមិនត្រូវ ទ្រាំចាំមើល ចាំស្តាប់ដំណឹង ទៅមុខទៀត ។*

*មីងៗទាំងនោះឱបចង្កេះឪពុកខ្ញុំយ៉ាងជាប់ និងទ្រហោយំខ្លាំងៗឡើង "ហឺៗ លោកបងអើយ លោកបង អស់ហើយៗ បើត្រូវការម៉ូតូគួរយកតែម៉ូតូទៅ ហេតុអីក៏ចាំយកមនុស្ស ទៅទៀត ថែមទាំងចងដៃ និងឃ្លុំមុខទៀតផង គេចោទថា CIA របស់ អាមេរិករកនិយាយតទៅទៀតលែងចេញ ពួកគាត់ទន់ខ្លួនដូច សំឡី ។ ឪពុកខ្ញុំដកដង្ហើមធំយូរ ស្ទាបដៃមីងៗទាំង នោះស្រាលៗ ដោយធ្លាប់ជាទីសង្ឃឹមយ៉ាងកក់ក្តៅ ជាទីប្រឹក្សាដ៏ភ្លឺស្វាង ជាទីទំនុកចិត្តរបស់អ្នកភូមិទាំងមូល ។ ពីមុនមក ទ័ពរំដោះមានការចាប់ចងមនុស្សម្នាក់ ឬពីរនាក់ ដែលដើរហើរឆ្ងាយពីភូមិ ហើយច្រើនតែចាប់នៅពេលថ្ងៃផង ដែលលោកឪពុកធ្លាប់និមន្តព្រះសង្ឃទៅជួយសូមបិណ្ឌបាតដោះស្រាយយកអ្នកទាំងនោះមកភូមិវិញបាន ។ តែការចាប់មនុស្សពេលនេះ វាកើតឡើងនៅពេលយប់ ហើយមានចំនួនច្រើន និងដោយរបៀបសាហាវបែបនេះ គឺជាលើកទីមួយហើយ និយាយរួមពេលនេះ វាហួសពីសមត្ថភាពលោកឪពុកហើយ ហើយលោកក៏កំពុងបារម្ភនឹងសុវត្ថិភាពខ្លួនលោកយ៉ាងក្រាស់ក្រែលដែរ ។ ចំពោះ ខ្ញុំវិញ មកទល់ពេលនេះ ខ្ញុំកាន់តែលែងយល់ហើយ ថាតើបដិវត្តន៍គឺជាអ្វី ដើម្បីអ្វី និងដើម្បីនរណា? លោកពុកមានតែពាក្យមួយម៉ាត់នេះតបទៅមីងៗថា "អត់ធ្មត់សិនទៅ!" ។*

*ចូលឆ្នាំ១៩៧២នេះ ប្រជាជននៅទីនេះ កាលណាឃើញកងទ័ពធ្វើដំណើរកាត់មុខ គេលែងហ៊ានងើបមុខមើលទ័ពរំដោះទៀតហើយ គេឱនធ្វើការធម្មតា បើទ័ពទៅឆ្ងាយ ទើបលួចមើលតាមក្រោយ សភាពការណ៍ឆ្នាំនេះ ធ្វើឲ្យប្រជាជនរអាក្នុងចិត្ត ។*

*៦ថ្ងៃរំលងផុត គឺនៅថ្ងៃទី៨ កុម្ភៈ ឆ្នាំ១៩៧២ ខ្ញុំ និងអ្នកម្តាយកំពុងដកសំណាបនៅវាលប្រាំងខាងលិចវត្តស្តៅ ។ លោកឪពុកកំពុងភ្ជួរប្រាំងឯព្រែកល្បាប់ក្នុងចម្ងាយមួយគីឡូម៉ែត្រពីគ្នា ដែលបាំងគ្នាដោយព្រៃរនាមមួយវាលធំ មិនអាចមើលគ្នាឃើញ ។ កងទ័ពខោអាវខ្មៅមួយកាណូត បានបើករុករានគ្រប់ច្រកល្ហក តាមកូនប្រឡាយតូចបត់ចុះបត់ឡើង ត្រឡប់មកដល់គល់ព្រែកល្បាប់ ពួកគេបានប្រទះឃើញបុរសចំណាស់ មាឌធំដំបងនោះគឺ លោកឪពុកខ្ញុំ ដែលកំពុងទប់ភ្ជួរប្រាំងជាមួយ មារ៉ា ប្អូនប្រុសខ្ញុំអាយុ១០ ឆ្នាំ ។ កាណូតបុកប្រាំងគឺបចូលចត កងទ័ពខ្មៅ៤ទៅ៥នាក់ ហក់សំដៅលោកឪពុកខ្ញុំ ដោយមានកាន់ខ្សែចំណងក្នុងដៃផង ។*

*មេកងរបស់ទ័ពរំដោះក្រុមនេះ ដើរមុខគេបោះជំហានវែងៗ តាមភ្លឺប្រាំងដែលលោក ឪពុកខ្ញុំកំពុងទប់ គេដើរស្ទើរជាន់ដៃលោកហួសទៅមួយជំហានលោកឪពុកខ្ញុំឥតហ៊ានងើបមើលមុខគេទេ ។ គាត់ឱនលូនក្បាដីអាចម៍បំណាស់លើកមកទប់ភ្លឺដូចជាមិនដឹងខ្លួន ។ "ហុចដៃមក" មេកងនិយាយដោយសំឡេងគំហក ។ ញ័រពោះដូចគោកន្ត្រាក់ ទឹកមុខខ្មៅរលេ លោកឪពុកលាងជម្រះភក់ចេញពីដៃ ហុចដៃទាំងគូរបស់លោកទៅឲ្យគេចងដោយនឹងនរ ទំនងជាទុកចិត្ត ថា គេត្រឹមតែយកលោកទៅរៀនសូត្របុំណ្ណោះ ។ យោធាពីរនាក់ចាប់ទាញដៃទាំងពីររបស់លោកមកក្រោយចងស្ទាបក្រញឹតយ៉ាង*

ណែន រួចបញ្ជាឲ្យចុះទូក ។ ម៉ារ៉ា ប្អូនប្រុសខ្ញុំកំពុងដោះក្របីចេញពីនឹម ក្រោយពេលដាក់ពីភ្ជួរ បានយំខ្សឹកខ្សួល ដៃទាំងពីរញ័រទទ្រើករហូតជ្រុះចំណងសត្វពាហណៈទាំងពីរពីក្នុងដៃ ដោយមិនដឹងខ្លួន ។ លោកឪពុកត្រូវគេបញ្ជាឲ្យចុះទៅក្នុងទូកអណ្ដែតនៅបាតទូក ទឹកមុខគ្មានឈាម លោកខំស្រែកប្រាប់ ម៉ារ៉ា ទាំងអណោចអាធ័មថា "ទៅផ្ទះទៅកូន" ។

ទៅមិនបាន ឯងហ៊ានតែទៅប្រាប់ទាហាន លន់ នល់ អញ អាកឯងអស់មួយពូជ សម្រែករបស់មេបញ្ជាការទ័ពខេមរភូមិន្ទ ។ កាណូតដែលដឹកលោកឪពុកហ៊ុមព័ទ្ធដោយយោធាដែលកាន់អាវុធនិងគ្រាប់បែកដៃប្រុងប្រាង បានរំកិលចូលក្នុងព្រៃចេៗ នៅចម្ងាយប្រមាណ២០០ម៉ែត្រ ឯត្រើយម្ខាងព្រែកល្បាប់ទៅ ម៉ារ៉ា ឈរទន្ទ្រាំដីយំម្នាក់ឯងក្ដែងៗ គួរឲ្យខ្លោចផ្សារ អ្នកធ្វើប្រាំងក្បែរនោះ គ្មានអ្នកណាហ៊ានសួរនាំឡើយ បរិយាកាសពេលនេះ គឺងចង្អៀតវិស័យរន្ធត្តម្ហុល ។ យើងគ្មានដំណឹងអ្វីពីលោកឪពុកទេ ។

ម្ភៃថ្ងៃក្រោយមក អ្នកនេសាទម្នាក់បាននាំដំណឹងអំពីការបានឃើញសាកសពលោកឪពុកនៅទីដែលទូកចូលចតបន្ទាប់ពីចាប់លោកទៅភ្លាមៗនោះ ។ យើងសន្និដ្ឋានបានថា នោះគឺជាការចាប់ភ្លាមសម្លាប់ភ្លាម ។ លោកឪពុកបានក្លាយទៅជាជនអភ័ព្វដែលត្រូវគេចាប់ខ្លួនលើកទី២ បន្ទាប់ពីការចាប់ក្រុមអ្នកមានម៉ូតូទាំង៧នាក់ ប៉ុន្ដែលោកជាអ្នកដែលត្រូវសម្លាប់ដោយទ័ពរំដោះដំបូងគេបំផុតនៅភូមិ-ឃុំយើងនេះ ។ នេះជាសកម្មភាពដែលពុំធ្លាប់ពុំ ពុំធ្លាប់កើតមានទេពីមុនមក ។ ជំងឺបេះដូងរបស់អ្នកម៉ែបានរើឡើងវិញយ៉ាងធ្ងន់ ម៉ែឈឺ រងាររញ័រញាក់រហូតជ្រុះសក់អស់ ។ យើងមិនអាចតស៊ូនៅតំបន់ប្រទាញប្រទង់នេះតទៅទៀតបានទេ ដើម្បីអាយុជីវិតអ្នកម្ដាយ និងក្រែងលោមានឱកាសបន្តការរៀនសូត្របានផង ខ្ញុំសម្រេចចិត្តបបួលអ្នកម៉ែទៅរស់នៅឯតំបន់ទាហានកាន់កាប់ សីប វិញ ។

ឆ្នាំ១៩៧៣ ទីក្រុងព្រៃវែងសល់តែប្រឡង់ ផ្លូវគមនាគមន៍ព្រៃវែង-អ្នកលឿងត្រូវកាត់ផ្ដាច់ទាំងអស់ ទាំងផ្លូវគោក ទាំងផ្លូវទឹក ។ មានតែអ្នកមានបណ្ដាស័ក្ដិជាមេទាហាន មន្ត្រីជាន់ខ្ពស់ និងអ្នកមានទឹកប្រាក់ច្រើនទេ ដែលអាចធ្វើដំណើរតាមអេលីកុបមកភ្នំពេញបាន ។ បង គង់ បានឮដំណឹងទុក្ខសោកពីមរណភាពឪពុកខ្ញុំ គាត់បានរក មធ្យោបាយធ្វើដំណើរយ៉ាងផ្សងព្រេងគាត់ពេលយប់ងងឹតមួយមកខេត្តព្រៃវែង ដើម្បីសាកសួរសុខទុក្ខពួកយើង ។ ពេលមកកៀក បង គង់ សំឡឹងមើលទីក្រុងព្រៃវែង ក្នុងស្រមោលខ្មៅស្ដុងខាងមុខ គាត់មានកម្លាំងព្រឹស ព្រឺសម្បុរពេញខ្លួន គាត់ខំលោជហានឲ្យវែងៗអស់ពីលទ្ធភាព គាត់ពុំហ៊ានឆ្លងថ្នល់លេខ ១១ ជិតភូមិតាកោពេកទេ ខ្លាចប៉ះគ្រាប់មីន ដែលហ៊ុមព័ទ្ធបន្ទាយមូលដ្ឋានរបស់ទាហានរដ្ឋាភិបាល តែចៃដន្យអាក្រក់ ក្រុមល្បាតមួយក្រុមរបស់ទាហានបានចាប់បង គង់ ចូលបន្ទាយព្រៃវែង បន្ទុំឲ្យស្លៀកពាក់យោធា ហើយមិនអនុញ្ញាតឲ្យចេញពីបន្ទាយឡើយ ព្រោះខ្លាចគាត់ជាអ្នកមកស៊ើបយកការណ៍ ។ យើងបានឮដំណឹងនេះ បានតែទៅសួរសុខទុក្ខបង គង់ ដល់បន្ទាយ យើងបានសុំឲ្យបង គង់ ទៅរស់នៅជាមួយពួកយើង តែមួយខែក្រោយមកដោយនៅតែមាននិស្ស័យជាអ្នកបដិវត្តន៍ច្រើនជាង និងដោយមិនចុះសម្រុងទាល់តែសោះជាមួយភាពពក់ពុលពាលា អាវ៉ាសែ ក្បត់មនសិកា របស់ពលទាហានរដ្ឋាភិបាល បង គង់ ក៏សម្រេចចិត្តដោះខោអាវ ខ្សែក្រវ៉ាត់ទាហានរបស់គាត់ក្រវាត់ចោល ហើយរត់តម្រង់ទៅទីតាំងបញ្ជាការដ្ឋានយោធាដើមរបស់គាត់វិញ ។

ដោគវាសនារបស់ជនខ្សត់ខ្សោយក្រោមភ្លក់ភ្លើងសង្គ្រាមនេះ គេចមិនផុតឡើយពីត្រូវបង្ហូរឈាមលាងព្រះធរណីចិត្តលោភដែលស្រេកទារឈាមស្រស់សាច់ស្រស់របស់ប្រជាជនស្លូតត្រង់ខ្មែរ គ្មានបេះស្កប់ស្កល់នេះ ។ បង គង់ ត្រូវក្រុមកងឈ្លបខេមរភូមិន្ទ ចាប់វះដោយធាងត្នោតប្រកស្មៅ នៅជិតភូមិដង្កោរ ទុកជាឧទាហរណ៍នៃកំហឹងសន្ធោរសន្ធៅចំពោះខ្មាំងសត្រូវបដិវត្តន៍ ដែលជាជាតិខ្មែរដូចគ្នា ។ មួយអាទិត្យក្រោយពីបង គង់ រត់ចេញពីទាហានទៅ យើងបានដំណឹងពីការឃើញសាកសពគាត់នៅជិតភូមិតាកោ ដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រខាងកើតទីរួមខេត្តព្រៃវែង ។

គ្រួសារយើងបន្តរស់នៅក្រុងព្រៃវែងរហូតដល់ឆ្នាំ១៩៧៣ ដោយមានសល់មាសប្រាក់បន្តិចបន្តួច ខ្ញុំបន្តខិតខំព្យាបាលជំងឺអ្នកម៉ែផង ចាត់ចែងឲ្យប្អូនៗទៅរៀនផង ទៅរៀនខ្លួនឯងផង ដោយក្ដីលំបាកបំផុត ។

ដោយមានជំនួយ និងលិខិត និងសំណូមពរពីលោកមារ ថុង

 

(ប្អូនប្រុសម្តាយខ្ញុំ) នៅភ្នំពេញ ផ្តាំឲ្យខ្ញុំព្យាយាមនាំម៉ែ និងប្អូនៗមកភ្នំពេញ ។ ខ្ញុំបានព្យាយាមទៅរង់ចាំចុះឈ្មោះសុំជិះយន្តហោះនឹងគេទាំងប្រថុយនឹងគ្រាប់ផ្លោង និងទាំងគ្មានសង្ឃឹមសោះ ។ ថ្ងៃមួយ មានសប្បុរសជនមួយរូប គឺលោកស័ក្តិ៣ ស៊ុប ដែលជាអតីតសាស្ត្រាចារ្យកីឡារបស់ខ្ញុំ លោកបានទទួលវេណជាអ្នកគ្រប់គ្រងយន្តហោះមួយរយៈខ្លី ។ ក្នុងម៉ោងហាត់កីឡាមួយ ដែលលោកបង្ហាត់ខ្ញុំត្រូវធ្លាក់ពីអេស្កាវ៉ាទ័របាក់កដៃ លោកនៅចាំខ្ញុំច្បាស់ លោកដឹងពីប្រវត្តិខ្ញុំដែលត្រូវកំព្រាឪពុកដោយវៀតកុងសម្លាប់ លោកបានជួយសង្រ្គោះក្រុមគ្រួសារខ្ញុំឲ្យបានធ្វើដំណើរមកភ្នំពេញដោយឥតមានបង់ប្រាក់ថ្លៃយន្តហោះឡើយ ។ បើពុំមានជំនួយពីលោកទេ គ្រួសារយើងពិតជាពុំមានលទ្ធភាពបង់ប្រាក់ថ្លៃយន្តហោះមកភ្នំពេញឡើយ ។

ក្រោមការជ្រោមជ្រែងពីលោកមារ ថុង និងលោកអ៊ុំ សារី (បងប្រុសម្តាយខ្ញុំ) អ្នកម៉ែ បានធូរស្រាលពីជំងឺ ខ្ញុំក៏បានបន្តរៀនរហូតដល់បាក់អង់ (*Bac*១) ។

## មហាជ័យជម្នះអសុរកាយ

ភ្លៀងផ្គររន្ទះកំណាចនៃគ្រាប់កាំភ្លើងគ្រប់ធុន នៅខែមេសា ១៩៧៥ មហាព្យុះសង្ក្រាបក់បោកបាចសាចមកពីគ្រប់ទិសទីជុំវិញទីក្រុងភ្នំពេញ ។ ថ្ងៃមួយ ក្រោមមេឃរលឹមស្រិចៗស្គររន្ទះផាំងបានលាន់ឮឡើងយ៉ាងខ្លាំងនៅវត្តភ្នំ កន្ទ្រាក់ស្មារតីអ្នកទីក្រុងពេលនោះ ឲ្យរន្ធត់ស្ទើរលោះព្រលឹង ។ មួយថ្ងៃកន្លងមក បណ្តាញព័ត៌មានបានចុះផ្សាយព្រោងព្រាតពីរឿងរន្ទះបាញ់ចេតិយព្រះពញាយ៉ាត ព្រះរាជាទី១នៃការតាំងរាជធានីភ្នំពេញឡើង ។ ព័ត៌មាននេះ បានត្រូវប្រជាពលរដ្ឋភ្នំពេញ និយាយចេញស្ទើរគ្រប់មាត់ដោយចាត់ទុកថាជាប្រផ្នូលនៃការបែកបាក់ខ្ចាត់ខ្ចាយទីក្រុងភ្នំពេញ ។ ម្នាក់ៗសន្និដ្ឋានថា មិនយូរទេ កម្លាំងខ្មែរក្រហមមុខជានឹងចូលកាន់កាប់ទីក្រុងភ្នំពេញ សង្គ្រាមនឹងត្រូវបញ្ចប់ ប៉ុន្តែតើអ្វីទៀតនឹងកើតឡើងនោះ ពិបាកទស្សន៍ទាយណាស់ ។ នរណាក៏ដឹងដែរថា ប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្មែរក្រហមប្រែធាតុជាកង់ទ័ពដ៏សាហាវឃោរឃៅ គេពុំមែនធ្វើអ្វីៗដើម្បីពុកម៉ែប្រជាជនដូចឆ្នាំចាប់ផ្តើមនោះទេ ។ ប៉ុន្តែ មតិភាគច្រើនគិតថា ខ្មែរមិនដែលសម្លាប់ខ្មែររហូតទៅដល់ការបំផ្លាញប្រជាជាតិខ្លួនឯងនោះទេ ។ ការសម្លាប់ពេលទើសមុខក្នុងសង្គ្រាម ជាការពិបាកចៀសវាង ប៉ុន្តែគេនឹងមិនធ្វើដូច្នេះទៀតទេ ក្នុងពេលបានសន្តិភាពហើយ ។ ខ្ញុំ និងអ្នកម៉ែតែងតែជម្រាបលោកអ៊ុំ សារី សុំកុំឲ្យសារភាពឲ្យសោះថា លោកជាមេទ័ពមានបណ្តាស័ក្តិខ្ពស់ ពីព្រោះយើងធ្លាប់ស្គាល់ហើយ អ្វីដែលហៅថា កំហឹងបដិវត្តន៍របស់ពួកគេ ។ យើងជម្រាបទៀតថា ខ្មែរក្រហមប្រាកដជានឹងកៀរជម្លៀសអ្នកភ្នំពេញឲ្យចាកចេញពីទីក្រុង ព្រោះយ៉ាងហោចណាស់គេប្តូរកន្លែងយើង តែលោកអ៊ុំពន្យល់យើងថា អ៊ុំលួចស្តាប់វិទ្យុរំដោះយូរហើយ គេនិយាយតែពីការកសាង គេអាចកៀរជម្លៀសប្រជាជននៅពេលដែលមិនទាន់ទទួលបាន ជោគជ័យផ្តាច់ព្រ័ត្រ ចុះពេលមានជ័យជម្នះទូទាំងប្រទេសទៅហើយ តើជម្លៀសមនុស្សទៅណាទៀត លោកអ៊ុំចោទសួរមកយើងវិញ ។ ខ្ញុំមិនយល់ស្របតាមអ៊ុំទេ តែខ្ញុំមិនអាចឆ្លើយរួច ហើយខ្ញុំសូមបន់ស្រន់ក្នុងចិត្ត សូមឲ្យការយល់ឃើញរបស់លោកអ៊ុំក្លាយជាការត្រឹមត្រូវទៅចុះ ។

ទីក្រុងដ៏តូចណែនណាន់ទៅដោយប្រជាជនជាង២លាននាក់រស់នៅពាក់ពពូន ក្រោមផ្សែងគ្រាប់រំសេវទ្រហឹងអឹងអាប់បាចសាចក្លិនឈ្ងៀមហៀរហោះពេញលំហវេហា សាច់ឈាម និងឆ្អឹងប្រជាពលរដ្ឋខ្មែររបេះធ្លាក់ខ្ចាយរាត់រាយពាសពេញផែនពសុធា ថ្ងៃណាក៏មានការផ្ទុះគ្រាប់បែកផ្លាស្ទិកដែរ កងទ័ពរំដោះ និងភ្នាក់ងារផ្ទៃក្នុងបានបង្កប់ខ្លួន នៅពាសពេញទីក្រុងភ្នំពេញ ជាពិសេសរោងភាពយន្ត ជាកន្លែងដែលមានការផ្ទុះញឹកញាប់ជាងគេ ប៉ុន្តែអ្នកដែលជ្រួលជ្រើមប្រជ្រៀតគ្នាមើលកុន នៅតែរងើមដូចអណ្តើកចូលភ្លើង នៅតាមផ្លូវថ្នល់មនុស្សធ្វើដំណើរ ដោយប្រយ័ត្នប្រយែងណាស់ សូម្បីតែផ្ទាំងក្រដាសតូចមួយ ក៏ជាប់សង្ស័យថា អាចមានគ្រាប់ផ្លាស្ទិកបង្កប់ពីក្រោមដែរ ឈាមខ្មែរហូរជាថ្លុកនៅពាសពេញរដ្ឋធានី ។ នៅកណ្តាលទីក្រុង ហាងលក់ទំនិញ តូចធំបង្អួតសម្ភស្សយ៉ាងសង្ហារ ហាក់គ្មានព្រឺខ្លាចនឹងគ្រាប់រំសេវទាំងនោះទេ តាមបារនានា ភ្លើងពណ៌ លោតលេងតាម ចង្វាក់បទភ្លេងដែលស្រែកកញ្ឆ្រៀវយ៉ាងញញ័រញញាក់សព្វសាច់ កញ្ញារូបស្រស់ទាំងហ្វូងៗពាក់អាវវាលកធំៗ បញ្ចេញសាច់ខ្នងសស្គាច សំពត់ខើចបញ្ចេញគល់ភ្លៅ ស្បែកជើងកែងខ្ពស់យ៉ាងហួសសម័យ បញ្ចើចចិត្តមេទាហាន អ្នកជំនួញ អ្នកត្រូវបាន់ អ្នកត្រដររកល្ហើយ តាមកម្លាំង

 

ខ្យល់គួច ឲ្យព្រឺព្រួចស្រើបរំពើតរំពើននៅស្ងៀមមិនបាន ។ នៅតាមសាលារៀន និងមហាវិទ្យាល័យនានា ចលនាបាតុកម្មប្រឆាំងនឹងទំនិញឡើងថ្លៃ និងវិបត្តិនយោបាយ ផុសឡើង ជ្រួលច្របល់គ្មានស្រាកស្រាន្ត ។

តាំងពីមុនព្រលឹមស្រាងៗ នៃថ្ងៃ១៧ មេសា ព្យុះកំណាចនៃគ្រាប់កាំភ្លើងត្បាល់ និងកាំភ្លើងដៃបក់បោកវិលវល់ឆាបឆក់ គួចគ្របាញ់សង្គ្រប់មកលើទីក្រុងភ្នំពេញ ស្នូរកាំភ្លើង តូចធំ រោទ៍ឡើងពីគ្រប់ទិស ហើយកាន់តែរំកិលចូលមកទីក្រុងជិតឡើងៗ ។

នៅក្នុងក្រុង ពលទាហានខ្លះមានជំហរមិនទុកចិត្តសភាពការណ៍ទេ គេនាំគ្នាខំរូតរះ ដោះរូបថត និងខោអាវទាហានរកកន្លែងលាក់ចោលបំបាត់តាង ។ បណ្ដាកងទ័ពរដ្ឋាភិបាល អង្គភាពខ្លះ មានជំហររៀបចំក្បួនឡានក្បួនរថក្រោះលើកទង់សសុំចុះចាញ់ ទៅរង់ចាំទទួលសមមិត្តរំដោះគ្រប់ទិស នៅដើមមហាវិថីធំៗ ត្រង់ច្រកដំបូងនៃការចូលមកដល់ទីក្រុងភ្នំពេញ ។ ទង់ជាតិសាធារណរដ្ឋខ្មែរត្រូវបន្ហូតចុះ ត្រឹមពាក់កណ្ដាលដង វាមិនរេរាំទៀតទេ ផ្ទុយទៅវិញ វាបាក់ខ្លួនខ្ទបសម្របនឹងដងទង់យ៉ាងកំសត់ ។ វិទ្យុសំឡេងនៃរបបសាធារណរដ្ឋខ្មែរត្រូវបានកាត់ផ្ដាច់ស្ងាត់ត្រចៀកតាំងពីម៉ោង៨ព្រឹកមកម្ល៉េះ ។

ខាងទិសផ្លូវជាតិលេខ៥ នៅពេលដែលកងទ័ពខ្មៅបានធ្វើដំណើរមកដល់វត្តចិនដំដែកភ្លាម ទាហានរដ្ឋាភិបាលដែលមានការរៀបចំវន្ទនកិច្ចទុកជាមុនស្រេច បានសម្ដែងការ វន្ទាអាវុធ យ៉ាងឧត្តុង្គឧត្តម ចំពោះកងកម្លាំងសមមិត្តរបស់ខ្លួននោះ រួចចាប់លើកមេបញ្ជាការ រំដោះ ៤-៥ រូប ជ្រោងឡើងយ៉ាងខ្ពស់ ដោយភក្ដីភាព និងក្ដីគោរព ស្ងើចសរសើរ ចំពោះវីរភាពគំរូរបស់ទ័ពរំដោះ ។

ប៉ុន្តែការឆ្លើយតបវិញរបស់ទ័ពរំដោះនៅពេលនោះ គឺជាការភ្ជង់ចុងកាណុងដាក់ ទាហានរដ្ឋាភិបាល ហើយស្រែកគំរាមថា «លើកដៃឡើង» ដោយទឹកមុខចងកំហឹងយ៉ាងគ្មានរសាយ និងដោយស្មារតីប្រុងប្រយ័ត្នគ្រប់ពេលវេលា ។ ទាហានរដ្ឋាភិបាលគ្រប់រូប ដែលនៅទីនោះត្រូវបានគេស្ទាប ឬច្របាច់រកអាវុធ រួចត្រូវបានគេចាប់បេះយកនាឡិកាដៃ ខ្សែក ខ្សែដៃ អលង្ការ ដែលមាននៅជាប់នឹងខ្លួនយ៉ាងអមិត្ត ។ ក្រោយពីបានលុកលុយទីក្រុងភ្នំពេញអស់រយៈពេលតែប៉ុន្មានម៉ោងក្រោយមក អ្នកទីក្រុងភ្នំពេញគ្រប់ផ្ទះ បានត្រូវភ្ជង់ដោយអាវុធឲ្យរៀបចំចេញដំណើរ ។

គ្រួសារខ្ញុំ និងលោកអ៊ំ សារី បានធ្វើដំណើរប្រជ្រៀតជាមួយនឹងសមុទ្រមនុស្សរាប់សិបគីឡូម៉ែត្រ ។ តាមបណ្ដោយផ្លូវជាតិលេខ៥ ហាងសាំងគីឡូលេខ៦យ៉ាងធំ ត្រូវបានដុតបំផ្លាញ អណ្ដាតភ្លើងកំពុងឆាបឆេះយ៉ាងពេញក្រមុំ សន្ធោរសន្ធៅអស់រយៈ៣យប់ថ្ងៃទៅហើយ មិនទាន់ថយនៅឡើយ នៅតែជះកម្ដៅភាយៗ ក្ដៅស្ទើរខ្លោចសាច់មកលើហ្វូងមនុស្ស ដែលរុញគ្នាពាសពេញតាមផ្លូវជាតិ រទេះអ្នកជំងឺ ជរា ពិការ លាយនឹងសម្រែក ស្រែកដង្ហើយវង្វេងម្ដាយ វង្វេងកូន ទំនួញឈឺចាប់របស់អ្នកជំងឺសែនឈឺផ្សាររកអ្វីប្រៀបផ្ទឹមពុំបានទេ ថ្ងឹមប្រម៉ាត់ប្រជាជនខ្មែរពេលនោះហាក់ត្រូវចិញ្ច្រាំហែកពុះច្រៀករាប់រយចម្រៀកឲ្យយើងឈឺចុកពើតពេញដើមទ្រូង រកនិយាយមិនចេញទេ ។ ពេលយើងមកដល់គីឡូម៉ែត្រលេខ៧ សាកសពស្ត្រីម្នាក់ស្លាប់អង្គុយយ៉ាងទ្រលុកទ្រលន់នៅកណ្ដាលថ្នល់ជាតិ ឮចចាមអារ៉ាមតគ្នាថា គាត់ត្រូវគេបាញ់សម្លាប់ ដោយតមាត់មិនព្រមរៀបចំចេញដំណើរ ។ ផុតពីនោះ តែបន្តិចមក នៅតាមបណ្ដោយចិញ្ចើមផ្លូវជាតិទាំងសងខាង ក៏ដូចជានៅក្នុងដងព្រៃរិចៗ អមបណ្ដោយផ្លូវជាតិលេខ៥ ទាំងសងខាងសាកសពទាហាន ប្រុសស្រី មានលាយទាំងប្រជាជន ឥតអាវុធផង ដួលដេកគងគាក់លើគ្នា លើថ្លុកឈាម ដែលនៅក្រហមច្រាលពាសពេញដងផ្លូវ គ្មានសល់ចន្លោះដីនៅទំនេរឡើយ ។ ក្លិនអាសោចហោះហើរយ៉ាងហួសប្រមាណ ។

យប់ថ្ងៃ១៧ ដល់១៩ មេសា មហាភ្លៀងកំហឹងបោកប្រាណលើព្រះធរណីហូរលាង ខ្ទុះឈាម លាមក ខ្លាញ់ ជម្រះចេញពីសាកសព អាសុភទម្លាក់ទៅក្នុងអាងទន្លេមេគង្គ ឲ្យទទួលផ្ទុកនូវរសជាតិប្រៃ ឆ្អេះឆ្អាប អាសោចន៍នេះ ព្រះទាំងហូរនាំនូវសាកសពប្រុសស្រី ចាស់ក្មេង ឲ្យអណ្ដែតផ្កាប់ផ្ងារ ខ្លះអាក្រាតទទេ ខ្លះមានតែខោស្លីប ឲ្យហូរចុះទៅតាមខ្សែទឹក ធ្វើឲ្យហ្វូងមនុស្សរាប់លាននាក់តាមផ្លូវ ត្រូវតែប្រទះឃើញគ្រប់ៗគ្នា ម្នាក់ៗ ពោរពេញ ទៅដោយសេចក្ដីព្រឺរន្ធត់ស្លុត ស្រយុតអស់ពីដួងចិត្ត ។ មានតែព្រះគង្គានៃដងទន្លេមេគង្គ តែមួយគត់ដែលជាប្រភពទឹកបរិភោគ សម្រាប់អ្នកធ្វើដំណើររាប់លាននាក់នេះ ។

ពេលយើងទៅដល់វត្តគ្រោះ ចម្ងាយប្រមាណ២៥គីឡូ

ម៉ែត្រ ខាងជើងទីក្រុងភ្នំពេញ ជាអតីតប៉ុស្តិ៍ធំមួយរបស់ទាហានរដ្ឋាភិបាល ដែលជាខ្សែក្រវ៉ាត់ទី១ សម្រាប់ការពារទីក្រុង ភ្នំពេញ បានទទួលប្រជាជនរាប់ម៉ឺនគ្រួសារឲ្យស្នាក់នៅពេលយប់ ។ ដោយការនឿយហត់ នឹងដំណើរថ្មើរជើង ពេលទៅដល់វត្តគ្រោះ ប្រមាណម៉ោង១០យប់ គ្រួសារអ៊ំ សារី និង គ្រួសារខ្ញុំបានប្រជ្រៀតចង់មុននឹងគេ ដើម្បីសម្រាកយកកម្លាំងនៅទីនោះ លុះព្រលឹមឡើង ទើបឃើញក្បាលខ្មោចដែលកប់របើកដីនៅចុងជើង និងម្រាមជើង ម្រាមដៃខ្មោចដែលគេ កប់មិនជិតល្អ នៅលើក្បាលដំណេកយើង ។ រឿងបែបនេះ វាសាមញ្ញទៅហើយ ត្រចៀកយើងបានឮ ភ្នែកយើងក៏បានឃើញ អ្នកជម្លៀសយើងបានពោលឡើងស្ទើរគ្រប់ម៉ាត់មុង មួយណាក៏គ្មានជៀសផុតពីឆ្អឹងខ្មោចឡើយ បានសេចក្តីថា បរិវេណវត្តគ្រោះ ដ៏ធំធេងនេះ គឺពោរពេញទៅដោយរណ្តៅផុត និងកប់ខ្មោចគ្មានចន្លោះបានប៉ុន្មានកន្លែងឡើយ ។

ការធ្វើដំណើរចេញជាង២០គីឡូម៉ែត្រនេះ ធ្វើឲ្យយើងយល់បានហើយនូវប្រយោគអង្គការដែលថា ស្នើឲ្យយើងចាកចេញតែ៣ថ្ងៃនោះ នឹងមិនមែនជាការពិតឡើយ ពីព្រោះនៅតាមដងផ្លូវនេះ ផ្ទះដង្ក្រឹងៗ គ្មានម្ចាស់នៅទេ ពួកគេក៏ត្រូវជម្លៀសដែរ តើទៅខាងណា? គ្មាននរណាដឹងបានទេ? ពួកយើងក៏មិនដឹងជាគេឲ្យទៅដល់ណាដែរ? យើងស្មានថា ព្រែកព្នៅ វត្តគ្រោះ ព្រែកក្តាមនេះ មានអ្នកម្ចាស់ស្រុករស់នៅ ហើយកំពុងទទួលអ្នកចេញពីភ្នំពេញឲ្យស្នាក់នៅត្រៀបត្រាហើយ តែពុំពិតទេ តើអ្វីទៅជាផែនការអង្គការ?

នៅរវាងថ្ងៃ២៥ មេសា សូរសព្ទរំពង សំឡេងមួយគ្រឿង បានដំឡើងនៅវត្តគ្រោះ ។ សូមបងប្អូនជនរួមជាតិដែលស្នាក់នៅទីនេះ រង់ចាំស្តាប់អង្គការថ្នាក់លើ អង្គការសូម ប្រកាសផ្សព្វផ្សាយដំណឹងដល់ជនរួមជាតិថា បងប្អូនណាដែលមានបណ្តាស័ក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ព្រមទាំងក្រុមគ្រួសារផង អញ្ជើញមកចុះឈ្មោះនៅទីចាត់ការ ដើម្បីរៀបចំដំណើរចូលទៅកាន់ទីក្រុងភ្នំពេញវិញ ធ្វើការរួមចំណែកកសាងប្រទេសឡើងវិញ ជាមួយកងកម្លាំងរំដោះជាតិយើង ។

ពាក្យឃោសនានេះ បានផ្សាយហើយផ្សាយទៀត ។ ជួយគិតគ្នាមើល តើគួរទៅឬកុំទៅ? សំឡេងខ្សឹបខ្សៀវរបស់នាយទាហាន ។

ពិបាកទុកចិត្តណាស់ តិចគេបញ្ឆោតយកយើងទៅសម្លាប់ទាំងពូជផងទេដឹង ។ សំឡេងខ្សឹបខ្សៀវដ៏អួលដើមកបានលេចឮឡើង ។

ច្បាំងដើម្បីរំដោះជាតិ តើរំដោះបានប្រទេសជាតិ ប្រជាជនទាំងមូលហើយ យកទៅ សម្លាប់ដើម្បីអ្វី?

អ៊ំ សារី ៖ សម្លាប់ប្រជាជនបានប្រយោជន៍អ្វី? រំដោះជាតិយកទៅឲ្យនរណាវិញ?

ថ្ងៃណាក៏បុណ្យ ថ្ងៃណាក៏បុណ្យ បុណ្យជារៀងរាល់ថ្ងៃនេះ ហើយសម័យបដិវត្តន៍ ជ័យជម្នះ បានមកជាប្រាកដ ។

យើងដាំ ដាំៗ ជារៀងរាល់ថ្ងៃ មិនឲ្យសល់ដីមួយចម្អាមឡើយ ។

រលកបទចម្រៀងនៃសំឡេងវិទ្យុកម្ពុជាប្រជាធិបតេយ្យ បានរសាត់ចូលសោតា មនុស្សមួយក្រុមដែលកំពុងជជែកគ្នា ។

ឮឬទេ យើងផ្ទៀងស្តាប់ចម្រៀងដ៏មានន័យនេះចុះ មិនខុសទេសម័យកាលណាក៏ដោយ សិល្បៈជាទម្រង់ខ្ពស់បំផុតនៃមនសិការសង្គម តែសិល្បៈល្អ គឺសង្គមល្អហើយ សិល្បៈបោះជំហានទៅណា គឺជាសង្គមបោះជំហានទៅនោះឯង ។ យើងឮហើយ សិល្បៈរបស់សង្គមថ្មីនេះ គឺគេគិតតែពីកសាងជាតិ គួរឲ្យជ្រះថ្លាណាស់ ខ្ញុំទៅហើយ ទៅចុះឈ្មោះ គ្រួសារប្រពន្ធកូនខ្ញុំ ខ្ញុំត្រូវចុះឈ្មោះប្អូនខ្ញុំថា ជាកូនថែមទៀត ចុះឈ្មោះប្អូនស្រីមេម៉ាយខ្ញុំ ថាជាប្រពន្ធទី២ដើម្បីឲ្យបានទៅភ្នំពេញជុំគ្នា ។ នេះជាសេចក្តីសម្រេចចិត្តរបស់អ៊ំ សារី ។

ថ្ងៃទី២៦ មេសា ប្រមាណប្រហែលម៉ោង២រសៀល ក្បួនរថយន្តកុងវ័រប្រមាណ៧ គ្រឿង បានតម្រៀបគ្នាលើផ្លូវជាតិលេខ ៥ មុខវត្តគ្រោះ ដើម្បីរង់ចាំដឹកទាហានមានបណ្តាស័ក្តិ និងក្រុមគ្រួសារចូលភ្នំពេញវិញ ។ គ្រួសារខ្ញុំទាំងអស់គ្នា ក៏បានឡើងអង្គុយលើរថយន្តនេះ រង់ចាំការចេញដំណើរនឹងគេដែរ ។ ម៉ោង៥ល្ងាច ពេលដែលក្បួនរថយន្តរៀបចាកចេញទៅ ដោយរថយន្តនីមួយៗ ផ្ទុកមនុស្សហូរហៀរហួសចំណុះ ខ្លះជិះពីលើដំបូល ខ្លះឈរ តោងពីក្រោយ ពីចំហៀង ។ កងទ័ពរំដោះបានចេញបញ្ជាម្តងទៀតថា អង្គការដឹងថា បងប្អូនខ្លះមិនមែនជាក្រុមគ្រួសារផ្ទាល់របស់មេទាហានមានបណ្តាស័ក្តិទេ អ្នកខ្លះគ្រាន់តែជាប្អូន ជាក្មួយ បានលួច

បន្ទំឡើងរថយន្តដែរ អង្គការនឹងមិនទទួលខុសត្រូវចំពោះការខូចរបប ហូបចុកសម្រាប់អ្នកបែបនេះទេ ។ អ្នកម៉ែ និងខ្ញុំ យើងសម្រេចចិត្តចុះចេញពីរថយន្តនេះភ្លាម ម៉្យាងយើងគ្មានចំណង់ចូលទៅវិញទេ ព្រោះយើងធ្លាប់ហែលជាមួយសារជាតិសាហាវរបស់ខ្មែរក្រហមហើយ យើងគ្មានសុទិដ្ឋិចំពោះពួកនេះទៀតទេ យើងឡើងលើឡាននេះ ក្នុងអារម្មណ៍អន្ទះសារ ដោយសារតែការគោរពចំពោះឆន្ទៈលោកអ៊ីតែប៉ុណ្ណោះ ស្រុកកំណើត ឯនោះទេ ដែលជាគោលដៅរបស់យើង ។ យើងនឹកស្រុកកំណើតណាស់ សន្តិភាពមកដល់ហើយ យើងចង់ឃើញភូមិកំណើត យើងចង់ជួបញាតិសន្តានដែលធ្លាប់កំសត់កម្រ តើអ្នកណារស់ អ្នកណាស្លាប់ខ្លះទៅ យើងពិបាកសង្ឃឹមណាស់ថា ខ្មែរក្រហមឲ្យយើងធ្វើដំណើរ តាមចិត្តប៉ង ប៉ុន្តែបើមានឱកាសយើងនឹងឆ្លៀត និងម៉្យាងទៀត យើងគិតថា បើពាក្យថា ចូលទៅជួយកសាងជាតិ ជាការពិតគឺយើងធ្វើឲ្យលោកអ៊ីពិបាកដោយសារយើងហើយ ។

បន្ទាប់ពីយើងចុះចេញមកក្បួនរថយន្តទាំងនោះ ក៏បានចាកចេញពីវត្តគ្រោះទៅ ។

ថ្ងៃទី២៧ មានការចុះឈ្មោះអ្នកស្ម័គ្រចិត្តធ្វើដំណើរថ្មើរជើងម្តងទៀត ។ មានមនុស្ស មួយក្រុមប្រមាណ៧០នាក់ បានចុះឈ្មោះស្ម័គ្រចិត្តធ្វើដំណើរថ្មើរជើងចូលទៅទីក្រុងភ្នំពេញ ដើម្បីរួមចំណែកកសាងជាតិ ព្រោះកាលពីម្សិលមិញពួកគេនៅអល់អែកលាក់ខ្លួន ។ ក្រុមយោធាមួយកងតូច បានដឹកនាំក្បួនដំណើរចេញទៅ ប្រមាណម៉ោង៤រសៀល ពួកស្ម័គ្រចិត្តក្រោយនេះទៅតែខ្លួនទេ ប្រពន្ធកូនរបស់ពួកគេ សម្ងំនៅវត្តគ្រោះសិន ពីព្រោះអង្គការមិនឲ្យយកកូនចៅរញេចរញោចតាម ។ ម៉ោង៧យប់ ភរិយាអ្នកវិលចូលភ្នំពេញ ដែលអង្គុយរង់ចាំដំណើរប្តីតាមដងផ្លូវនោះ បានប្រទះឃើញកងទ័ពដែលនាំអ្នកថ្មើរជើងយើងចេញដំណើរទៅម៉ោង៤រសៀលនោះ បានត្រឡប់មកវិញ ដោយអ្នកខ្លះមានទាំងកាន់ក្រមា ពាក់អាវប៉ារ៉ាអាមេរិកាំង ពាក់អាវពីឡុត ឬពាក់នាឡិកាដៃរបស់នាយទាហានស្ម័គ្រចិត្តទាំងនោះផង ។

ទំនួញខ្សឹបខ្សៀវរបស់ភរិយាអភ័ព្វទាំងនោះ បានលេចព្រឺឡើងយ៉ាងលួចលាក់ ។

ឃ្លាតចាកពីលោកអ៊ំ សារី គ្រួសារខ្ញុំមិនអាចទៅដល់ស្រុកកំណើតបានទេ ។ ការធ្វើដំណើរនេះស្ថិតនៅក្រោមការចាត់ចែងរបស់អង្គការ ។ យើងត្រូវអង្គការបំបែរទិសដៅ ដំណើរយើងឲ្យទៅរស់នៅក្នុងភូមិត្រពាំងខ្វាត់ព្រាយ ស្រុកឧដុង្គ នាជើងភ្នំព្រះរាជទ្រព្យ ។ កូនខ្ទមឫស្សីប្រកស្លឹកត្នោត គ្រែធ្វើអំពីធាងត្នោត ទោះជាពិបាកខ្លាំងក្តី ដោយស្ត្រីជាច្រើន ត្រូវឡើងកូនត្នោតតូចៗ តាមដែលអាចឡើងបាន ត្រូវចូលព្រៃឫស្សី ឆ្ការកាប់យកដើមឫស្សីមកសង់ជម្រក ដោយខ្លួនឯង ។ គ្រួសារនីមួយៗមិនសូវមានមនុស្សប្រុសទេ បុរសជាច្រើន បានត្រូវសម្លាប់ក្នុងសង្គ្រាម៥ឆ្នាំនេះ ។ យើងត្រូវដើររើសធាងត្នោតទុំជ្រុះយកមកធ្វើជារនាបគ្រែ គាវត្នោតងាប់ជាខសដុត រើសផ្លែត្នោតទុំមកស្ងោរ ឬដុតជំនួសនំនែកដែលធ្លាប់ទិញ គួរឲ្យស្ងើចសរសើរ ដោយស្រុកឧដុង្គសម្បូរដោយសម្បត្តិធម្មជាតិយ៉ាងពិសេស ផ្តល់លទ្ធភាពរស់ឲ្យប្រជាជនជម្លៀសពីក្រុងភ្នំពេញរាប់ពាន់គ្រួសារអាចចាប់ផ្តើមជីវិត ដោយបាតដៃទទេបាន ។

ម្នាក់ៗខំស្រវាវេចប្រាក់មាសពេជ្រទៅតាមខ្លួនយ៉ាងប្រុងប្រយ័ត្ន សង្ឃឹមថា យើងអាចទិញជម្រក និងស្បៀងអាហារបានតែផុយស្រឡះ អង្គការប្រកាសឈប់ទទួលស្គាល់ក្រដាសប្រាក់ដោយចាត់ទុកថា ជាមធ្យោបាយរបស់ចក្រពត្តិដែលខ្ជិលច្រអូសមិនព្រមធ្វើពលកម្មដោយខ្លួនឯង ហើយយកប្រាក់ទៅទិញពលកម្មអ្នកដទៃជំនួសវិញ អង្គការចាត់ទុកប្រាក់ជាមធ្យោបាយកេងប្រវ័ញ្ចពលកម្មរបស់ចក្រពត្តិនេះ គឺជាអ្វីដែលបដិវត្តន៍ស្អប់ខ្ពើមបំផុត ។ សេចក្តីប្រកាសនេះបានធ្វើឡើង នៅរវាង ២-៣ អាទិត្យក្រោយថ្ងៃរំដោះ ។

ព្រឹកទី១ ម៉ែ និងខ្ញុំ ក៏ដូចជាប្រជាជនឯទៀត បានទទួលចបកាប់ និងពូថៅគ្រប់ដៃពីអង្គការថ្នាក់ភូមិ ប្រកាសបើកទិវាពលកម្មស្តាព្រៃស្បាតរាប់សិបហិកតា សម្រាប់ធ្វើដំណាំស្រូវ ស្តាមាតុភូមិឡើងវិញ ។ យើងត្រូវកាប់ព្រៃដែលមានដើមឈើធំៗ ដើមឈើខ្លះកាប់រាប់រយពូថៅទើបរលំ យើងត្រូវកាយដីប្រឡោះជុំវិញឫសឈើ លុងឲ្យផុតឫសកែវ ដែលមានជម្រៅរហូតទៅដល់២ម៉ែត្រ ទំហំមាត់រណ្តៅរហូតទៅដល់៥ម៉ែត្រក៏មាន ទើសឫសត្រង់ណាទើបប្រើពូថៅកាប់ចោលត្រង់នោះ បើប៉ះដី និងថ្មរឹង យើងប្រើត្រសេះសម្រាប់ចោះ ប្រែះលុះគ្រាតែសម្រេចផែនការបក្ស ។

*បក្ស ដាក់ផែនការត្រង់ណា ត្រូវតែសម្រេចត្រង់នោះជូនបក្សឲ្យបានដាច់ខាត ។ ទោះបីបាតដៃឡើងពងរហូតហូរទឹករងៃឡាក់ក្តី ទោះបីទទួលរបបអង្ករ តែកន្លះកំប៉ុងក្នុងមួយថ្ងៃ ត្រូវហូបទំពាំងប្ញស្សី ត្រកួន សម្រាប់បង្គ្រប់ការស្រេកឃ្លានក្តី ក៏ញើសយើងត្រូវតែហូរពីព្រលឹមទល់ព្រលប់ ហូរដូចទឹកភ្លៀង ហូរស្ទើរខ្សោះអស់ពីរាងកាយ មិនអាចស្រាកស្រាន្ត ។*

*មកដល់ថ្ងៃនេះ គិតទៅជាង៣ខែហើយ បន្ទាប់ពីការចាកចេញពីទីក្រុងភ្នំពេញមក ថ្ងៃណាក៏ពលកម្ម ថ្ងៃណាក៏សម្រុកកាប់គាស់ ដកស្ទូងតាំងពីមុនព្រលឹមរហូតដល់ក្រោយព្រលប់គ្មានស្រាកស្រាន្ត ។ កំពុងតែកាប់គាស់ញើសស្រោចជោគប្រាណថ្ងៃនេះ ស្នូរធឹកៗៗ នៃឧត្តម្ភាគចក្រមួយ ហោះយ៉ាងខ្ពស់ពីទិសខាងជើងលឹមៗមក ហោះកាត់ពីស្រុកខដុក្ក របស់យើង វាតម្រង់ទៅភ្នំពេញ មែនហើយ វាដាំក្បាលចុះហើយ! ឱ! ព្រះអើយ! ឱ! ភ្នំពេញ អើយខ្ញុំនឹកអ្នកណាស់ តើមានព្រឹត្តិការណ៍អ្វីប្លែកទៅ? វិទ្យុខ្ញុំ ដែលខ្ញុំបានផ្លាស់ថ្មីនៅថ្ងៃ១៧ មេសា មុននឹងចាកចេញពីភ្នំពេញមក បានអស់ថ្មពីរបីថ្ងៃទៅហើយ ថ្ងៃត្រង់នេះ ពេលអាហារថ្ងៃត្រង់ ខ្ញុំខំឆ្លៀតហាលថ្មវិទ្យុ ក្រែងលោយប់នេះ បានស្តាប់ព័ត៌មានដឹងថា យន្តហោះមកចុះភ្នំពេញ មានអ្វីកើតឡើង ។ ពិតមែនសំឡេងខ្សាវៗបំផុតនៃដង្ហើមចុងក្រោយរបស់ថ្មវិទ្យុខ្ញុំ បានឲ្យខ្ញុំស្តាប់ព័ត៌មានល្ងាចនោះប្រហែលកន្លះម៉ោង ។ ព័ត៌មានបានឲ្យដឹងពីកងទ័ព និងកម្មាភិបាលយោធាបដិវត្តន៍បានរៀបចំបដិសណ្ឋារកិច្ចទទួលសម្តេចឪ នៅព្រលានយន្តហោះពោធិ៍ចិនតុង ។ យើងឮសូរស្នូរយន្តហោះចុះចតយើងឮស្នូរទះដៃយ៉ាងស្រុះគ្នាបំផុត តែហាក់មានសភាពស្ងៀមស្ងាត់ និងប្រុងប្រយ័ត្នខ្លាំងណាស់ ព្រោះគ្មានស្នូរអ្វីក្រៅពីនេះលាយឡំបន្តិចសោះឡើយ រួចបន្ទាប់មក ព្រះសូរសៀងរបស់សម្តេចឪបានថ្លែង ឡើង "ខ្ញុំព្រះករុណាខ្ញុំ សូមថ្លែងអំណរគុណជាពន្លឹកចំពោះ យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍ដ៏មហិមារបស់យើង ចំពោះការដែលបានអនុញ្ញាតឲ្យខ្ញុំ ដឹកព្រះសពរបស់ មាតាខ្ញុំដែលបានតម្កល់នៅប៉េកាំងអស់មួយរយៈមកហើយ មកកាន់ទីក្រុងភ្នំពេញយើង តាមរយៈឧត្តម្ភាគចក្រចិននេះ មកធ្វើបុណ្យបូជាតាមប្រពៃណីជាតិយើង ។ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមថ្លែងផងដែរចំពោះលោកប្រធានម៉ៅ ដ៏មហិមាដែលបានជួយខ្ញុំ ទោះជាលោក មិនយល់ព្រមឲ្យខ្ញុំថ្លែងអំណរគុណចំពោះលោកក្តី ក៏ខ្ញុំចាំបាច់ត្រូវតែថ្លែងនូវអំណរគុណដ៏មហិមា ចំពោះលោក" ។ ថ្មវិទ្យុយើងបានបញ្ចប់ជីវិតខ្លួនតែត្រឹមនេះទៅ បន្សល់ទុកនូវតែការសោកស្តាយក្នុងដួងចិត្តយើង ពីថ្ងៃនេះទៅ យើងបាត់បង់ត្រចៀកជារៀងរហូតហើយ ។ យើងយល់ថា ព្រះសូរសៀងដ៏ខ្លីនោះថ្លែងឡើងក្នុងការប្រុងប្រយ័ត្នយ៉ាងអាថ៌កំបាំង និងថែមទាំងក្នុងសភាពខំទប់ព្រះទ័យយ៉ាងខ្លាំងប្រឆាំងនឹងភាពក្តុកក្តួលយ៉ាងឥតឧបមារបស់ទ្រង់ យើងរកស្មានមិនដល់ យល់មិនបានទេ ថាព្រះករុណា អង្គព្រះសម្តេចឪដែលធ្លាប់ជាប្រធានរណសិរ្សសេរីកាជាតិ ដែលជាអ្នកស្រែកអំពាវនាវហើយអំពាវនាវទៀតឲ្យកូនចៅ ប្រជាកសិករ សិស្សនិស្សិត ព្រះសង្ឃ បញ្ញវន្តរត់ចូលព្រៃម៉ាគី សាមគ្គីស្មាគៀកស្មាគ្នាជាមួយទ្រង់ ជាមួយកងទ័ពរណសិរ្សសេរីកាជាតិ ហេតុអ្វីក៏ទ្រង់ត្រូវយាងចូលមកដល់ប្រទេស ទាំងក្នុងសភាពដែលមិនទទួលបានភាពស្និទ្ធស្នាល កក់ក្តៅ ពីបដិវត្តន៍យ៉ាងនេះ?*

*ស្នូរត្រដោកប្ញស្សីម៉ោង៤ទៀបភ្លឺដាស់យើងឲ្យម្នាក់ៗចាប់ទាញចប ពូថៅ រត់ចូលជួរ ។ នេះជាការប្រជុំជួរពេលព្រឹក ដែលអង្គការតែងតែចំណាយពេលរវាងមួយម៉ោង ដើម្បីដុសខាត់ជម្រះសតិអារម្មណ៍ចាស់ ក៏ដូចជាបំពាក់ឲ្យយើងនូវមាគ៌ាថ្មីរបស់បដិវត្តន៍ក្រហមឆ្អិនឆ្អៅរបស់បក្ស ។ យើងជាប្រជាជនថ្មី ការរៀនសូត្រពីប្រជាជនចាស់ ឬអ្នកមូលដ្ឋាន ជាពិសេស ពីគណៈសហករណ៍របស់យើង ជាការចាំបាច់ណាស់ ។*

*សមមិត្តប្រធានភូមិៈ ពេលនេះទើបរំដោះ អង្គការខ្វះខាតស្បៀងសម្រាប់ឧបត្ថម្ភ បងប្អូនទ្រាំសិនទៅ ទម្រាំកាប់ព្រៃរួច លើកជាភ្លឺស្រែ រួចយើងស្ទូងស្រូវ តែមួយរដូវជីវភាព បងប្អូនលែងខ្វះខាតហើយ ។*

*ត្រូវហើយគស៊ូសិនទៅកូន ម៉ែដឹងថា កូនៗឃ្លានណាស់ ទោះម្ហូបឆ្ងាញ់ ឬមិនឆ្ងាញ់ ម៉ែមិនដែលឲ្យកូនហូបមិនឆ្អែតទេ អង្គការលើកឡើងយុទ្ធសាស្រ្តឲ្យមួយរដូវខាងមុខ យើងនឹងបានហូបឆ្អែតហើយណា ។ អ្នកម្តាយលួងលោមខ្ញុំ និងប្អូនខ្ញុំ ។*

***(តទៅលេខក្រោយ)***

**អ៊ុំ ឧណ្ណា**

# ដំណើរស្វែងរកម្តាយមីងដែលបាត់ខ្លួន

នាងខ្ញុំឈ្មោះ ហេឡែន ត្រាន បច្ចុប្បន្នរស់នៅប្រទេសអូស្រ្តាលី ។ នាងខ្ញុំបាត់ម្តាយមីងម្នាក់ឈ្មោះ លឿង ធីក ហា ។ ម្តាយមីងរបស់ខ្ញុំរស់នៅប្រទេសវៀតណាម ដែលមានអាសយដ្ឋាន ៤២១/៩ បេន ភូ ឡាម ទីក្រុងហូជីមិញ នៅមុនសម័យខ្មែរក្រហម ។ នៅឆ្នាំ១៩៧៤ ម្តាយមីងរបស់ខ្ញុំ ដែលពេលនោះមានអាយុ១៨ឆ្នាំ បានមកលេងបងប្អូនដែលរស់នៅប្រទេសកម្ពុជា តែជាអកុសល ពេលរបបខ្មែរក្រហមចូលមកដល់ គាត់មិនបានវិលត្រឡប់ទៅប្រទេសវៀតណាមវិញទេ ។ បងប្អូនរបស់ម្តាយមីងខ្ញុំនៅពេលនោះ មានផ្ទះនៅលើផ្លូវលេខ៨០ មុំសាលាយុគន្ធរ ក្រុងភ្នំពេញ ប្រទេសកម្ពុជា និងមានបើកហាងលក់គ្រឿងលង្ហារ ។

នាងខ្ញុំបានភ្ជាប់មកជាមួយនូវរូបថតចំនួន៧សន្លឹក និងព័ត៌មានដែលទាក់ទងជាមួយរូបថតទាំងនេះដូចខាងក្រោម ៖

◆ **រូបថតទី១**


尋人啓事
梁耀池，現居澳洲南部，現找尋：
①大妹夫：吳乃瑜及大妹：梁巧堅。外甥：
、鑑江、鑑津，甥女：景芳、景芬、景珍(全
住金邊市，育干托街80號)。
②妹夫：吳光華及小妹：梁慧堅(細堅)。甥女：鳳儀、靜儀
③女兒：梁淑霞，前住越南堤岸富林街421/9。(1974年曾住
金邊市，解放後失去聯絡)。
如有仁人君子知其下落，請與下列地址聯絡，不勝感激，當

ជាសេចក្តីប្រកាសរកម្តាយមីងដែលបានបាត់ខ្លួន ផ្ញើរចេញពីប្រទេសអូស្រ្តាលី ទៅកាន់កាកបាទក្រហមអន្តរជាតិនៅប្រទេសកម្ពុជាពីឆ្នាំ១៩៨០ ទៅ ១៩៨២ ដើម្បីស្រាវជ្រាវរកព័ត៌មាន ។ នៅក្នុងសេចក្តីប្រកាសនេះ មានផ្ទុកនូវអាសយដ្ឋានសាច់ញាតិដែលម្តាយមីងខ្ញុំស្នាក់នៅ កំឡុងពេលដែលគាត់មកលេងប្រទេសកម្ពុជា និងដាក់ឈ្មោះជីតារបស់ខ្ញុំ គឺ លឿង ដែលបានប្រកាសរកម្តាយមីងខ្ញុំ ។

◆ **រូបថតទី២**




រូបទីពីរនេះ គឺបានសរសេររៀបរាប់អំពីទីតាំងរបស់រោងកុនមួយដែលស្ថិតនៅពីមុខផ្ទះរបស់បងប្អូន និងសាច់ញាតិរបស់ម្តាយមីងខ្ញុំនៅក្នុងប្រទេសកម្ពុជា នាសម័យនោះ ។

◆ **រូបថតទី៣**



រូបថតខាងលើ បងប្អូនរបស់ខ្ញុំនៅក្រុងភ្នំពេញ ប្រទេសកម្ពុជា ដែលមីងរបស់ខ្ញុំបានមកស្នាក់នៅជាមួយ ។



◆ **រូបថតទី៤**

រូបថតទី៤នេះ គឺជារូបមីង របស់ខ្ញុំនៅពេលដែលគាត់ មានអាយុចន្លោះ ១៨ ទៅ ២០ឆ្នាំ ។ គាត់បានបាត់ខ្លួននៅ ប្រទេសកម្ពុជានៅពេលដែល គាត់មានអាយុប្រមាណជាង ២០ឆ្នាំ ។

◆ **រូបថតទី៥**



រូបថតទី៥នេះ គឺជារូប ម្តាយរបស់ខ្ញុំដែលត្រូវជា បងស្រីបង្កើតរបស់ម្តាយមីង ដែលបានបាត់ខ្លួននៅប្រទេស កម្ពុជា នៅក្នុងអំឡុងរបបខ្មែរ ក្រហមគ្រប់គ្រង ។ ម្តាយខ្ញុំ នៅក្នុងរូបថតនេះមានអាយុ ចន្លោះ១៤-១៥ឆ្នាំ ។

◆ **រូបថតទី៦**

រូបថតទី៦ គឺជាការជួបជុំគ្រួសាររបស់ខ្ញុំ រួមមាន ជីដូនជីតា ម្តាយ មីង និង ពូ ។ រូបមីងរបស់ខ្ញុំគឺមានគូសរង្វង់នៅខាងស្តាំ ។



◆ **រូបថតទី ៧**



រូបថតទី៧ យាយតារបស់ខ្ញុំ ដែលត្រូវជា ឪពុក និង ម្តាយ របស់មីងដែលបានបាត់ខ្លួន ។

ប្រសិនបងប្អូនបានស្គាល់ម្តាយមីងខ្ញុំដូចមានរៀបរាប់ខាងលើ សូមទំនាក់ទំនងមកនាងខ្ញុំ ហេឡែន ត្រាន តាមរយៈ អ៊ីម៉ែលៈ *helen_tran@live.com* និងម្តាយរបស់ខ្ញុំ លឿង ធីក ធឿង ។ សូមអរគុណ! ដោយសេចក្តីគោរពពីខ្ញុំ **ហេឡែន**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 218, February 2018 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.